ISSN 1560-7615

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៨ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៤ | តម្លៃ ១.៥០០៛

# តើប័ណ្ណសំគាល់កម្មសិទ្ធិជួយកាត់បន្ថយភាពក្រីក្រនៅជនបទកម្ពុជាដែរទេ?

**រាជរដ្ឋាភិបាលកម្ពុជា នឹងចេញប្លង់ដីចំនួន ១លាន ក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ។ ក្នុងអត្ថបទនេះ លោក Brett Ballard និង លោក សូ សុវណ្ណារិទ្ធិ ពិភាក្សាវែកញែកថា តើប្លង់ដីអាចផ្តល់អត្ថប្រយោជន៍ដល់គ្រួសារជនបទ នឹងជួយរួមចំណែកកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្តេច?***

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ (MLMUPC) កំពុងអនុវត្តគំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី (LMAP) ដោយមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ ដើម្បីពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី និងប្រព័ន្ធគ្រប់គ្រងដីធ្លី ។ ក្នុង LMAP មានសកម្មភាពច្រើនទៀត ជា អា ទ៍



*ខេត្តព្រៃវែង ស្រុកបាភ្នំ ឃុំរាក់ជ័យ ថ្ងៃទី៣០ ធ្នូ ២០០៣ ។ ការងារធ្វើប័ណ្ណសំគាល់កម្មសិទ្ធិ បានចាប់ផ្តើមនៅក៏រិតភូមិ ដោយអ្នកភូមិផ្តល់ពត៌មានពីដីរបស់ខ្លួន ទៅឱ្យមន្ត្រី LMAP (រូបភាព LMAP) ។*

ការគ្រប់គ្រងកម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិជាប្រព័ន្ធ ដែលក្នុងនោះមានការចេញ នូវ ១លានប័ណ្ណប្លង់ដីក្នុងរយៈពេល១៥ឆ្នាំ ។ នៅជនបទ ផលចំណេញរំពឹងទុក រួមមានកំនើន វិនិយោគ ផលិតភាពផ្នែកកសិកម្ម និងការអភិ វឌ្ឍន៍ទីផ្សារដីធ្លី គឺមានប្រសិទ្ធិភាពល្អ ។ ផល ចំណេញទាំងនេះ និងផលចំណេញផ្សេងទៀត រំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការ កាត់បន្ថយភាពក្រីក្រនៅជនបទ ។

នៅដើមឆ្នាំនេះ CDRI សហការជាមួយ MLMUPC ដើម្បីធ្វើអង្កេតជាមូលដ្ឋានមួយលើ ១.២៣២គ្រួសារ ។ ទិន្នន័យ ប្រមូលបាននឹងប្រើការដើម្បីវាយតំលៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គមកិច្ចនៃប័ណ្ណសំគាល់កម្មសិទ្ធិនៅក្រោយរយៈពេលបីឆ្នាំ ។ អត្ថបទនេះរាយការណ៍ពីទិន្នន័យគន្លឹះដែលទទួលបានពី ៣៣ភូមិ ក្នុង៤ខេត្តមាន LMAP (កំពង់ចាម កំពង់ធំ ក្រុងព្រះសីហនុ និងតាកែវ) និងដែលប្រមូលលើ ៩១៦ គ្រួសារ ក្នុងនេះមាន ២២៥គ្រួសារគឺមានស្រ្តីជាមេគ្រួសារ ។ ក្នុងមួយភូមិៗ ប្រហែល ២៥-៣០គ្រួសារត្រូវបានជ្រើសរើសដោយចៃដន្យ ទៅតាមទំហំដីកសិកម្មកាន់កាប់ និងភេទនៃមេគ្រួសារ ។ អត្ថបទនេះពិភាក្សាផងដែរពីអត្ថប្រយោជន៍រំពឹងទុកនៃប័ណ្ណសំគាល់កម្មសិទ្ធ និងធ្វើសេចក្តីសន្និដ្ឋាន ដោយមានផ្តល់អនុសាសន៍អំពីកម្មវិធី និងគោលនយោបាយ ។

## ទ្រឹស្តី និងការអនុវត្តន៍ទាក់ទិននឹងការចេញប័ណ្ណសំគាល់កម្មសិទ្ធិ

ហេតុផលនៃកម្មវិធីចេញប័ណ្ណប្លង់ដីផ្អែកលើទ្រឹស្តីអំពីកម្មសិទ្ធិអចលនទ្រព្យ និងការស្រាវជ្រាវដែលបង្ហាញពីចំណងទាក់ទងរវាងការកាន់កាន់ដីមានសុវត្ថិភាព និងការវិនិយោគលើដីធ្លី ព្រមទាំងការអភិវឌ្ឍន៍ទីផ្សារដីធ្លី និងហិរញ្ញវត្ថុដ៏មានប្រសិទ្ធិភាព។ យោងតាមទ្រឹស្តីនេះ (Feder and Feeney,

* អត្ថបទនេះដកស្រង់ពីគំរោងអង្កេតជាមូលដ្ឋានមួយធ្វើដោយ វបសអ សហការជាមួយ MLMUPC ដោយមានជំនួយថវិកាពីធនាគាពិភពលោក ។ របាយការណ៍ពេញ លេញនៃការសិក្សានេះនឹងចេញផ្សាយនៅខែសីហា ២០០៤ ។ លោក Brett Ballard ជាទីប្រឹក្សាបច្ចេកទេសសំរាប់គំរោងអង្កេតនេះ ហើយលោក សូ សុវណ្ណារិទ្ធិ ជាអ្នក ស្រាវជ្រាវជាន់ខ្ពស់នៅ វបសអ។

## មាតិកា

តើប័ណ្ណសំគាល់កម្មសិទ្ធិអាចជួយកាត់បន្ថយភាពក្រីក្រនៅជនបទកម្ពុជាដែរឬទេ?. ១
សមាគមតាមវត្ត និងការផុសចេញសង្គមស៊ីវិលនៅកម្ពុជា ........ ៥
ការកសាងផែនការគ្រាន់តែជាជំហានមួយប៉ុណ្ណោះ ........ ៨
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស ........ ១២
— ស្ថានភាពក្នុងប្រទេស ........ ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៧
ពត៌មានថ្មីៗពី វបសអ ........ ២០

1996) ប័ណ្ណប្លង់ដីផ្តល់ទំនុកចិត្តដល់ប្រជាជនថា ខ្លួនគេ ឬអ្នកស្នងមរតករបស់គេ នឹងបានទទួលអត្ថប្រយោជន៍ពីការវិនិយោគ។ ម្ចាស់ដីក៏អាចប្រើប័ណ្ណប្លង់ដីជាវត្ថុដាក់ធានា ដើម្បីបានឥណទានសំរាប់កែលំអផលិតកម្មកសិកម្ម ឬចាប់ផ្តើមមុខរបរថ្មី ។ នៅពេលតំលៃដីកើនឡើងទីផ្សារដីធ្លីនឹងតំរែតំរង់ការប្រើ ប្រាស់ដីទៅរកការប្រើប្រាស់ណាដែលមានផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។ កំណើនតំលៃដី ព្រមទាំងការរំពឹងទុកពីសុវត្ថិភាព នឹងបង្កើនការចុះបញ្ជីផ្លូវការ ដើម្បីកត់ត្រាពីការផ្ទេរដីធ្លី ។

ប្រទេសដែលធ្វើវិនិយោគលើការគ្រប់គ្រង ការកាន់កាប់ដីធ្លីឱ្យមានសមភាព និងប្រសិទ្ធភាពខ្ពស់ ច្រើនតែមានការអភិវឌ្ឍន៍លឿនជាងប្រទេសដែលមិនបានធ្វើវិនិយោគបែបនេះ ។ម្យ៉ាងទៀត កង្វះសមភាពក្នុងលទ្ធភាពប្រើប្រាស់ដី និងសុវត្ថិភាពក្នុងកាន់កាប់ដី វារួមចំណែកបង្កភាពក្រីក្រតោកយ៉ាក ការពឹងផ្អែកខ្លាំង និងលំនាំគ្មានចិរភាពនៃចំណាកស្រុកនៅជនបទ (Munro Faure, 2002) ។ ការសិក្សាលើការចេញប័ណ្ណសំគាល់កម្មសិទ្ធិនៅថៃ និងប្រទេសផ្សេងទៀត ក៏បង្ហាញដែរថា ផលប៉ះពាល់លើការលូតលាស់ខាងសេដ្ឋកិច្ច និងសង្គមកិច្ច អាចមានទំហំធំធេងណាស់ (Onchan and Aungsumalin, 2002) ។

ប៉ុន្តែ ការបែងចែកអត្ថប្រយោជន៍នៃការចេញប្លង់ដី ប្រហែលពុំមានសមភាពរវាងក្រុមសេដ្ឋកិច្ច-សង្គមកិច្ចនានាទេ ដោយសារពុំមានគោលនយោបាយសំរាប់បំពេញបន្ថែម និងស្ថាប័នគាំទ្រផ្សេងៗសំរាប់ជំរុញការគោរពសិទ្ធិលើដីធ្លី និងធ្វើឱ្យសេវាកម្មអភិវឌ្ឍន៍កាន់តែងាយបានទៅដល់ម្ចាស់ដីតូចៗ និងក្រុមងាយរងគ្រោះផ្សេងទៀត ។

## ការបែងចែកដីក្នុងក្រុមគ្រួសារបានធ្វើអង្កេត

គ្រួសារដែលកាន់កាប់ដីតិច គឺមានដីកសិកម្មតិចឡូត៍ (និងមានទំហំឡូត៍តូច) ជាងគ្រួសារដែលកាន់កាប់ដីធំ ។ ចំនួន និងទំហំដីឡូត៍ វាកើនឡើងយ៉ាងទៀងទាត់ពីគ្រួសារអ្នកកាន់កាប់ដីមួយថ្នាក់ ទៅមួយថ្នាក់ទៀត (តារាង ១) ។

ការពន្យល់ដែលមានលើកឡើងជារឿយៗគឺ លំនាំនេះចាប់ផ្តើមតាំងពីការបែងចែកដីនៅឆ្នាំ១៩៨៩ ដែលនៅពេលនោះមានការប្រឹងប្រែងចែកដីដែលមានឱ្យបានស្មើភាពគ្នា ទៅតាមចំនួនសមាជិកគ្រួសារគ្រប់អាយុពលកម្ម ។ គ្រួសារណាមានសមាជិកធ្វើពលកម្មច្រើននាក់ គឺទទួលបានដីច្រើន ហើយរឿងនេះនាំឱ្យមានលក្ខណៈខុសគ្នាមួយកើតតាំងពីដំបូងក្នុងការបែងចែកដីធ្លី ។

មរតកនៃការបែងចែកដីធ្លីឆ្នាំ១៩៨៩ ត្រូវបានឆ្លុះបញ្ចាំងដោយស្ថានភាពថា ៥៥% នៃគ្រួសារអង្កេត បានទទួលដីកសិកម្មពីរដ្ឋ (តារាង ២) ។ ទិន្នន័យអង្កេតក៏បង្ហាញពីបែបបទដែលគ្រួសារមានដីធំពីដំបូង បានទទួលដីបន្ថែមតាំងពីឆ្នាំ១៩៨៩មក ។ ឧទាហរណ៍ គ្រួសារមានដីធំ (ដែលមានទ្រព្យមូលធន និងចំណូលច្រើនជាងអ្នកមានដីតូច) គឺមានកើត ភាគរយនៃការរកបានដីបន្ថែមតាមរយៈការទិញនិងការកាប់ឆ្ការ ច្រើនជាងគ្រួសារមានដីតូចៗ ។ រូបភាពនេះហាក់បង្ហាញថា បើសិនគេមានដីកាន់តែច្រើន គេក៏រកដីបន្ថែមបានកាន់តែច្រើនដែរ ។

| តារាង ១: សង្ខេបគ្រួសារដែលកាន់កាប់ដីកសិកម្ម | | | | | | |
|---|---|---|---|---|---|---|
| ដីកាន់កាប់ (ហ.ត) | (ហ.ត) | ប្លង់ដីសរុប | ផ្ទៃដីសរុប | ផ្ទៃដី/ហ. | ប្លង់ដី/ហ.ត | ផ្ទៃដី/ប្លង់ |
| < 0.5 | 201 | 465 | 55.37 | 0.27 | 2.31 | 0.11 |
| 0.5 – 0.9 | 223 | 843 | 156.11 | 0.70 | 3.78 | 0.18 |
| 1.0 – 1.9 | 229 | 1,092 | 322.66 | 1.41 | 4.76 | 0.29 |
| 2.0 – 2.9 | 122 | 653 | 294.25 | 2.41 | 5.35 | 0.45 |
| > 3.0 | 132 | 826 | 634.50 | 4.80 | 6.25 | 0.76 |
| Total | 916 | 3,879 | 1,462.89 | 1.59 | 4.23 | 0.37 |

| តារាង២: ដីកសិកម្ម និងវិធីទទួលបានដី | | | | |
|---|---|---|---|---|
| ទំហំដី | រដ្ឋ | មតិក | ទិញ | ដីរាន |
| < 0.5 | 53.1 | 33.2 | 11.8 | 2.0 |
| 0.5 – 0.99 | 57.9 | 23.1 | 15.7 | 3.1 |
| 1.0 – 1.9 | 62.1 | 18.8 | 13.8 | 5.3 |
| 2.0 – 2.9 | 55.3 | 17.5 | 16.3 | 10.8 |
| > 3.0 | 46.6 | 20.8 | 17.6 | 15.0 |
| សរុប | 55.6 | 21.7 | 15.2 | 7.4 |

ការពន្យល់មួយទៀតពីលំនាំនៃការបែងចែកដី វាជាប់ទាក់ទងនឹងការកាត់ច្រៀកដីលំអិត តាមរយៈការលក់ដូរ និង/ឬការបន្តមរតក (So, Sophal and Acharya 2001; Biddulph, 2004) ។ ក្នុងចំណោមគ្រួសារមានដីតូច, ទំហំ និងចំនួនប្លង់ដី ហាក់ដូចជាថយចុះលឿនជាងគ្រួសារនានាដែលពុះចែកដីរបស់ខ្លួនឱ្យទៅកូនចៅ ។ មតិនេះហាក់ដូចមានការគាំទ្រពីទិន្នន័យអង្កេតដែលបង្ហាញពីលក្ខណៈញឹកញាប់ជាងនៃ ការទទួលបានដីតាមរយៈការបន្តមរតកក្នុងចំណោមគ្រួសារមានដីតូចៗ ។

ផលប៉ះពាល់នៃការចេញប័ណ្ណសំគាល់កម្មសិទ្ធទៅលើទំហំដី គឺជាបញ្ហាដ៏សំខាន់មួយ ។ ភស្តុតាងនៅថៃ បង្ហាញថា ចំនួន និងទំហំដីតាមគ្រួសារមាននិន្នាការថយចុះ នៅពេលមានការផ្តល់ប័ណ្ណប្លង់ដី ប៉ុន្តែក៏មានឥទ្ធិពលពីកត្តាផ្សេងៗទៀតដែរ ។ ការសង្កេតនេះជាប់ទាក់ទងជាពិសេសដល់កម្ពុជា យោងតាមការបារម្ភសព្វថ្ងៃ អំពីកំណើនអត្រាអ្នកជិតគ្មានដី (មានដីតិចជាងកន្លះហិកតា) និងអ្នកគ្មានដីនៅជនបទ (Buddhulph 2004) ។ នៅពេលអ្នកមានដីតូច លក់ដីម្តងមួយប្លង់ៗ (លក់ដោះទ័ល) ឬក៏ពុះច្រៀកដីដើម្បីយកមួយចំនែកលក់ អ្នកទាំងនោះកាត់បន្ថយសមត្ថភាពផលិតកម្មរបស់ខ្លួន ហើយនិងអាចឈានយ៉ាងលឿនទៅកាន់ភាពគ្មានដីធ្លី ។

***យេនឌ័រ:*** លំនាំបែងចែកដីដូចបានពិភាក្សានៅខាងលើ គឺមានពិតជាក់ស្តែងទាំងសំរាប់គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ ។ ប៉ុន្តែគ្រួសារបុរសមេគ្រួមាន ៤,៤ប្លង់ដី/គ្រួសារ ដែលមានទំហំ ០,៣៩ហត/ប្លង់, រីឯគ្រួសារស្ត្រីមេគ្រួ មានជាមធ្យម ៣,៨ប្លង់ដី/គ្រួសារ ដែលមានទំហំ ០,៣០ហត/ប្លង់ ។ ម្យ៉ាងទៀត ៣៤% នៃគ្រួសារស្ត្រីមេគ្រួ មានដីកសិកម្មតិចជាងកន្លះហិកតា ចំណែក ១៨% នៃគ្រួសារបុរសមេគ្រួ មានដីកសិកម្មតិចជាងកន្លះហិកតា ។ ផ្ទុយទៅវិញ ១៧% នៃគ្រួសារស្ត្រីមេគ្រួ មានដីកសិកម្មច្រើនជាង ២ហិកតា ហើយ ៣១% នៃគ្រួសារបុរសមេគ្រួ មានដីកសិកម្មច្រើនជាង ២ហិកតា ។

វិធីរកដីបន្ថែមក៏ខុសគ្នាទៅតាមភេទនៃមេគ្រួសារដែរ ។ ឧទាហរណ៍ គ្រួសារស្ត្រីជាមេគ្រួមានចំនួន ភាគរយ (៧១,១%) នៃប្លង់ដីទទួលបានពីរដ្ឋខ្ពស់ជាងគ្រួសារបុរសជាមេគ្រួ (៥១,១%) ។ ទន្ទឹមនេះដែរ ភាគរយនៃប្លង់ដីដែលគ្រួសារស្ត្រីជាមេគ្រួទទួលបានតាមការបន្តមរតក (១១,២%) គឺទាបជាងគ្រួសារបុរសជាមេគ្រួ (២៤,៦%) ។ តួលេខនេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ យោងតាមរបៀបរបបជាប្រពៃណីនៅជនបទកម្ពុជា ដែលជារឿយៗដីធ្លីត្រូវបានចែកទៅឱ្យកូនប្រុសៗ ។

ភាគរយនៃការរកបានដីបន្ថែមតាមការទិញ និងការកាប់រាននៃគ្រួសារស្ត្រីជាមេគ្រួ ក៏ទាបជាងគ្រួសារបុរសជាមេគ្រួដែរ ។ ភាគរយទាបនៃការ

ទទួលបានដីតាមរយៈការបន្តមរតក ការទិញ និងការកាប់រាន បង្ហាញថា គ្រួសារស្ត្រីជាមេគ្រួ មានលទ្ធភាពតូចជាងគ្រួសារបុរសជាមេគ្រួ ក្នុងការកបានដីបន្ថែម ។ ទិន្នន័យក៏បង្ហាញដែរថា គ្រួសារស្ត្រីជាមេគ្រួតាមចំណាត់ថ្នាក់នីមួយៗមានទ្រព្យសម្បត្តិ និងចំណូលតិចជាងគ្រួសារបុរសជាមេគ្រួ ។ ធនធានសំរាប់ការងារកសិកម្មមានតិចជាង បង្ហាញពីកំហិតចំពោះទំហំដីដែលអាចធ្វើកសិកម្មបាន រីឯចំណូលទាបជាងបង្ហាញពីកំហិតចំពោះការទិញដីបន្ថែម ។

## លទ្ធភាពរកបាន និងប្រើប្រាស់ឥណទាន

ក្រុមធ្វើអង្កេតរាយការណ៍ថាមានសរុប ៧៤៣កំចីក្នុងរយៈ៦ខែមុនពេលអង្កេត ។ ប្រហែល ៦០%នៃកំចីទទួលបានពីវិស័យក្រៅផ្លូវការ គឺមានសាច់ញាតិ និងមិត្តភក្តិ (៤៣,៧%) និងអ្នករកស៊ីចងការប្រាក់ (១៦,០%) ។ កំចី ៣១% ទទួលបានពីវិស័យផ្លូវការ គឺមានធនាគារអេស៊ីលីដា (៦,១%) ឬស្ថាប័នមីក្រូហិរញ្ញវត្ថុណាមួយទៀត (MFI) (២៤,៩%) ។ ប្រហែល ៩% ទៀត ទទួលបានពីវិស័យពាក់កណ្តាលផ្លូវការគឺ NGO ។

វិនិយោគមានផលិតភាពតំណាងឱ្យ ៣៦%នៃកំចីទាំងអស់គឺមានផលិតកម្មកសិកម្ម (១៤,៤%) ពាណិជ្ជកម្មធុនតូច (១២%) និងការចិញ្ចឹមសត្វ (៩,៦%) ។ គ្រួសារបុរសជាមេគ្រួមានខ្ចីច្រើនជាង សំរាប់ការងារកសិកម្ម និងជំនួញ ឯគ្រួសារស្ត្រីមេគ្រួមានខ្ចីច្រើនជាងសំរាប់ការចិញ្ចឹមសត្វ ។ ប៉ុន្តែការថែទាំសុខភាព (២១,៧) និងកង្វះស្បៀង (១៧,៩%) តំណាងឱ្យជិតដល់ ៤០% នៃកំចីទាំងអស់ ។ អត្រានៃគ្រួសារស្ត្រីជាមេគ្រួ និងគ្រួសារបុរសជាមេគ្រួ មានកំរិតប្រហែលគ្នាក្នុងការខ្ចី កំចីសំរាប់ថែទាំសុខភាព ប៉ុន្តែអត្រាគ្រួសារស្ត្រីមេគ្រួ ដែលខ្ចីកំចីសំរាប់ដោះស្រាយកង្វះអាហារមានកំរិតខ្ពស់ជាង ។ កំចីដែលនៅសល់ (២៤,៥%) គឺសំរាប់សកម្មភាពផ្សេងៗទៀត ដូចជាបុណ្យទាន សាងសង់ផ្ទះ និងការដឹកជញ្ជូន ។

អ្នកធ្វើផែនការរំពឹងថា ប័ណ្ណសំគាល់កម្មសិទ្ធនឹងជួយបង្កើនចំនួន និងទឹកប្រាក់កំចីសំរាប់វិនិយោគកសិកម្ម និងសកម្មភាពរកចំណូលផ្សេងទៀតនៅក្រោមការសន្មតថា អត្រាការប្រាក់ និងចំណាយធ្វើប្រតិបត្តិការក្នុងវិស័យផ្លូវការ អាចប្រកួតប្រជែងបានជាមួយវិស័យក្រៅផ្លូវការ ហើយប្រជាជនមានចំនូលចិត្ត និងសមត្ថភាពដើម្បីខ្ចីប្រាក់ ។ និយាយដូច្នេះគឺមានការរំពឹងថា ចំនួនសកម្មភាពឥណទាននឹងកើនឡើងនៅក្នុងតំបន់ដែលប្រជាជនអាចទៅទាក់ទងស្ថាប័នផ្លូវការបានដោយងាយ ។ មានការរំពឹងដែរថា មានការប្រែប្រួលខុសគ្នាខ្លះនៅក្នុងភាពញឹកញាប់ បរិមាណ និងការប្រើប្រាស់កំចី ទៅតាមទំហំ គ្រួសារ និងភេទនៃមេគ្រួសារ ។

## វិនិយោគកសិកម្ម ផលិតភាព និង ការប្រើប្រាស់ដី

ចំណាយមធ្យមក្នុងមួយគ្រួសារសំរាប់ផលិតកម្មស្រូវ មាននិន្នាការកើនឡើងតាមទំហំដីកាន់កាប់ ។ ឧទាហរណ៍ ចំណាត់ថ្នាក់ដីទាបបំផុតពីរក្រុម ចំណាយ ១៣,០៣ម៉ឺនរៀល និង ២១,៥៧ម៉ឺនរៀលរៀងៗគ្នា ចំណែកចំណាត់ថ្នាក់ដីខ្ពស់បំផុតពីរក្រុមវិញ ចំណាយ ៣១,៦ម៉ឺនរៀល និង ៥១,៩៨ម៉ឺនរៀល រៀងៗគ្នា ។ គ្រួសារបុរសមេគ្រួ ចំណាយ ៥០% ច្រើនជាងគ្រួសារស្ត្រីមេគ្រួ ។ មយ៉ាងទៀត គ្រួសារបុរសមេគ្រួនៅគ្រប់ចំណាត់ថ្នាក់នៃការកាន់កាប់ដី តែងចំណាយច្រើនជាងគ្រួសារស្ត្រីមេគ្រួជាដរាប សំរាប់សឹងតែគ្រប់ធាតុចូល ។

| តារាង ៣: ផលិតភាព និងការចំណាយ (ម៉ឺនរៀល) | | | | | |
|---|---|---|---|---|---|
| ដីកាន់កាប់ (ហ.ត) | ទិន្នផល (គ.ក/ហ.ត) | 10,000 ៛/ហ.ត | គ.ក/ 10,000 ៛ | 10,000 ៛/ហ.ត | (គ.ក/ ហ.ត) |
| < 0.5 | 2,051 | 51.3 | 39.98 | 160.1 | 640.3 |
| 0.5 – 0.99 | 1,676 | 32.4 | 51.72 | 228.1 | 1,180.0 |
| 1.0 – 1.99 | 1,464 | 29.4 | 49.80 | 343.1 | 1,708.5 |
| 2.0 – 2.99 | 1,145 | 18.5 | 61.89 | 333.7 | 2,065.2 |
| > 3.0 | 1,016 | 19.5 | 52.10 | 628.1 | 3,272.3 |

ចំណាយលើផលិតកម្មស្រូវ ដែលដោះស្រាយដោយ ហិរញ្ញប្បទាន "ប្រភពផ្ទាល់ខ្លួន" មានជិត ៩០%, បន្ទាប់មកគឺ កំចីពីសាច់ញាតិនិងមិត្តភក្តិ (៨,៣%) និងឥណទានពី "កម្មវិធីផ្សេងៗ" ដូចជា ក្រុមសន្សំប្រាក់ ក្រុម កំចី, MFI, និងធនាគារពាណិជ្ជ (២,៣%) ។ ប្រភពហិរញ្ញប្បទានសំរាប់ធាតុចូលផ្សេងៗប្រែប្រួលខុសគ្នា ទៅតាមទំហំដីកាន់កាប់ ។ ឧទាហរណ៍ សំរាប់ចំណាយលើកំលាំងពលកម្ម ចំណាត់ថ្នាក់ខាងលើគេទាំងពីរក្រុម បានខ្ចីប្រាក់ពីគ្រួសារ មិត្តភក្តិ និងកម្មវិធីឥណទានច្រើនជាងចំក្រុមចំណាត់ថ្នាក់ទាបៗ ។ រឿងនេះបង្ហាញថា ការផ្លាស់ប្តូរចេញពី "ធនធានប្រភពផ្ទាល់ខ្លួន" ទៅរកឥណទានផ្លូវការសំរាប់វិនិយោគកសិកម្ម អាចចាប់ផ្តើមពីការដែលម្ចាស់ដីធំៗ ខ្ចីពីគ្រួសារ និងមិត្តភក្តិ ។ បើដូច្នេះមែនគេរំពឹងថា នឹងមានការយឺតយ៉ាវខ្លះមុនពេលដែលម្ចាស់ដីតូចៗអាចទទួលបានអត្ថប្រយោជន៍ខាងឥណទានអំពីប័ណ្ណប្លង់ដី ពីព្រោះពួកគេអាចមិនទាន់បានត្រៀមខ្លួនដើម្បីប្រើប្រាស់សេវាវិស័យផ្លូវការទេ ។

***ផលិតភាព:*** ទិន្នន័យអង្កេតនៅតារាង៣ បញ្ជាក់ពីទំនាក់ទំនងបញ្ច្រាស (inverse relationship) រវាងទំហំដីកាន់កាប់ និងផលិតភាពនៅកម្ពុជា និងប្រទេសផ្សេងទៀតនៅអាស៊ី (Sophal and Acharya, 2002): ដីកាន់កាប់តូចច្រើនតែមានផលិតភាពជាផលស្រូវក្នុងមួយហិកតា ខ្ពស់ជាងដីកាន់កាប់ធំដោយមិនទាក់ទងនឹងភេទនៃមេគ្រួសារទេ ។ ហេតុផលលើកឡើងជារឿយៗដើម្បីពន្យល់ពីនិន្នាការនេះគឺថា ប្លង់ដីតូចៗ ច្រើនតែកើតចេញពីការពុះច្រៀកដីដែលមានជីជាតិ ។ មូលហេតុផ្សេងទៀតគឺ កសិករតូចៗអាចប្រើបច្ចេកទេស និងធ្វើការគ្រប់គ្រងបានល្អជាង ហើយពលកម្មគ្រួសារ និងធាតុចូលផ្ទាល់ខ្លួនផ្សេងទៀត មានប្រើច្រើនជាងនៅលើដីកាន់កាប់តូចៗ ។

យោងតាមទិន្នន័យអង្កេត កសិករតូចៗ ក៏ប្រើប្រាស់ធាតុចូលទិញគេច្រើនជាងកសិករធំៗដែរ ។ ឧទាហរណ៍ ក្នុងដី ១ហ.ត ចំណាត់ថ្នាក់ទាបបំផុតពីរក្រុម ចំណាយ ៥១,៣ និង ៣២,៤ម៉ឺនរៀលលើគ្រប់ធាតុចូល រីឯចំណាត់ថ្នាក់ខ្ពស់ពីរក្រុមវិញ ចំណាយ ១៨,៥ និង ១៩,៥ម៉ឺនរៀល ។

ថ្វីបើដីកាន់កាប់តូចៗមានផលិតភាពក្នុងមួយហិកតា ខ្ពស់ជាងដីធំៗក្តី ប៉ុន្តែ ដីតូចនៅតែមានផលិតភាពទាបជាងវិញ បើគិតពីរឿងវិនិយោគ ។ អង្កេតបង្ហាញថា ដីកាន់កាប់ទំហំតូចជាង ០,៥ហ.ត ទទួលបាន ៣៩,៩៨គ.ក/ម៉ឺនរៀលនៃចំណាយ ចំណែកដីទំហំ ២-២,៩៩ហ.ត និងធំជាង ៣ហ.ត ទទួលបាន ៦១,៨៩គ.ក និង ៥២,១០គ.កស្រូវរៀងៗគ្នា ។ តួលេខនេះបង្ហាញថា ប្រសិទ្ធភាពវិនិយោគ វាសំខាន់ដូចគ្នា ឬសំខាន់ខ្លាំងជាងកំរិតនៃការវិនិយោគ ។ ចំពោះផលប៉ះពាល់នៃការចេញប័ណ្ណប្លង់ដី កំណើនលទ្ធភាពមានឥណទានប្រើប្រាស់សំរាប់វិនិយោគកសិកម្ម ត្រូវតែមានបំពេញបន្ថែមដោយសេវាផ្សព្វផ្សាយបច្ចេកទេស និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលអាចជួយកែលំអផលិតភាពនៃដើមទុន ។

ផលិតភាពខ្ពស់ចំពោះដីកាន់កាន់តូចៗ មិនមានន័យថា ផលិតកម្ម/គ្រួសារ ក៏បានខ្ពស់ដែរនោះទេ ។ គ្រួសារមានដីតូចជាង ០,៥ហ.ត ផលិត

ស្រូវបានតែ ៦៤០,៣គ.ក ថ្វីបើមានផលិតភាពខ្ពស់ជាងក្តី ។ ដីកាន់កាប់ធំៗ ផលិតបាន ៣.២៧២,៣គ.ក/គ្រួសារ ទោះបីផលិតភាពរបស់វាបានតែពាក់កណ្តាលនៃដីតូចក្តី ។ ជាលទ្ធផល កសិករមានដីកាន់កាប់តូចគឺត្រូវចាញ់ប្រៀបគេមួយកំរិត ពីព្រោះត្រូវបន្តប្រើប្រាស់ធនធានគ្រួសារដែលនៅសល់ (បន្ទាប់ពីដកចំណាយលើកសិដ្ឋាន) ដើម្បីបំពេញកង្វះខាតស្បៀង ដោយ មិនបានធ្វើវិនិយោគទៅលើសកម្មភាពផ្សេងទៀតទេ ។ ម្យ៉ាងទៀត បើសិនកសិករតូចៗខ្ចីបុលមកវិនិយោគលើការដាំដុះដែលមិនអាចផ្តល់ស្រូវអង្ករបានគ្រប់គ្រាន់សំរាប់ការហូបចុកក្នុងគ្រួសារនោះទេ ពួកគេនឹងជំពាក់បំណុលកាន់តែធ្ងន់ពីមួយឆ្នាំទៅមួយឆ្នាំ ។ ចំណុចនេះរំលេចឱ្យឃើញម្តងទៀតពីតំរូវការឥណទានមានតំលៃថោកសមរម្យអាចខ្ចីប្រើការបាន សេវាផ្សព្វផ្សាយបច្ចេកទេសល្អ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីទាញអត្ថប្រយោជន៍ឱ្យបានច្រើនពីការចេញប័ណ្ណប្លង់ដី ។

***ការប្រើប្រាស់ដី*** ភាគរយនៃដីឡូតិ៍ដែលបែងចែកសំរាប់ផលិតកម្មស្រូវវស្សា វាធ្លាក់ចុះនៅពេលទំហំដីកើនឡើង រីឯភាគរយសំរាប់ស្រូវប្រាំងវាកើនឡើងយ៉ាងទៀងទាត់ស្របតាមទំហំដី ។ ភាគរយប្លង់ដីសំរាប់ចំការវាមានកំរិតថេរសំរាប់ស្ទើរគ្រប់ចំណាត់ថ្នាក់ដីកាន់កាប់, រីឯភាគរយដីទំនេរកើនឡើងស្របតាមទំហំដី ។ ភាគរយនៃប្លង់ដីទុកសំរាប់ចំការដំណាំហូបផ្លែ និងដំណាំចំរុះ មានកំរិតទាបសំរាប់គ្រប់ចំណាត់ថ្នាក់ដីកាន់កាប់ ។ ដូច្នេះគឺមានលទ្ធភាពច្រើនណាស់សំរាប់ការធ្វើចំរុះកម្មដំណាំទៅអនាគតនៅក្នុងតំបន់ធ្វើអង្កេតជាច្រើន ។

ដីដាំដុះមានប្រហែល ៩០% នៃប្លង់ដីទាំងអស់ ហើយអត្រានេះថយចុះនៅពេលទំហំដីកើនឡើង ។ ភាគរយដីដាំដុះមានកំរិតប្រហាក់ប្រហែលគ្នាសំរាប់គ្រួសារស្ត្រីមេគ្រួ និងគ្រួសារបុរសមេគ្រួ ក្នុងស្ទើរគ្រប់ចំណាត់ថ្នាក់ដីកាន់កាប់ ។ ភាគរយនៃប្លង់ដីទំនេរ (៧,៦% ជាទូទៅ) កើនឡើងស្របតាមទំហំដី រីឯភាគរយនៃប្លង់ដីជួលឱ្យគេ (១,៦%) មានកំរិតស្មើគ្នាជាទូទៅ ។ គ្រួសារស្ត្រីមេគ្រួមានភាគរយដីទំនេរខ្ពស់ជាងបន្តិច និងមានអត្រាដីជួលឱ្យគេខ្ពស់ជាងគ្រួសារបុរសមេគ្រួ ។ មូលហេតុលើកឡើងជារឿយៗពីការទុកដីឱ្យនៅទំនេរគឺ កង្វះកំលាំងពលកម្ម (៣៤%), គ្មានផលចំណេញ (១៦%), និងដើមទុនមិនគ្រប់គ្រាន់ (៩%) ។

ការស្រាវជ្រាវនៅថៃបង្ហាញថា ប័ណ្ណកម្មសិទ្ធិដីជំរុញឱ្យកសិករខ្លះប្តូរពីដំណាំមានចំនាយទាប/ចំនូលទាបទៅដាំដំណាំពាណិជ្ជកម្មដែលទាមទារវិនិយោគច្រើនជាង ប៉ុន្តែអាចផ្តល់ចំនូលខ្ពស់ទៅអនាគត (Ongchan and Aungsumalin, 2002) ។ លក្ខខ័ណ្ឌទីផ្សារ និងកសិកម្មនៅកម្ពុជាវាខុសគ្នាក៏ពិតមែន ប៉ុន្តែគេរំពឹងថា កសិករក៏ចាប់ផ្តើមធ្វើចំរុះកម្មដែរ ថ្វីបើផលប៉ះពាល់ពេញលេញទាមទារឱ្យមានការសង្កេតតាមដានលើសពីបីឆ្នាំ ។ គេរំពឹងដែរថា វិសាលភាពនិងកំរិតនៃការធ្វើចំរុះកម្មនឹងកើនឡើងកាន់តែលឿននៅលើដីកាន់កាប់ធំៗ ។ អត្រានៃការប្រើប្រាស់ដីក៏អាចកើនឡើងដែរ នៅពេលកសិករធ្វើវិនិយោគកាន់តែច្រើននៅក្នុងផលិតកម្មកសិកម្ម ថ្វីបើរាងយឺតៗបន្តិចដោយសារអវត្តមានវិធានការខាងគោលនយោបាយដើម្បីបង្កើនអត្រាប្រើប្រាស់ដី (ឧ. ពន្ធលើដីទំនេរធំៗ) ។ ផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិទៅលើការប្រើប្រាស់ដី នឹងប្រែប្រួលទៅតាមកត្តាដូចជា លទ្ធភាពមានឥណទាន សេវាផ្សព្វផ្សាយបច្ចេកទេស វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (ឧ. ប្រព័ន្ធស្រោចស្រព) និងថ្លៃទីផ្សារ ។

## តំលៃដី និងការលក់ដី

អង្កេតបង្ហាញថា តំលៃដីបា៉ន់ស្មាន/ហ.តថយចុះនៅពេលទំហំដីកាន់កាប់កើនឡើង សំរាប់ទាំងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។ រឿងនេះអាចដោយសារការប្រមូលផ្តុំដីល្អនៅតាមកសិដ្ឋានតូចៗ ដែលឆ្លុះបញ្ចាំងតាមផលិតភាពខ្ពស់ ។ ប៉ុន្តែតំលៃដីក៏អាចខុសគ្នាទៅតាមតំបន់ដែរ (ឧ. ដីជិត/ជាប់ផ្លូវធំ ឬជិតផ្ទះ) ។

ទោះបី តំលៃដី/ហ.ត មានកំរិតខ្ពស់ក្តី ប៉ុន្តែតំលៃមធ្យមនៃដីមួយប្លង់នៅក្នុងកសិដ្ឋានតូចៗ វាទាបជាងនៅក្នុងកសិដ្ឋានធំៗ ពីព្រោះវាជាប់ទាក់ទងផ្ទាល់ទៅនឹងទំហំប្លង់ដី ។ ឥទ្ធិពលមួយនៃការសង្កេតឃើញនេះ គឺលទ្ធភាពរកបានឥណទាន ។ បើសិនទឹកប្រាក់ឥណទាន វាជាប់ទាក់ទងមួយចំណែកទៅនឹងតំលៃវត្ថុដាក់ធានា អ្នកមានដីធំគឺអាចទទួលបានកំចីច្រើនជាងអ្នកមានដីតូច ដូច្នេះក្នុងការវិនិយោគពួកគេមានប្រៀបជាង អ្នកមានដីតូច ។

***ការលក់ដី:*** តាំងពីឆ្នាំ១៩៨៩មក មានការលក់ដី ២៥២លើកដែលតំណាងឱ្យ ៦,៤% នៃប្លង់ដីទាំងអស់នៅក្នុងគំរូតាង ក្នុងនេះការលក់ដីនៅក្នុងចំណាត់ថ្នាក់ទាបបំផុតពីរក្រុម គឺមានច្រើនខ្លាំងណាស់ ។ ចំណាត់ថ្នាក់ទាបពីរក្រុមនេះ កាន់កាប់ ៣៣,៧% នៃប្លង់ដីទាំងអស់នៅក្នុងគំរូតាង ប៉ុន្តែតំណាងឱ្យ ៥០,៨%នៃប្លង់ដីដែលបានលក់ ។ ចំណាត់ថ្នាក់ខ្ពស់បំផុតពីរក្រុមកាន់កាប់ ៣៨%នៃប្លង់ដីទាំងអស់ ប៉ុន្តែតំណាងឱ្យត្រឹមតែ ២៩% នៃប្លង់ដីដែលបានលក់ ។ ចំណុចគួរភ្ញាក់ផ្អើលគឺ គ្រួសារស្ត្រីជាមេគ្រួ កាន់កាប់ ៤៦% នៃប្លង់ដីនៅក្នុងចំណាត់ថ្នាក់ដីកាន់កាប់ទាបទាំងពីរក្រុម ប៉ុន្តែតំណាងឱ្យតែមួយភាគបីនៃការលក់ដីនៅក្នុងចំណោមពួកគេនេះ ។

ហេតុផលនៃការលក់ដីដែលមានលើកឡើងជារឿយៗ គឺការថែទាំសុខភាព (២៤,៩%) បន្ទាប់មកវិនិយោគលើរបររកស៊ី (១៨,៦%) និងលក្ខណៈដីផ្ទាល់ ដូចជា ដីតូចពេកគ្មានផលចំណេញ ដីខ្វះជីជាតិ ឬដីនៅឆ្ងាយពេក (៩,៧%) ។ ការលក់ដី ៨,៥%ទៀត គឺសំរាប់ដោះស្រាយកង្វះខាតស្បៀង ។ ហេតុផលផ្សេងទៀត មានដូចជា ការសងបំណុល បុណ្យសព សោហ៊ុយចំណាកស្រុក និងគ្រោះអាសន្នដោយអាកាសធាតុ ។

ប័ណ្ណសំគាល់កម្មសិទ្ធិតែមួយមុខ មិនអាចពន្យឺត ឬពន្លឿនអត្រាលក់ដីនៅក្នុងចំណាត់ថ្នាក់ណាមួយឡើយ ។ ឧទាហរណ៍ គេរំពឹងថា ការលក់ដីដោយសារមូលហេតុដូចខាងលើ នឹងបន្តនៅដដែល ឬកើនឡើងនៅក្នុងតំបន់នានាដែលខ្វះខាត សេវាថែទាំសុខភាពមានតំលៃសមរម្យអាចទទួលយកបាន ការផ្សព្វផ្សាយបច្ចេកទេស និងឥណទាន ។ រឿងនេះជាប់ទាក់ទងជាពិសេសដល់អ្នកមានដីតូចដែលជិតក្លាយជាអ្នកគ្មានដី ។ ម្យ៉ាងទៀត បើសិនប្រជាជនប្រើប័ណ្ណសំគាល់កម្មសិទ្ធិដាក់ធានាកំចីដើម្បីយកមកវិនិយោគក្នុងមុខរបរ និងសកម្មភាពផ្សេងទៀត គេអាចរំពឹងថា ការលក់ដីនឹងថយចុះ លើកលែងតែវិនិយោគនោះទទួលបរាជ័យ ហើយប្រជាជនត្រូវលក់ដីដើម្បីសងបំណុល ។ ក្នុងករណីបែបនេះ ប័ណ្ណសំគាល់កម្មសិទ្ធិអាចជួយប្រជាជនឱ្យលក់ដីបានថ្លៃ ថ្វីបើរឿងនេះ វាជួយសំរាលការលំបាកបានមួយកំរិតតូចប៉ុណ្ណោះ ចំពោះអ្នកដែលគ្មានរបរអ្វីសោះក្រៅពីការដាំដុះ ។

***ការផ្ទេរដីធ្លី:*** យ៉ាងហោចណាស់ ៦៥% នៃការលក់ដីបានរាយការណ៍ឡើងនៅក្នុងតំបន់អង្កេត LMAP គឺមានកត់ត្រាផ្ទេរឈ្មោះនៅលើបង្កាន់ដៃទទួលពាក្យសុំប័ណ្ណសំគាល់កម្មសិទ្ធិ ។ ការលក់ដូរដីដែលបានរាយការណ៍ តែមិនបានចុះបញ្ជីជាផ្លូវការមានចំនួនច្រើន ពីព្រោះប្រជាជនមានប្រើវិធីក្រៅផ្លូវការផ្សេងៗដើម្បីបញ្ជាក់ការផ្ទេរដីកាន់កាប់ ។ អ្នកធ្វើផែនការរំពឹងថា

*តទៅទំព័រទី ១៦*

# សមាគមតាមវត្ត និងការផុស ចេញសង្គមស៊ីវិលនៅកម្ពុជា

**Arnaldo Pellini បានពិនិត្យមើលទៅលើបទពិសោធន៍ដែលទទួលបានពីសមាគមតាមវត្ត និងការចូលរួមចំណែករបស់ពួកគេ ចំពោះការកើតឡើងសង្គមស៊ីវិលកម្ពុជា និងការកែលំអអភិបាលកិច្ចនៅមូលដ្ឋាន***

*អត្ថបទនេះ វិភាគពីសមាគមសង្គមស៊ីវិលនានានៅក្នុងទិដ្ឋភាពជាទុនសង្គមកិច្ចតាមប្រពៃណីដោយពិនិត្យទៅលើសក្ដានុពលរបស់វា ដើម្បីរួមចំណែកដល់ការកកើតសង្គមស៊ីវិលកម្ពុជា និងការកែលំអអភិបាលកិច្ចនៅមូលដ្ឋាន ។ អត្ថបទនេះពិនិត្យពីបទពិសោធន៍ក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទរបស់ GTZ (GTZ RDP) ដែលធ្វើការជាមួយសមាគមតាមវត្ត (ឈ្មោះជាផ្លូវការគឺ សមាគមប្រពៃណី) នៅស្រុកស្ទោង ខេត្តកំពង់ធំ ។ អត្ថបទបានរែកញែកថា សមាគមតាមវត្តក្នុងទំរង់ជាសមាគមសន្សំប្រាក់ និងស្រូវ មានសក្ដានុពលអាចរីកដុះដាលតាមរយៈសកម្មភាពឥណទាន ហើយមិនសូវពឹងផ្អែកលើមូលនិធិពីក្រៅទេដើម្បីអនុវត្តសកម្មភាពអភិវឌ្ឍន៍សហគមន៍ ។ ម្យ៉ាងទៀត សក្ដានុពលរបស់វា ដើម្បីតំណាងផលប្រយោជន៍សហគមន៍ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ អាចកើនឡើងថែមទៀតតាមរយៈវិធានការកសាងសមត្ថភាពដែលផ្ដោតទៅលើការរៀនសូត្រតាមការអនុវត្តន៍ ជាជាងតាមទ្រឹស្ដី និងការកំណត់និយមន័យលើអភិបាលកិច្ចមូលដ្ឋាន ។*

## ១. សេចក្ដីផ្ដើម

ការអភិវឌ្ឍន៍គឺជាដំណើរការផ្លាស់ប្ដូរ ។ ទោះបីវាផុសចេញពីក្នុងសង្គមតែម្ដង ឬក៏ត្រូវបានគេណែនាំតាមរយៈជំនួយឧបត្ថម្ភពីខាងក្រៅ, ការផ្លាស់ប្ដូរត្រូវប្រឈមមុខនឹងតំលៃជាប្រពៃណីនៃវប្បធម៌នៅតាមមូលដ្ឋាន ។ យោងតាម Pye (1999) មានសមាសធាតុ ៣ ដែលជាមូលដ្ឋានគ្រឹះសំរាប់របបប្រជាធិបតេយ្យពហុបក្ស: សេចក្ដីគួរសម ទុនសង្គមកិច្ច និងសង្គមស៊ីវិល ។

*សេចក្ដីគួរសម* គឺជារបៀបរបបធ្វើអន្តរកម្មរបស់បុគ្គលដែលធានាឱ្យមានសណ្ដាប់ធ្នាប់ និងបែបបទសង្គម និងដែលធ្វើឱ្យចូលគ្នាចុះនៅក្នុងសង្គម ។ Pye បានអះអាងថា សេចក្ដីគួរសមមិនអាចបង្កើតឡើងតាមរយៈគោលនយោបាយរបស់រដ្ឋទេ ប៉ុន្តែវាពឹងផ្អែកលើសំពាធសង្គម និងការអាម៉ាសដែលកើតពីអារម្មណ៍ថាបានធ្វើខុសឆ្គង ។ ក្នុងបរិបទកម្ពុជា គេអាចរែកញែកថា ទំនាក់ទំនងអន្តរបុគ្គល វាមានឋានានុក្រម ហើយរបៀបរបបគឺផ្អែកទៅលើទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម ឬ អ្នកឧបត្ថម្ភ-អ្នកទទួលផល ។ ដោយមូលហេតុនេះ Ovensen *et al.* (1996:34) បានសរសេរថា នៅកម្ពុជា "គោលការណ៍ដែលជ្រៅតជ្រាបពាសពេញក្នុងជីវភាពសង្គមខ្មែរ គឺសញ្ញាណនៃឋានានុក្រម ។ រាល់ទំនាក់ទំនងសង្គម គឺមានឋានានុក្រម... សណ្ដាប់ធ្នាប់សង្គមហាក់ដូចពឹងផ្អែកលើការដែលគ្រប់ៗគ្នាគោរពតាមឋានានុក្រម ហើយម្នាក់ៗឈរតាមកន្លែងរបស់ខ្លួននៅក្នុងឋានានុក្រមនេះ" ។

*ទុនសង្គមកិច្ច* គឺជាកំរិតទំនុកចិត្តដែលត្រូវមានជាចាំបាច់ក្នុងចំណោមសមាជិកនៃសង្គមណាមួយ ដើម្បីញ៉ាំងឱ្យសកម្មភាពជាសមូហភាពអាចអនុវត្តទៅបាន ។ វឌ្ឍនភាពសង្គម នាំឱ្យមាន "ការប្រមូលផ្ដុំនូវអារម្មណ៍ផ្សារភ្ជាប់គ្នានៃទំនុកចិត្ត និងការជួយគ្នាទៅវិញទៅមក ដែលអាចក្លាយជាមូលដ្ឋានសំរាប់សកម្មភាពជាសមូហភាពដ៏សក្ដិសិទ្ធិ ។ នៅពេលទុនសង្គមកិច្ចមានលក្ខណៈវិជ្ជមាន, អ្នកមានវណ្ណៈខ្ពស់គេធ្វើការដើម្បីផលប្រយោជន៍រួម ។ នៅពេលទុនសង្គមកិច្ចមានលក្ខណៈអវិជ្ជមាន អំពើពុករលួយ និងម៉ាហ្វីយ៉ានឹងឡើងត្រួតត្រា" (Pye 1999:770) ។ តាម Ovensen *et al.* (1996:34) អារម្មណ៍សាមគ្គីគ្នា មិនដែលមានខ្លាំងក្លាទេក្នុងសហគមន៍ខ្មែរ គឺវាតែងនៅពីក្រោមអារម្មណ៍បុគ្គលនិយម និងចំណងទាក់ទងដ៏ជិតស្និទ្ធរបស់បុគ្គលជាមួយក្រុមគ្រួសារ (ដែលសំខាន់ជាងជាមួយសហគមន៍) ។ លំនាំទាំងនេះ ត្រូវបានពង្រឹងថែមទៀតដោយសាររបួសគ្រាំគ្រា បង្កដោយសង្គ្រាមស៊ីវិលអស់ច្រើនទសវត្សរ៍និងរបបខ្មែរក្រហម ។ ក្នុងសហគមន៍កម្ពុជា ទំនុកចិត្តគឺជា "សមាសធាតុនៅខ្វះខាតមួយនៃការរួបរួមគ្នាក្នុងសង្គម និងការចូលរួមដ៏សកម្មនៅក្នុងដំណើរការធ្វើសេចក្ដីសំរេចនៅមូលដ្ឋាន" (UNICEF 1996:33) ។

តាម Pye (1999:764) សង្គមស៊ីវិល "មានសារៈសំខាន់បំផុតសំរាប់កិច្ចដំណើរការដ៏សក្ដិសិទ្ធិនៃរបបប្រជាធិបតេយ្យ" ហើយ "មធ្យោបាយតែមួយគត់ដើម្បីគ្រប់គ្រងក្រុមអ្នកមានផលប្រយោជន៍ គឺការអនុញ្ញាតឱ្យមានសង្គមស៊ីវិលមួយដ៏ខ្លាំង" (*ibid:780*) ។ ហេតុនេះ *សង្គមស៊ីវិល* ត្រូវបានកំណត់និយមន័យថាជាក្រុមអ្នកមានផលប្រយោជន៍ស្វយ័ត និងផ្សេងៗពីគ្នា ដែលអាចដាក់សំពាធទៅលើរដ្ឋ ។ តាមនិយមន័យនេះ គេអាចនិយាយបានថា គំនិតឱ្យមានសង្គមស៊ីវិលនៅកម្ពុជា គឺថ្មីថ្មោងនៅឡើយនិងផុសចេញពីកំណែទំរង់អភិបាលកិច្ចដែលរដ្ឋាភិបាលកំពុងអនុវត្ត ។ នេះជាការវិវត្តន៍យឺតៗនៃដំណើរការខាងសង្គមកិច្ច ស្របគ្នានឹងការអភិវឌ្ឍន៍ ទំនើបនីយកម្ម និងកំណែទំរង់ស្ថាប័នរបស់រដ្ឋាភិបាល ។ តាំងពីបានឯករាជ្យមក សង្គមស៊ីវិលកម្ពុជា មិនទាន់មានកំលាំងខ្លាំងគ្រប់គ្រាន់ដើម្បីដាក់សំពាធទៅលើរដ្ឋទេ ។

នៅកំរិតភូមិ សកម្មភាពជាសមូហភាពភាគច្រើន បានពិនិត្យឃើញនៅតាមវត្តអារាម ។ តាមប្រពៃណី ភូមិនានាតែងផ្សារភ្ជាប់ជាមួយវត្តដែលគេចាត់ទុកជាមជ្ឈមណ្ឌលខាងសង្គមកិច្ច វប្បធម៌ និងសាសនា (Aschmoneit *et al.* 1997) ។ ការប្រមូលផ្ដុំទុនសង្គមកិច្ចបានកើតមានឡើងដោយពាក់ព័ន្ធនឹងវត្ត ដែលធ្វើឱ្យកកើតឡើងនូវសមាគម និងគណៈកម្មការមួយចំនួន ។ ក្រុមទាំងនេះបានទទួលរងផលវិបាកនៃសង្គ្រាម និងការរីករវរខាងនយោបាយ ប៉ុន្តែបច្ចុប្បន្នហាក់ដូចបានផុសចេញមកវិញ នៅពេលមានសន្តិភាពសាជាថ្មី ។ អត្ថបទនេះ ពិនិត្យពីបទពិសោធន៍នៃ GTZ RDP ដែលធ្វើការជាមួយសមាគមតាមវត្តក្នុងស្រុកស្ទោង ខេត្តកំពង់ធំ និងវិភាគពីតួនាទីរបស់វា ។

## ២. ចរិតលក្ខណៈសមាគមតាមវត្តក្នុងស្រុកស្ទោង

អង្គការ GTZ ចាប់ធ្វើការនៅក្នុងស្រុកស្ទោង តាំងពីឆ្នាំ១៩៩៥ នៅពេលមានការសំរេចចិត្តផ្ដោតការងារលើសមាគម ៤ប្រភេទ ដែលគេយល់ថាជាប់ទាក់ទងច្រើននឹងបញ្ហាអភិវឌ្ឍន៍សហគមន៍ និងការកាត់បន្ថយភាពក្រីក្រ គឺមានសមាគមសន្សំប្រាក់ សមាគមស្រូវ ធនាគារអង្ករ និងសមាគមបុណ្យសព ។

សមាគមតាមវត្ត ជាទិដ្ឋភាពជាប្រពៃណីមួយនៃការរស់នៅរបស់ប្រជាជនមូលដ្ឋានទូទាំងប្រទេសកម្ពុជា ។ ការសិក្សាមួយក្នុងស្រុកស្ទោង ធ្វើ ដោយ Narak (1998) ឬ

---

* **Arnaldo Pellini** គឺជាទីប្រឹក្សានៃកម្មវិធីអភិវឌ្ឍន៍ជនបទរបស់អង្គការ

| តារាង១. សមាគមក្នុងស្រុកស្ទោងឆ្នាំ២០០៣ | |
|---|---|
| សមាគមសន្សំប្រាក់ក្នុងវត្ត | 29 |
| សមាគមសន្សំប្រាក់ក្នុងភូមិ | 25 |
| សរុប | **54** |
| សមាគមអង្ករក្នុងវត្ត | 14 |
| សមាគមអង្ករក្នុងភូមិ | 24 |
| សរុប | **38** |
| សមាគមសាលារៀន | 2 |

ានរកឃើញសមាគម ២៩ប្រភេទ ដែលជាប់ទាក់ទង នឹងវត្ត ។ តាម Aschmoneit *et al.* (1998:7), អង្គការកិរិតមហាជនទាំងនេះ ពួកអ្នកភូមិបានបង្កើតឡើងដើម្បីអនុវត្តសកម្មភាពជួយគ្នាទៅវិញទៅមក ដែលជាការអនុវត្តន៍ជាក់ស្ដែងនូវការទូន្មានរបស់ព្រះពុទ្ធ "ខ្លួនទីពឹងខ្លួន" ។

Narak បានរកឃើញថា ក្រុមទាំងនេះមានដំណើរការសកម្មនៅកិរិតសហគមន៍នៅមុនឆ្នាំ១៩៧០ ដែលជាឆ្នាំចាប់ផ្ដើមមានសង្គ្រាមស៊ីវិល ។ សមាគមភាគច្រើន បានឈប់ដំនើរការនៅក្រោមរបបខ្មែរក្រហម ហើយបានចាប់ដំណើរការឡើងវិញ ប៉ុន្ដែ នៅក្រោមការគ្រប់គ្រងរបស់រដ្ឋនៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតុកម្ពុជាពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ។ បច្ចុប្បន្នពួកគេមិនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋទៀតទេ និងតំណាងឱ្យសកម្មភាពជួយខ្លួនដោយខ្លួនឯងជាប្រពៃណីដែលសហគមន៍ខ្មែរតែងរៀបចំឱ្យជាប់ទាក់ទងនឹងវត្ត ។ សមាគមមានសមាជិកពី ៥០-២០០នាក់ ដោយជាមធ្យមមាន សមាជិក ១២០នាក់ ។ សមាគមនីមួយៗមានគណៈកម្មការគ្រប់គ្រងមួយ ដែលមានសមាជិកជាប់ឆ្នោតពី ៥-៧នាក់ ។ ការងារចំបងរបស់សមាគម គឺផ្ដល់កំចីខ្នាតតូចជាប្រាក់ និងអង្ករ ទៅឱ្យសមាជិក ហើយឥណទានមានទំហំជាមធ្យម ១០-១៥ដុល្លារ ឬអង្ករ ៥០គ.ក ។ ការប្រាក់ត្រូវសងនៅដំណាច់វដ្ដឥណទាន (៦ខែសំរាប់កំចីជាប្រាក់ និង ១២ខែសំរាប់កំចីជាអង្ករ) និង មានកិរិត ៥% ក្នុងមួយខែសំរាប់កំចីជាប្រាក់ និង ៣០% ក្នុងមួយខែសំរាប់កំចីជាអង្ករ ។ អ្នកខ្ចី ៦០% គឺជាអ្នកភូមិក្រីក្រ ហើយកំចីភាគច្រើនត្រូវបាន ប្រើប្រាស់សំរាប់សកម្មភាពបង្កើតចំណូលតូចៗ ។ នៅពេលអ្នកណាម្នាក់មិនអាចសងបំណុលទាំងអស់បាន ចំនួនមិនទាន់សងត្រូវផ្ទេរទៅក្នុងវដ្ដបន្ទាប់ដោយចាត់ទុកជាឥណទានមួយថ្មី ។ គណៈកម្មការសមាគមអាចលុបចោល បំណុលរបស់ជនណាម្នាក់ដែលគ្មានលទ្ធភាពសងវិញ ដោយយោងតាម កាលៈទេសៈពិសេសខ្លាំង ដូចជា គ្រោះថ្នាក់ ជម្ងឺ ឬគ្រោះធម្មជាតិ ។

នៅឆ្នាំ១៩៩៧ គណៈកម្មការសំរបសំរួលវត្ត (Pacoco) ត្រូវបានបង្កើតឡើងដើម្បីធ្វើការសំរបសំរួលរវាងសមាគមនានា ហើយធ្វើជាអន្ដរការីរវាងសមាគម និងអ្នកផ្ដល់ជំនួយ ។ ជាគោលការណ៍ សមាជិកគណៈកម្មការត្រូវជ្រើសតាំងតាមការបោះឆ្នោត ប៉ុន្ដែវិធីនេះហាក់ដូចមិនបានអនុវត្តរាល់ៗលើកទេ (ក្នុងការបោះឆ្នោតលើកទី១នៅឆ្នាំ១៩៩៧ បេក្ខនារី ២នាក់ បានទទួលសន្លឹកឆ្នោតច្រើនជាងគេ ប៉ុន្ដែបេក្ខជនម្នាក់ត្រូវបានជ្រើសតាំងជាប្រធានវិញ ពីព្រោះជាលក្ខណៈវប្បធម៌ដំណោះស្រាយបែបនេះ ងាយទទួលយកជាង) ។ ការងារចំបងរបស់ Pacoco គឺ *"ផ្ដល់ឱកាសដល់អ្នកក្រ ដើម្បីឱ្យគេមានសមត្ថភាពកាន់តែច្រើនសំរាប់ប្រយុទ្ធនឹងភាពក្រីក្រ, និងលើកទឹកចិត្តឱ្យបណ្ដាសមាគមជាសមាជិក ធ្វើការកែលំអ និងស្ដារជួសជុលហេដ្ឋារចនាសម្ព័ន្ធដ៏សមស្របនានា សំរាប់បំរើផលប្រយោជន៍ទាំងខាងសង្គមស៊ីវិល និងសាសនានៅក្នុងតំបន់របស់ពួកគេផ្ទាល់"* (Pacoco 1999) ។

សមាជិក Pacoco ជួបប្រជុំប្រចាំខែ និងផ្ដល់យោបល់ក្រៅផ្លូវការជាប្រចាំទៅឱ្យសមាគម និងគណៈកម្មការនានា ។ ពួកគេទទួលខុសត្រូវលើសមាគម/គណៈកម្មការមួយចំនួននៅក្នុងទូទាំងតំបន់អភិវឌ្ឍន៍ណាមួយ ដោយយោងទៅតាមរបាយសមាគមមិនមែនតាមព្រំប្រទល់ឃុំទេ ។ ថ្វីបើពីដំបូងសមាគមសន្សំប្រាក់ និងអង្ករ ស្ថិតនៅក្នុងវត្ត ប៉ុន្ដែសព្វថ្ងៃមានសមាគមជាច្រើនស្ថិតនៅតាមភូមិ និងសាលារៀន ។ ចំនួនសមាគមកើនឡើងគួរកត់សំគាល់ពីឆ្នាំ១៩៩៧ ដល់ ២០០៣ ដូចជាកំណើនសមាគមសន្សំប្រាក់ពី ៤២ ទៅ ៥៤ និងកំណើនសមាគមអង្ករពី ៣៤ ទៅ ៣៨ សមាគម ។

កំណើនចំនួនសមាគម ឆ្លុះបញ្ចាំងនូវការគាំទ្រពីខាងក្រៅ ។ នៅឆ្នាំ ១៩៩៧ គំរោងបានចូលរួមវិភាគទានដល់ទុនចាប់ផ្ដើមរបស់ ២២សមាគម នៅក្នុង ១០វត្ត ដោយប្រើប្រាក់អស់ប្រហែល ៩.២០០ដុល្លារ និងអង្ករ ៨១.៣០០គ.ក ។ បន្ទាប់ពីរយៈពេលដំបូងនេះ ការគាំទ្ររបស់ GTZ ដល់សមាគមតាមវត្តនានា បានថយចុះ ដោយសារនៅឆ្នាំ១៩៩៨ មានការពង្រីក សកម្មភាពគំរោងអភិវឌ្ឍន៍ជនបទ ដោយបញ្ចូលថែមនូវកសិកម្ម ការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការអភិវឌ្ឍន៍សហគមន៍ ។ បុគ្គលិក ដែលពីមុនទទួលបន្ទុកលើបណ្ដាសមាគមតាមវត្ត គឺត្រូវបានប្រគល់ភារកិច្ចខាងអភិវឌ្ឍន៍សហគមន៍ ដូចជា ការបង្កើតគណៈកម្មការថែទាំផ្លូវ និងក្រុមអ្នកប្រើប្រាស់ទឹក ។ គេបានទុកបុគ្គលិកម្នាក់ឱ្យពិនិត្យតាមដានសមាគមតាមវត្តនានានៅស្ទោង ។ រហូតដល់ឆ្នាំ២០០២ គំរោងគាំទ្រគឺមានជាសំខាន់ការបណ្ដុះបណ្ដាលគណនេយ្យសាមញ្ញ និងរបៀបប្រើប្រាស់ទំរង់ផ្សេងៗ សំរាប់តាមដាន ការបើកផ្ដល់/ការបង្វិលសងកំចី ។

ការបោះឆ្នោតឃុំនៅឆ្នាំ២០០២ បានផ្ដល់សេណារីយ៉ូមួយថ្មីសំរាប់សមាគមតាមវត្ត ។ គំរោង GTZ បានដាក់សមាគមតាមវត្ត ឱ្យនៅក្រោមសមាសភាគបង្កើតថ្មីមួយរបស់សង្គមស៊ីវិល ដែលមានបុគ្គលិកជាទីប្រឹក្សាអន្ដរជាតិម្នាក់របស់ DED (Deutscher Entwicklungs Dienst: សេវាអភិវឌ្ឍន៍ អាឡឺម៉ង់) និងនិយោជិតក្នុងស្រុកម្នាក់, ជាបន្ថែមទៅលើបុគ្គលិកអភិវឌ្ឍន៍សហគមន៍របស់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកស្ទោង ។ តាំងពីពេលនោះមក ការគាំទ្ររបស់គំរោងបានផ្ដោតកាន់តែច្រើនទៅលើការកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ និងតួនាទីដែលសមាគមនានាអាចបំពេញបាននៅក្នុងអភិបាលកិច្ចនៅមូលដ្ឋាន ។ ការគាំទ្រហិរញ្ញវត្ថុនៅឆ្នាំ ២០០៣ មានកំរិតត្រឹម ១.៣១៥ដុល្លារ និងគ្របដណ្ដប់ជាសំខាន់លើចំណាយធ្វើដំណើរសំរាប់ការប្រជុំនៅតាមវត្ត និងទស្សនកិច្ចសិក្សាមួយទៅខេត្តកណ្ដាល ដើម្បីឱ្យសមាជិក Pococo បានជួប និងពិនិត្យសង្កេតសមាគមតាមវត្ត និងសមាគមតាមភូមិ ដែលគាំទ្រដោយ NGO អន្ដរជាតិមួយ ។ ក្រោយធ្វើទស្សនកិច្ចសិក្សា សមាជិក Pococo បានផុសគំនិតថ្មីៗ: សមាគមជួលម៉ាស៊ីនបោកស្រូវនៅរដូវប្រមូលផលដោយយកតំលៃថោក (ផ្ដល់ទុនដោយស្ថានទូតជប៉ុន), និងសមាគមប្រហាក់ប្រហែលសហករណ៍សំរាប់ទិញដុំនូវស្រូវពូជ និងជី ដើម្បីលក់ទៅឱ្យបណ្ដាសមាគមជាសមាជិកក្នុងតំលៃថោក និងសមាគមអ្នកចិញ្ចឹមជ្រូក ។ សំណើគំរោងនានាត្រូវបានរៀបចំ និងបង្ហាញ

ជូនដល់តំណាងអ្នកផ្ដល់ជំនួយនានាដែលមកធ្វើទស្សនកិច្ចនៅស្មោង ។

ថ្វីបើជំនួយទ្រទ្រង់ខាងហិរញ្ញវត្ថុបានថយចុះ (ធៀបនឹងឆ្នាំ១៩៩៧) ប៉ុន្ដែ មានសមាគមថ្មីៗជាច្រើនបានកកើតឡើង ហើយទុនសរុប និងទុនជាមធ្យមរបស់សមាគមនានាក៏កើនឡើងដែរ (តារាង២) ។ យោងតាមលោកស្រី Sasse (1998:104) រឿងនេះបង្ហាញថា "តំលៃនៃគំរោង ស្ថិតនៅលើផលសំរេចរបស់វាក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈ ការពង្រឹងអង្គការកីរិតមហាជនជាប្រពៃណីទាំងនេះ" ។ គាត់បន្ថែមថា "ក្រុមជួយខ្លួនដោយខ្លួនឯងដែលមានស្រាប់ គឺមានចីរភាពល្អណាស់ ពីព្រោះមានគោលដៅការគ្រប់គ្រង និងប្រភពមូលនិធិផ្ទាល់នៅក្នុងសហគមន៍... ថ្នាក់គ្រប់គ្រងរបស់ក្រុមទាំងនេះ ច្រើនតែគួរទុកចិត្តបាន នឹងប្រាកដប្រជា ជាងក្រុមបង្កើតថ្មី ដោយសារសមាជិកគណៈកម្មការធ្វើការជាសំខាន់ដើម្បីសន្សំកុសល មិនមែនស្វែងរកប្រាក់ចំណេញទេ *(ibid)*" ។ម្យ៉ាងទៀត សមាគមនានាតំណាងឱ្យមួយភាគធំនៃប្រជាជន(តារាង៣) ដូច្នេះមានលទ្ធភាពច្រើនក្នុងការដាក់សំពាធលើអាជ្ញាធរមូលដ្ឋាន បើសិនត្រូវបានផ្ដល់ឱកាសឱ្យធ្វើការងារនេះ ។

នៅពេលសមាគមទទួលបានទុនពីដំបូង និងទទួលបានកីរិតសមត្ថភាពសំរាប់គ្រប់គ្រងឥណទាន និងវិភាគទានរបស់សហគមន៍, ទុនរបស់សមាគមអាចរីកចំរើនទៅតាមចំនួនគ្រួសារដែលសមាគមអាចពង្រីកការងារទៅ ដល់ ។ នៅពេលនោះ ការគាំទ្រហិរញ្ញវត្ថុពីក្រៅ អាចកាត់បន្ថយបាន ហើយដាក់ប្រមូលផ្ដុំទៅលើការកសាងសមត្ថភាពប្រភេទផ្សេងៗទៀត ។

## ៣. តួនាទីរបស់សមាគមតាមវត្តនៅក្នុងសង្គមស៊ីវិល

នៅកម្ពុជា សមាគមតាមវត្តបានរួចរស់ពីការរីករវរខាងសង្គមកិច្ច និងនយោបាយផ្សេងៗ ។ រឿងនេះបង្ហាញថា ទុនសង្គមកិច្ចគឺមានជាក់ស្ដែង និងមានសក្ដានុពលដើម្បីពង្រឹងសកម្មភាពជាសមូហភាពនានា ដោយចាប់ផ្ដើមចេញអំពីបណ្ដាស្ថាប័នជាប្រពៃណី ។ ហេតុនេះ វាមានសារៈសំខាន់ដែលត្រូវធ្វើវិភាគពីសមាគមតាមវត្តអំពីសេចក្ដីគួរសម ទុនសង្គមកិច្ច និងសង្គមស៊ី វិល ដើម្បីស្វែងយល់ពីតួនាទីដែលសមាគមអាចបំពេញបាន ។

### ៣.១ សេចក្ដីគួរសម: ការដឹកនាំ និងទំនាក់ទំនងជាបុគ្គលនៅក្នុងសមាគម

ឋានានុក្រមដែលជាចរិតលក្ខណៈនៃសេចក្ដីគួរសមរបស់សង្គមខ្មែរ បានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធអង្គការចាត់តាំងរបស់សមាគម ។ ការដឹកនាំគឺហាក់ដូចជាសមាសធាតុមួយដែលធ្វើឱ្យសមាគមក្លាយជាសកម្ម ឬមិនសកម្ម ។ អាចារ្យដែលមានបុគ្គលិកលក្ខណៈរឹងមាំល្អ គឺជាអ្នកដែលដឹងច្បាស់ពីវិធីកៀងគរសហគមន៍ ។ បញ្ហាចោទគឺអាចារ្យមិនមែនសុទ្ធតែមាន សមត្ថភាពដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន

| តារាង២. ទុនរបស់សមាគម | | |
|---|---|---|
| | អង្ករ (គ.ក) | អង្ករជាមធ្យម (គ.ក) |
| **1997** | 98,140 | 7,346 |
| **2001** | 308,516 | na |
| **2002** | 231,980 | 6,105 |
| **2003** | 343,148 | 9,030 |
| | ប្រាក់សន្សំ (រៀល) | ប្រាក់សន្សំជាមធ្យម (រៀល) |
| **1997** | 43,700,000 | 4,537,353 |
| **2001** | 204,180,900 | na |
| **2002** | 432,129,127 | 8,002,391 |
| **2003** | 377,281,030 | 6,796,715 |
| ១ ដុល្លារ = ៣.៩00រៀល | | |

| តារាង ៣. អ្នកបានទទួលផលអំពី សមាគមសន្សំប្រាក់ និងអង្ករនៅឆ្នាំ២00៣ | | | | | |
|---|---|---|---|---|---|
| អង្ករ | ទុន (គ.ក) | គ្រួសារ | ប្រជាជន | ស្រី | គ្រួសារក្រីក្រ |
| 38 | 343,148 | 2,154 | 10,797 | 5,875 | 1,241 |
| ទុនជាមធ្យម | 9,030 | | | | |
| សាច់ប្រាក់ | ទុន (រ) | គ្រួសារ | ប្រជាជន | ស្រី | គ្រួសារក្រីក្រ |
| 54 | 367,022,631 | 4,766 | 6,159 | 7,833 | 2,080 |
| ទុនជាមធ្យម | 6,796,715 | | | | |
| ប្រភពទិន្នន័យ: Pacoco 2003 | | | | | 1 ដុល្លារ = 3.900 រៀល |

ប្អូនក៏មានជំនាញដើម្បីចូលរួមយ៉ាងសកម្មក្នុងការប្រជុំធ្វើផែនការនានានោះទេ ។ អាចារ្យដែលរឹងមាំ ច្រើនតែបានទទួលការបណ្ដុះបណ្ដាលពី NGOs និងអ្នកផ្ដល់ជំនួយ ដែលធ្វើឱ្យគាត់មានជំហរកាន់តែរឹងមាំថែមទៀតនៅក្នុងសមាគម ។ បញ្ហាមួយទៀតដែលបានសង្កេតឃើញនៅកំពង់ធំ គឺពួកអ្នកដឹកនាំសហគមន៍ហាក់ដូចច្រើនតែទទួលបានការតែងតាំងនៅក្នុងគណៈកម្មការច្រើនបែបយ៉ាង ដែលគំរោង និង/ឬ អង្គការអន្ដរជាតិនានា បានបង្កើតឡើង និងដែលធ្វើឱ្យពួកគាត់មានបន្ទុកច្រើនពេក[៤] ។

### ៣.២ ទុនសង្គមកិច្ច: ចំរុះកម្មសមាគម និងសកម្មភាពជាសមូហភាព

ចីរភាពក៏មានន័យដែរថាជា ការកាត់បន្ថយហានិភ័យ ។ ចំពោះសមាគម ការធ្វើចំរុះកម្មសកម្មភាពឥណទានជាប្រពៃណី ទៅក្នុងវិស័យថ្មីៗទៀត នឹងធ្វើឱ្យហានិភ័យបែកខ្ញែកជាច្រើនមុខ, ដូច្នេះវានឹងកាត់បន្ថយការពឹងផ្អែកទៅលើជំនួយគាំទ្រពីខាងក្រៅ ។ បទពិសោធន៍ពី Pacoco បង្ហាញថា វិធីដ៏ល្អបំផុតមួយដើម្បីពង្រីងចំណេះដឹង និងអភិវឌ្ឍគំនិតថ្មីៗ គឺការផ្ដល់ឱកាសឱ្យប្រជាជនបានជួបអ្នកផ្សេងទៀតដែលមានជាប់ពាក់ព័ន្ធនឹងសកម្មភាពស្រដៀងគ្នាដែរ ។ ទស្សនកិច្ចសិក្សាទៅខេត្តឯទៀតៗ បានបង្ហាញថា វាជាមធ្យោបាយប្រសើរបំផុតសំរាប់ឱ្យសមាជិក Pacoco ផុសគំនិតអំពីសមាគមប្រភេទថ្មីៗ ។ វិធីសាស្ត្រនេះ អាចនាំឱ្យមានសកម្មភាពជាសមូសភាពកាន់តែច្រើន និងជួយពង្រឹងទុនសង្គមកិច្ចនៅមូលដ្ឋាន ។

### ៣.៣ សង្គមស៊ីវិល: តួនាទីសមាគមតាមវត្ត

រចនាសម្ព័ន្ធសមាគមតាមវត្ត ឆ្លុះបញ្ចាំងពីរបៀបរបបឋានានុក្រមដែលគ្រប់គ្រងសង្គមខ្មែរ, ហើយទំនុកចិត្តដែលផ្សារភ្ជាប់សមាជិកសមាគមវាតំណាងឱ្យទុនសង្គមកិច្ចនៃស្ថាប័នជាប្រពៃណីនានា ។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២00២ និងកំណែទំរង់វិមជ្ឈការដែលរដ្ឋាភិបាលកំពុងអនុវត្តសព្វថ្ងៃ បានផ្ដល់ឱកាសឱ្យសមាគមជាប្រពៃណីនានាដើម្បីដាក់សម្ពាធខ្លះ ទៅលើអាជ្ញាធរមូលដ្ឋាន និងដើរតួជាអ្នកតំណាងសង្គមស៊ីវិល ។ សមាគមតាមវត្តបានទទួលទំនុកចិត្តពីសមាជិករបស់ខ្លួន ដូច្នេះអាចចាត់ទុកជាអ្នកនាំពាក្យពេញលក្ខណៈច្បាប់ សំរាប់ពាំនាំតំរូវការរបស់សហគមន៍ទៅប្រាប់ក្រុមប្រឹក្សាឃុំ, ហើយសមាគមអាចចូលពាក់ព័ន្ធក្នុងការធ្វើផែនការនៅមូលដ្ឋាន, ឬរួមចំណែកជាទុនផ្ទាល់របស់ខ្លួន ដើម្បីផ្ដល់ថវិកាសំរាប់គំរោងខ្នាតតូចៗ ។ ដើម្បីធ្វើដូច្នេះបាន សមាគមត្រូវស្គាល់ច្បាស់ថែមទៀតពីបរិស្ថានវិមជ្ឈការ និងឱកាសល្អថ្មីៗដែលជាប់ទាក់ទងនឹងតួនាទីថ្មីរបស់ខ្លួន ។

*តទៅទំព័រទី ១៩*

# ការកសាងផែនការគ្រាន់តែជាជំហានមួយប៉ុណ្ណោះ

**Melissa Marschke បានគូសរំលេចពីបទពិសោធន៍នៅកម្ពុជាស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ដោយផ្អែកលើសហគមន៍***

*"យើងលើកគំរោង ហើយបន្ទាប់មកធ្វើផែនការជាច្រើន" ។ ប៉ុន្តែនៅពេលយើងអង្គុយធ្វើផែនការ ព្រៃរបស់យើងត្រូវគេកាប់ ហើយដីរបស់យើងត្រូវគេរំលោភយក ។ មានការនេសាទត្រីដោយប្រើគ្រឿងផ្ទុះនៅបឹងទន្លេសាប ហើយត្រីកាន់តែមានតិចទៅៗ ។ យើងចង់រកវិធីមួយដើម្បីដោះស្រាយបញ្ហាទាំងនេះ មិនមែនគ្រាន់តែនិយាយពីវាប៉ុណ្ណោះទេ", សំដីអ្នកភូមិម្នាក់នៅខេត្តពោធិសាត់ ថ្ងៃទី ៩ មីនា ២០០៤ ។*

សំរាប់អ្នកភូមិនៅជនបទកម្ពុជាដែលយកចិត្តទុកដាក់ដល់បញ្ហាទន្ទ្រានយកដី ការដោះស្រាយទំនាស់ក្នុងដែននេសាទ ឬក៏កិច្ចការពារតំបន់ព្រៃឈើ រឿងទាំងនេះមិនមែនងាយស្រួលទេ ។ ពួកអ្នកភូមិអាចធ្វើការតាមរយៈយន្តការដោះស្រាយទំនាស់មានស្រាប់នានា ដូចជាក្បៀងគរការគាំទ្ររបស់មេភូមិ ឬមេឃុំ និង/ឬធ្វើការងារជាមួយអ្នកដឹកនាំវត្ត ឬវិហារអ៊ីស្លាម ។ ប៉ុន្តែ វាមានលទ្ធភាពច្រើនថា (ជាពិសេសបើអ្នកភូមិ ត្រូវធ្វើការជាមួយស្ថាប័នរដ្ឋ ឬ NGO) នឹងមានការបង្កើតគណៈកម្មការគ្រប់គ្រងធនធានប្រភេទណាមួយដើម្បីចាត់ចែងលើបញ្ហាបែបនេះ ។ ឈ្មោះគណៈកម្មការជាប់ទាក់ទិនជាសំខាន់ទៅនឹងស្ថាប័នរដ្ឋ ឬ NGO ណាមួយ ដែលធ្វើការជាមួយពួក អ្នកភូមិ ។ ឧទាហរណ៍ នៅក្នុងភូមិតែមួយ អាចមានគណៈកម្មការជលផល សហគមន៍ គណៈកម្មការព្រៃឈើសហគមន៍ គណៈកម្មការគ្រប់គ្រងការប្រើប្រាស់ដី ឬអនុគណៈកម្មការរបស់ក្រុមប្រឹក្សាឃុំ ដោយគណៈកម្មការទាំងអស់នេះធ្វើការលើទិដ្ឋភាពខុសៗគ្នានៃការគ្រប់គ្រងធនធានធម្មជាតិ ។ ក្នុងគណៈកម្មការទាំងនេះ អាចមាន ឬគ្មានសមាសភាពមេភូមិដែលជាអ្នកមានគំនិតយោបល់អំពីការគ្រប់គ្រងធនធានធម្មជាតិ ។ រឿងនេះជួយបំភ្លឺពីមូលហេតុដែលសមាជិកក្នុងសហគមន៍ (ដូចរៀបរាប់ខាងលើ) បានលើកពីការខកចិត្តចំពោះ ចំនួនវគ្គធ្វើផែនការដែលខ្លួនបានចូលរួម ។

និយាយដូច្នេះមិនមែនមានន័យថា ពួកអ្នកភូមិមិនយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លីនោះទេ ។ ពួកគេយកចិត្តទុកដាក់ណាស់ ជាពិសេសបើសិនមានជំនឿថា ពួកគេអាចដោះស្រាយបញ្ហាជាប់ទាក់ទងនឹងជីវភាពរស់នៅរបស់ខ្លួន ។ អ្នកភូមិនៅជនបទមានចំណងផ្សារភ្ជាប់ទៅនឹងទឹកដី និងធនធានធម្មជាតិ ហើយការប្រើប្រាស់ធនធាននៅក្នុងមូលដ្ឋានវាពឹងផ្អែកជាសំខាន់ទៅលើវត្តមានធនធានទាំងនេះ ។ អ្នកភូមិជាច្រើន មិនបានបែងចែកធនធានតាមផ្នែកដាច់ៗពីគ្នា តាមបែបបទដូចស្ថាប័នរដ្ឋនានាទេ ។ ឧទាហរណ៍ នាយកដ្ឋានជលផល ចាត់ចែងតែរឿងជលផល, រដ្ឋបាលព្រៃឈើចាត់ចែងតែរឿងព្រៃឈើប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ពួកអ្នកភូមិមើលឃើញពីចំណងទាក់ទងរវាងដី និងទឹក, ដើមឈើ និងត្រី (Marschke 2003) ។ សំខាន់ជាងនេះទៀត អ្នកភូមិជាច្រើនទទួលស្គាល់ថា ត្រូវមានយុទ្ធសាស្ត្រច្រើនដើម្បីដោះស្រាយបញ្ហា ការរំលោភយកដី លទ្ធភាពប្រើប្រាស់ និងការថយចុះធនធានធម្មជាតិ ។ ដូច្នេះ ត្រូវមានការគិតគូរថ្លឹងថ្លែងមួយចំនួនដើម្បីវាយតំលៃថា តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យគោលនយោបាយផ្សេងៗដែលផ្អែកលើសហគមន៍ ដូចឃើញមាននៅក្នុងច្បាប់ និងកម្មវិធីជាច្រើន អាចជួយដោះស្រាយតំរូវការរបស់សហគមន៍បានប្រសើរបំផុត ។

អត្ថបទនេះចាប់ផ្តើមឡើងដោយគូសរំលេចនូវបទពិសោធន៍ពីដំបូងៗនៃការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ (CBNRM) នៅកម្ពុជា, ហើយបន្ទាប់មក ធ្វើសំយោគនូវ ៣ វិធីសាស្ត្រទាក់ទិននឹង CBNRM ដែលបណ្តាស្ថាប័នរដ្ឋ និង NGOs កំពុងអនុវត្តសព្វថ្ងៃ: ក) ការគ្រប់គ្រងជលផលដោយសហគមន៍, ខ) ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម (PLUP), គ) ការសង្កត់ធ្ងន់លើការលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NREM) នៅក្នុងផែនការនានារបស់ក្រុមប្រឹក្សាឃុំ ។ វិធីសាស្ត្រទាំង ៣ នេះ នឹងយកមកប្រៀបធៀប និងវិភាគដោយត្រួសៗ, បន្ទាប់មកគឺការលើកពីបទពិសោធន៍នៅផ្ទាល់កន្លែងទាក់ទិននឹងរបៀបរបបអនុវត្ត CBNRM ។ ខ្ញុំបានជជែកវែកញែកថា ត្រូវមានអ្វីលើសពីការបង្កើតបរិបទខាងគោលនយោបាយទៅទៀត ដើម្បីធានាថា ពួកអ្នកភូមិអាចអនុវត្តការងារគ្រប់គ្រងផ្អែកលើសហគមន៍បាន ។ ការធ្វើផែនការអាចគ្មានន័យអ្វីសោះ បើសិនប្រជាជនគ្មានជំនឿថា ផែនការរបស់ពួកគេមានអ្នកធំគាំទ្រ, ទោះបីផែនការនោះមានគុណភាពល្អប៉ុណ្ណា ឬក៏ច្បាប់បានចែងយ៉ាងណាក្តី ។

## ការរីកដុះដាលនៃដំណើរការ CBNRM

ថ្វីបើការគាំទ្របណ្តាកម្មវិធីគ្រប់គ្រងផ្អែកលើសហគមន៍ គឺអាចជារឿងសមហេតុផល (តាមទ្រឹស្តី ដំណើរការបែបនេះផ្តល់លទ្ធភាពដល់អ្នកភូមិឱ្យធ្វើសកម្មភាព) ប៉ុន្តែវាស្មុគស្មាញជាងក្នុងការស្វែងយល់ថា តើត្រូវធ្វើអ្វីដើម្បីលើកកំពស់កិរិតជីវភាព ដោះស្រាយទំនាស់ ឬបង្កើនលទ្ធភាពប្រើប្រាស់ធនធានរបស់ប្រជាជននៅជនបទកម្ពុជា ។ គ្រួសារនានា និងបណ្តាស្ថាប័ននៅកិរិតភូមិ បានអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងធនធានផ្សេងៗ ដូចជា កិច្ចការពារតំបន់ព្រៃដើម្បីទុកធ្វើជាតំបន់ទ្រនាប់ទប់ទល់នឹងខ្យល់ព្យុះជាដើម ។ ប៉ុន្តែជារឿយៗបណ្តាស្ថាប័នកិរិតភូមិ មិនអាចអនុវត្តរបៀបរបបគ្រប់គ្រងធនធាន ដូចជា ការដើរល្បាត និងសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ផ្សេងៗ ដោយគ្មានការគាំទ្រតាមបែបណាមួយពីថ្នាក់លើនោះទេ ពីព្រោះទំនាក់ទំនងក្នុងសង្គមកម្ពុជាត្រូវធ្វើឡើងនៅក្នុងបរិបទមានឋានានុក្រមនិងអំណាចផ្តាច់ការ ។ ដូច្នេះគេអាចលើកកំពស់យុទ្ធសាស្ត្រគ្រប់គ្រងធនធានបាន (ដោយ មានអារម្មណ៍ថា មិនសូវប្រថុយពេកក្នុងការសាកល្បងវិធីផ្សេងៗ) នៅពេល មានការគាំទ្រដ៏សមស្របជាផ្លូវការ (គោលនយោបាយ) និងក្រៅផ្លូវការ (អ្នកធំ) ដល់ការចូលពាក់ព័ន្ធរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធាន ។

នៅកម្ពុជា តាំងពីទសវត្សរ៍១៩៩០ មក មានគំរោងជាច្រើនដែលធ្វើការ

---

* **Melissa Marschke** ជាបេក្ខនារីថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យមានីតូបានៅប្រទេសកាណាដា ។ អត្ថបទនេះផ្អែកលើការស្រាវជ្រាវថ្នាក់បណ្ឌិតរបស់គាត់ គួបនឹងការងារផ្សេងទៀតដែលគាត់បានធ្វើនៅជនបទ កម្ពុជាតាំងពីឆ្នាំ១៩៩៩ ។ ពត៌មានបន្ថែម: **Melissa Marschke <mjmarschkeca@yahoo.com>**

លើ CBNRM ដូចជាបណ្ដាគំរោងផ្ដល់មូលនិធិដោយ FAO, GTZ, IDRC ជាដើម ។ ការងារ CBNRM ពីដំបូងៗនេះ ភាគច្រើនមានលក្ខណៈសាកល្បងៈ សមាជិកសហគមន៏ និង NGOs និង/ឬអ្នកសំរបសំរួលខាងរដ្ឋាភិបាល បានធ្វើការងារដើម្បីស្វែងយល់ថា តើការគ្រប់គ្រងធនធានអាចមានរូបភាពយ៉ាងដូចម្ដេច "នៅផ្ទាល់កន្លែង" ។ ក្នុងករណីទាំងនេះ ស្ថាប័នគ្រប់គ្រងធនធានកំរិតភូមិត្រូវបានបង្កើតឡើងដោយពុំមានគោលនយោបាយណែនាំទេ ហើយផែនទី និងផែនការគ្រប់គ្រងផ្សេងៗ ត្រូវបានទទួលស្គាល់ជាលក្ខណៈក្រៅផ្លូវការតាមរយៈហត្ថលេខាដ៏សមស្របមួយចំនួន (តាំងពីមេភូមិដល់អភិបាលខេត្ដ), និងក្នុងករណីខ្លះតាមរយៈមន្ទីរក្រសួងជំនាញនៅកំរិតខេត្ដ និងកំរិតជាតិ ។ ដូច្នេះបទពិសោធន៏ពីដំបូងៗទាំងនេះ បានរួមវិភាគទានដល់ការរីកដុះដាលដំណើរការ CBNRM (ឬយ៉ាងហោចណាស់ក៏ចំណែកខ្លះនៃដំណើរការទាំងនេះដែរ) នៅទូទាំងប្រទេសកម្ពុជានាបច្ចុប្បន្ន ដូចជាតាមរយៈកម្មវិធីវិមជ្ឈការរបស់រដ្ឋាភិបាល កម្មវិធីគ្រប់គ្រងដីធ្លី និងកម្មវិធីព្រៃឈើ និងជលផលសហគមន៏ជាដើម ។ម្យ៉ាងទៀត NGOs ខាងបរិស្ថានបានបន្ថែម "ការគ្រប់គ្រងផ្អែកលើសហគមន៏" ទៅក្នុងការងាររបស់ពួកគេ (Marschke 2004) ។

ការងារ CBNRM នៅខេត្ដរតនគីរី (គាំទ្រដោយ IDRC/UNDP/SIDA) គឺជាឧទាហរណ៏មួយដែលបានជះឥទ្ធិពលយ៉ាងច្រើនទៅលើវិធីសាស្ដ្រ ដែលសំដៅដាក់បញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ ទៅក្នុងកម្មវិធីវិមជ្ឈការរបស់កម្ពុជា ។ កិច្ចប្រឹងប្រែងដាក់បញ្ជ្រាបការគ្រប់គ្រងធនធានទៅក្នុងផែនការអភិវឌ្ឍន៏ឃុំ បានចាប់ផ្ដើមនៅឆ្នាំ២០០៣ ក្នុង ៤០ឃុំ ។ បទពិសោធន៏ផ្សេងៗទៀតបានជួយដល់ការបង្កើតគោលនយោបាយគាំទ្រដល់ព្រៃឈើសហគមន៏ និងជលផលសហគមន៏ ។ ឧទាហរណ៏ គំរោង FAO-សៀមរាប បានជះឥទ្ធិពលគួរកត់សំគាល់ទៅលើ "កំណែទំរង់ជលផល" ឆ្នាំ២០០១ របស់កម្ពុជា ។ ក្នុងការផ្សារភ្ជាប់ការគ្រប់គ្រងដីធ្លីទៅនឹងបញ្ហាគ្រប់គ្រងធនធាន ធម្មជាតិ, សេចក្ដីណែនាំ PLUP បានផុសចេញអំពីសិក្ខាសាលាមួយខ្សែជាមួយ សហគមន៏ព្រៃឈើ អ្នកសំរបសំរួលខាងជលផល និងមន្ដ្រីរដ្ឋាភិបាល ដែលបានធ្វើឡើងពីឆ្នាំ១៩៩៩ ដល់ ២០០១ (ដំណើរការនេះសំរបសំរួលដោយ GTZ) ។ ប៉ុន្ដែវាមិនច្បាស់ទេថាតើដំណើរការទាំងនេះ នៅពេលគេស្គាល់វាកាន់តែច្រើនឡើង នឹងអាចលើកកំពស់កំរិតជីវភាពនៅមូលដ្ឋាន ឬក៏ដោះស្រាយបញ្ហាគ្រប់គ្រងធនធានបានឬទេ ។

## បរិបទគោលនយោបាយ "ជាផ្លូវការ": ចលនាមួយ?

*"ខ្ញុំដឹងពីរឿងច្បាប់ ។ ច្បាប់ថ្នាក់លើ និងច្បាប់នៅមូលដ្ឋានផ្ទុយគ្នាស្រឡះ ។ ច្បាប់នៅមូលដ្ឋានចង់ការពារសហគមន៏ ប៉ុន្ដែថ្នាក់លើមិនគាំទ្ររឿងនេះទេ ។ ពួកគេនិយាយថា វាខុសច្បាប់ដែលពួកយើងឃាត់ និងចាប់ខ្លួនពួកចោរ ។ យើងអាចឃ្លាំមើល និងផ្ដល់ពត៌មានទៅឱ្យបុគ្គលិកបច្ចេកទេស ។ (ប៉ុន្ដែ) ទំរាំយើងធ្វើរឿងនេះ វាឃើតពេលរាល់តែលើក ។ ខ្ញុំអាចយល់ដឹងពីច្បាប់ខ្លះៗ ដោយសារការបណ្ដុះបណ្ដាលជាច្រើនដែលខ្ញុំបានចូលរួម ។ ច្បាប់របស់រដ្ឋាភិបាលមិនផ្ដល់សិទ្ធិអ្វីឱ្យប្រជាជននៅមូលដ្ឋានទេ" អ្នកភូមិម្នាក់នៅខេត្ដសៀមរាប, ថ្ងៃ ១៨ មីនា ២០០៤ ។*

បើពិនិត្យខាងស្ថាប័នវិញ មានមន្ទីរក្រសួងរដ្ឋជាច្រើនបានទទួលភារកិច្ចមួយចំនួនជាប់ទាក់ទិននឹងការគ្រប់គ្រងធនធាន (សូមមើលតារាង១) ។ ស្ថាប័នរដ្ឋនិមួយៗ ធ្វើការជាមួយពួកអ្នកកសាងគោលនយោបាយរបស់ខ្លួនផ្ទាល់ ដើម្បីតាក់តែងច្បាប់ៈ ក្នុងករណីខ្លះ មានការសង្កត់ធ្ងន់លើការកសាងផែនការមជ្ឈការ ដូចជានៅក្នុងក្រសួងមហាផ្ទៃជាដើម ។ ស្ថាប័ននានាមិនសុទ្ធតែបានដឹងអំពី ឬបានធ្វើទំនាក់ទំនងជាមួយស្ថាប័នឯទៀតៗដែលធ្វើការងារប្រហាក់ប្រហែលគ្នានោះទេ ។

ម ា -
នយន្ដការខាងច្បាប់មួយចំនួនសំរាប់គាំទ្រការចូលពាក់ព័ន្ធរបស់សហគមន៏ក្នុងការគ្រប់គ្រងធនធាន ។ ឧទាហរណ៏ ក្នុង *ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់* ក្រុមប្រឹក្សាឃុំ-មានបទប្បញ្ញតិយ៉ាងទូលាយមួយទាក់ទិននឹងការគ្រប់គ្រង និង-កិច្ចការពារធនធានធម្មជាតិ (មាត្រា ៤១ និង ៤៣) ប៉ុន្ដែ "ក្រុមប្រឹក្សាឃុំគ្មានអំណាចសំរេច លើវិស័យព្រៃឈើ... ទេ" (មាត្រា ៤៥) ។ យោងតាមអនុក្រឹត្យព្រៃឈើសហគមន៏, ព្រៃឈើសហគមន៏អាចកើតមានឡើង តាមការសំរេចយល់ព្រមរបស់រដ្ឋបាលព្រៃឈើ ។ ឯកសារច្បាប់ផ្សេងទៀត ដូចជា អនុក្រឹត្យជលផលសហគមន៏ កំពុងរង់ចាំការអនុមតិ ។

ជាមួយនឹងការរីកដុះដាលយន្ដការខាងច្បាប់ និងដំណើរការគ្រប់គ្រងធនធានផ្សេងៗ, ក៏មានការសង្កត់ធ្ងន់លើដំណើរការធ្វើផែនការ ។ ឧទាហរណ៏ការធ្វើផែនការ គឺជាចំណែកដ៏ពេញលេញមួយនៃកិច្ចធ្វើការងារនៅក្នុងរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាឃុំ ហើយតាមនេះ គឺកិច្ចធ្វើការងារលើការគ្រប់គ្រងធនធាន ។ ទោះបីវាជាការរៀបចំផែនការអភិវឌ្ឍន៏ឃុំរយៈ៥ឆ្នាំ និងផែនការវិនិយោគប្រចាំឆ្នាំរបស់ឃុំ, ឬក៏ការរៀបចំផែនការជលផលសហគមន៏ ឬព្រៃឈើសហគមន៏ក្ដី, អ្នកភូមិក្នុងគ្រប់ឃុំសុទ្ធតែមានបទពិសោធន៏ធ្វើផែនការ! ។ នៅឆ្នាំ២០០២ គេប៉ាន់ថា មានជលផលសហគមន៏ ១៦២កន្លែងនៅកម្ពុជា (McKenny & Prom 2002), ហើយនៅឆ្នាំ២០០៤ យោងតាមនាយក-ដ្ឋានជលផល គឺមានជលផលសហគមន៏ដល់ទៅ ៣២៩កន្លែង ។

គួរឱ្យស្ដាយ ផែនការទាំងនេះភាគច្រើនគឺជំរុញដោយអ្នកសំរបសំរួលមកពីក្រៅ (NGOs ឬរដ្ឋាភិបាល) ដែលអាចបានយល់ ឬមិនបានយល់ទេថា ក្នុងឋានៈជាអ្នកសំរបសំរួលតើត្រូវធ្វើអ្វី។ ជារឿយៗគេសន្មតថា ប្រជាជននៅ

**តារាង១ៈ ការទទួលខុសត្រូវខាងស្ថាប័នទាក់ទិននឹងការគ្រប់គ្រងធនធានធម្មជាតិ**

| ស្ថាប័ន | ការទទួលខុសត្រូវទាក់ទិននឹងការគ្រប់គ្រងធនធានធម្មជាតិ | ឧបករណ៏ខាងច្បាប់/គោលនយោបាយទាក់ទិននឹង CBNRM |
|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) | ទទួលខុសត្រូវលើការអភិវឌ្ឍន៏កសិកម្ម និងសកម្មភាពជលផល ក្នុង-វិស័យជលផល | សេចក្ដីព្រាងអនុក្រឹត្យជលផលសហគមន៏ |
| រដ្ឋបាលព្រៃឈើ (FA) | ទទួលខុសត្រូវលេ-ើរាល់សកម្មភាពខាងព្រៃឈើក្នុង វិស័យព្រៃឈើ | អនុក្រឹត្យព្រៃឈើសហគមន៏ |
| ក្រសួងបរិស្ថាន (MoE) | ទទួលខុសត្រូវលើតំបន់ការពារធម្មជាតិៈ សត្វព្រៃ និងកិច្ចការពារបរិស្ថាន | សេចក្ដីព្រាងអនុក្រឹត្យតំបន់ការពារធម្មជាតិ |
| ក្រសួងមហាផ្ទៃ (MoI) | ទទួលបន្ទុកលើវិមជ្ឈការ និងការពិនិត្យតាមដាន | ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) | ទទួលខុសត្រូវលើការធ្វើផែនការប្រើប្រាស់ដី, ការបែងចែកដី, ការគ្រប់គ្រងដី | អនុក្រឹត្យសម្បទានដីសង្គមកិច្ច ការធ្វើផែនការប្រើដីដោយមានការចូលរួម (គោលនយោបាយ) |

**តារាង២. ការប្រៀបធៀបដំណើរការគ្រប់គ្រងធនធាន ទាំងបី**

| | ជលផលសហគមន៍ | PLUP | ការបញ្ជ្រាប NREM |
|---|---|---|---|
| គោលដៅ | ផ្តល់លទ្ធភាពឱ្យអ្នកភូមិ, ដោយមានកិច្ចគាំទ្រ ពង្រឹងការអនុវត្តន៍អំពីបុគ្គលិក DoF ដើម្បីការពារនិងគ្រប់គ្រងជ | ដោះស្រ- សាយបញ្ហាគ្រប់គ្រងធនធាន និងកាន់កាប់ដី | កសាងការយល់ដឹងពីបញ្ហា NREM ក្នុងដំណើរការធ្វើផែនការកំរិតឃុំ |
| តើច្រើនប៉ុណ្ណា | ជលផលសហគមន៍ មាន ៣២៩កន្លែង | ១១ឃុំបានធ្វើហើយ, ៩ឃុំកំពុងធ្វើ | ៤០ឃុំនៅឆ្នាំ២០០៣, ពង្រីកថែមនៅឆ្នាំ២០០៤ |
| បញ្ហាប្រឈម | អ្នកភូមិមិនអាចពង្រឹងការអនុវតន៍ច្បាប់ ដោយគ្មានបុគ្គលិក DoF (ខ្វះបុគ្គលិក) ត្រីចល័ត ខ្លាំងណាស់សមត្ថភាពមានកំរិតនៃបុគ្គលិក DoF ដើម្បីសំរបសំរួលរឿងនេះ | វិធីសាស្ត្រដោះស្រាយបញ្ហាស្មុគស្មាញដែលទាមទារជំនាញសំរបសំរួលដ៏មាំទាំ "ការរំលោភយកដី" ជារឿងស្មុគស្មាញ, បញ្ហាដីធ្លីពិបាកកសាងចេញជាផែនទី ដោយសារចរិតក្រៅផ្លូវការនៃការដោះដូរដីភាគច្រើន | ដាក់បញ្ចូល NREM ទៅក្នុងដំនើរការធ្វើផែនការមួយដែលកំណត់ជាមុន និងផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ គឺជាបញ្ហាប្រឈម ពីព្រោះ NREM ទាមទារដំណោះស្រាយរយៈវែង បញ្ជ្រាប NREM មិន-ទាន់ជំរុញដោយកំរិតមូលដ្ឋានេ |

មូលដ្ឋានខ្វះសមត្ថភាពដើម្បីអនុវត្តផែនការបែបនេះខ្លួនឯង ដូច្នេះហើយ ក៏មានវគ្គបណ្តុះបណ្តាល និងកសាងសមត្ថភាពដ៏ច្រើន ដែលពួកអ្នកភូមិអាចបានចូលរួម ។ មានផុសសំនួរដ៏ធំមួយថាតើយន្តការធ្វើផែនការដ៏ស៊ីជំរៅបែបនេះវាសមស្របឬទេ ។ មានគោលនយោបាយច្រើនណាស់នៅលើក្រដាស ប៉ុន្តែក្នុងករណីជាច្រើន "ការអនុវត្តន៍" ហាក់ដូចដើរយឺតជាងការធ្វើផែនការ ។ Blunt (2003: 57) ក៏បានចោទសួរពីតំរូវការនូវដំណើរការធ្វើផែនការដ៏ស្មុគស្មាញបែបនេះទាក់ទិននឹងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែរ:

*"សំនួរគឺ តើចំណាយផលិតកម្មខ្ពស់ វាបានផ្តល់តំលៃបន្ថែមគ្រប់គ្រាន់ឬទេ ។ តើនីតិវិធីធ្វើផែនការដ៏ស្មុគស្មាញដែលបានប្រើប្រាស់ វានាំឱ្យមានសេចក្តីសំរេចចិត្តខុសប្លែក និងប្រសើរឡើងដោយក្រុមប្រឹក្សាឃុំឬទាក់ទិននឹងការកំណត់ពីតំរូវការ និងអាទិភាពនានា ។ ឬក៏មានការកសាងផ្លូវ ស្ពាន និងអណ្តូងដូចគ្នា នៅក្នុងកន្លែងដូចគ្នាដែរ បើសិនគេប្រើនីតិវិធីធ្វើផែនការដែលសាមញ្ញជាង និងថោកជាង?"*

ដោយសារជារឿយៗការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវាងាយធ្វើផែនការជាងការដោះស្រាយបញ្ហាគ្រប់គ្រងធនធាន, ហើយភាពស្មុគស្មាញនៃការធ្វើផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក៏មានគេចោទសំនួរដែរ, ដូច្នេះគឺមានមេរៀនមួយដែលអាចរៀនសូត្របាន! ។ ដំណើរការធ្វើផែនការត្រូវតែធ្វើឱ្យសាមញ្ញ និងអាចបត់បែនបានច្រើនជាងនេះ ដើម្បីទុកលទ្ធភាពឱ្យអ្នកភូមិ និង NGOs/ស្ថាប័នរដ្ឋនានា ចំណាយពេលបានច្រើនទៅលើគំរោងលើកកំពស់ជីវភាព និងការដោះស្រាយបញ្ហាគ្រប់គ្រងធនធាន ។

## ការប្រៀបធៀបដំណើរការគ្រប់គ្រងធនធាន ទាំងបី

ថ្វីបើពីដំបូងតែងមាន "ដីទួល" ខ្លះដែលត្រូវពង្រាប ប៉ុន្តែគេមានបរិបទគោលនយោបាយមួយដែលផ្តល់ឱ្យសហគមន៍នានានូវលទ្ធភាពធ្វើផែនការព្រមទាំងអាចឈានថែមទៀតទៅដល់ការអនុវត្តន៍សកម្មភាពគ្រប់គ្រងធនធានក្នុងមូលដ្ឋាន ។ ការវិភាគយ៉ាងជិតដល់នូវជលផលសហគមន៍ ដំណើរការដាក់បញ្ជ្រាប PLUP និង NREM បានឆ្លុះបញ្ចាំងថាតើដំណើរការទាំងនេះវាត្រួតគ្នាប៉ុណ្ណា ប៉ុន្តែដំណើរការនិមួយៗមានគោលដៅខុសគ្នាបន្តិចៗ (សូមមើលតារាង២) ។

ដំណើរការនិមួយៗដូចខាងលើ សង្កត់ធ្ងន់លើការធ្វើផែនការស៊ីជំរៅនៅកំរិតភូមិ និងឃុំ ។ ឧទាហរណ៍ កម្មវិធីដាក់បញ្ជ្រាប NREM បានបន្ថែមការងារធ្វើផែនការកំរិតឃុំចំនួន២ថ្ងៃទៀត ទៅក្នុងដំណើរការធ្វើផែនការកំរិតឃុំដែលមមាញឹកស្រាប់ (Marschke 2004) ។ គេប៉ាន់ថា ការសំរបសំរួលដំណើរការ PLUB មួយនៅកំរិតភូមិ ត្រូវចំណាយពេល ២១ថ្ងៃក្នុងមួយភូមិ (មកទល់សព្វថ្ងៃ បទពិសោធន៍អនុវត្តន៍ គឺនៅមានកំរិត) ។ រីឯការបង្កើតផែនការគ្រប់គ្រងជលផលសហគមន៍ ត្រូវចំណាយច្រើនថ្ងៃ ឬច្រើនខែ ទៅតាមរឿងថាតើបុគ្គលិករបស់ NGO ឬក៏នាយកដ្ឋានជលផល (DoF) ដែលមកធ្វើជាអ្នកសំរបសំរួល ។ ក្នុងដំណើរការទាំង៣ ត្រូវមានអ្នកសំរបសំរួលពីក្រៅ មកជួយភូមិឬឃុំ ដើម្បីធ្វើផែនការនេះ ដែលមានទាំងការកសាងផែនទីបច្ចេកទេសលំអិតផង ។ម្យ៉ាងទៀត មានការផុសសេចក្តីសង្ឃឹមក្នុងចំនោមអ្នកភូមិដែលបានចូលរួមក្នុងដំណើរការ ហើយសេចក្តីសង្ឃឹមនោះ "ត្រូវរលាយអស់" នៅពេលការអនុវត្តន៍ជាក់ស្តែងធ្វើបានតិច ។

រឿងកើតឡើងជារឿយៗគឺ អ្នកភូមិត្រូវបានគេជួយសំរបសំរួលឱ្យធ្វើផែនការបែបនេះ ទទួលបានការយល់ព្រម ហើយបន្ទាប់មកក៏ត្រូវព្រលែងចោលឱ្យអនុវត្តផែនការគ្រប់គ្រងធនធានទាំងនេះដោយខ្លួនឯង ។ គឺបានន័យថា មានពេលតិចតួចសំរាប់ឱ្យអ្នកសំរបសំរួលចុះធ្វើការជាក់ស្តែងជាមួយអ្នកភូមិដើម្បីជួយដោះស្រាយបញ្ហា ពីព្រោះពួកគេត្រូវទៅភូមិ ឬឃុំមួយទៀតដើម្បីបន្តដំណើរការធ្វើផែនការ ។ ដូច្នេះរឿងសំខាន់នៅពេលនេះ គឺតើត្រូវធ្វើយ៉ាងណាជួយទ្រទ្រង់ដល់អ្នកភូមិក្នុងការអនុវត្តន៍ផែនការ និងស្វែងរកដំណោះស្រាយសំរាប់បញ្ហាផ្សេងៗរបស់ពួកគេ ។ ឧទាហរណ៍ ដើម្បីអនុវត្តជាក់ស្តែងនូវសកម្មភាព CBNRM, ជារឿយៗត្រូវមានការសំរបសំរួល និងការគាំទ្រជាប់រហូត ក្នុងពេលដែលអ្នកភូមិកំពុងចូលប្រឡូកក្នុងបញ្ហាដ៏ស្មុគស្មាញនានា ។ សំខាន់ដូចគ្នាដែរ ត្រូវមាន "ការជឿតាម" របស់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីសំខាន់ៗខ្លះ ដើម្បីឱ្យអ្នកភូមិមានអារម្មណ៍នឹងនក្នុងការអនុវត្តន៍ឱ្យបានចប់ចុងចប់ដើមនូវផែនការគ្រប់គ្រងធនធានរបស់ខ្លួន ។

## តើត្រូវធ្វើអ្វីខ្លះដើម្បី "អនុវត្ត" នៅផ្ទាល់កន្លែង

ឧទាហរណ៍ខាងក្រោម ដែលផ្អែកលើបទពិសោធន៍នៃការគ្រប់គ្រងធនធានព្រៃកោងកាងដោយមានការចូលរួម (PMMR) នៅខេត្តកោះកុង បានឆ្លុះបញ្ចាំងថា ហេតុអ្វីបានជាពេលវេលា និងការគាំទ្រតាមការសំរបសំរួល វាចាំបាច់ណាស់សំរាប់ឱ្យអ្នកភូមិអនុវត្តសកម្មភាពគ្រប់គ្រងធនធានប្រភេទខ្លះ ។

នៅខេត្តកោះកុង ការបញ្ឈប់ផលិតកម្មធ្យូងខុសច្បាប់ គឺជាការប្រយុទ្ធជាប់រហូតមួយទាំងចំពោះអ្នកភូមិ និងមន្ត្រីខេត្ត ។ ក្នុងទសវត្សរ៍១៩៩០ អ្នកភូមិជាច្រើនធ្វើចំណាកស្រុកទៅកាន់តំបន់ព្រៃកោងកាងក្នុងខេត្តកោះកុង ដើម្បីផលិតធ្យូង (ឈើកោងកាងឆេះល្អ និងផលិតធ្យូងមានគុណភាពខ្ពស់) សំរាប់លក់ទៅថៃ ។ ប្រព័ន្ធនេះស្មុគស្មាញ ដោយមានឈ្មួញកណ្តាលប្រមូលយកផលចំណេញភាគច្រើន និងអ្នកក្រីក្រដែលកាប់ដើមកោងកាងផលិតធ្យូង ។ សកម្មភាពទប់ស្កាត់ផ្សេងៗគាំទ្រដោយរដ្ឋាភិបាលបានចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍១៩៩០ ហើយការទប់ស្កាត់ខ្លាំងក្លាបំផុត គឺនៅឆ្នាំ១៩៩៩។ នៅពេលនោះអ្នកភូមិមើលឃើញច្បាស់ថា ផលិតកម្មធ្យូងមិនមែនជាជំរើសមានសុវត្ថិភាពសំរាប់ពួកគេទេ ហើយប្រជាជនភាគច្រើនបានបែរទៅធ្វើនេសាទវិញ ។

នៅពេលគណៈកម្មការគ្រប់គ្រងធនធានកំរិតភូមិជាប់ឆ្នោត (គំរោង PMMR បានអនុវត្តវិធីសាស្ត្រដែលថា CBNRM វាឪណាមិក និងគ្របដណ្តប់លើធនធានច្រើនមុខ) នៅក្នុងតំបន់នោះ ចាប់ផ្តើមធ្វើផែនការគ្រប់គ្រង ធនធានរបស់ខ្លួន

ការបញ្ឈប់សកម្មភាពខុសច្បាប់ដូចជាផលិតកម្មធ្យូងជា ដើម ក៏ត្រូវបានដាក់បញ្ចូលក្នុងផែនការ ។ មុនពេលបង្កើតគណៈកម្មការគ្រប់គ្រងធនធាន, សហគមន៏នៅមូលដ្ឋានមានការភ័យខ្លាចមិនហ៊ានបញ្ឈប់សកម្មភាពខុសច្បាប់ដែលគាំទ្រដោយពួកអ្នកមានអំណាចនោះទេ (គឺអ្នក មានអាវុធ មានប្រាក់ និងឥទ្ធិពល) ។ ប៉ុន្តែហេតុការណ៏ដូចតទៅបានបង្ហាញ ពីកំណើនទំនុកចិត្តរបស់គណៈកម្មការមួយនៅក្នុងការងារគ្រប់គ្រងធនធាន របស់ខ្លួន ។

នៅខែឧសភា ២០០២ គណៈកម្មការគ្រប់គ្រងធនធាននៅកោះស្រឡៅ បានចាប់ទូកមួយដែលមានដឹកឈើកោងកាងយ៉ាងច្រើន ។ ទូកនេះគ្មានការអនុញ្ញាតឱ្យកាប់ដើមកោងកាង អំពីគណៈកម្មការគ្រប់គ្រងធនធានដែលជាប់ឆ្នោតក្នុងមូលដ្ឋានទេ: តាមបទប្បញ្ញត្តិដែលបានអនុម័តហើយរបស់ពួកគេ ឈើកោងកាងអាចកាប់បានសំរាប់តែធ្វើផ្ទះប៉ុណ្ណោះ ។ ប៉ុន្តែម្ចាស់ទូកមានខ្សែរយៈជាប់ជាមួយមេបញ្ជាការប៉ូលីសខេត្ត ។ ដូច្នេះក្រោយពេល គេរឹបអូសឈើ ម្ចាស់ទូកបានហៅប៉ូលីសខេត្ត ។ PMMR បានរំលឹកប៉ូលីសថា អភិបាលខេត្តបានចុះហត្ថលេខាលើ ផែនការគ្រប់គ្រងរបស់គណៈកម្មការ ហើយទង្វើរបស់គណៈកម្មការគឺ ការបញ្ឈប់សកម្មភាពខុសច្បាប់ ។ PMMR បានស្នើឱ្យប៉ូលីសធ្វើការជាមួយគណៈកម្មការដើម្បីដោះស្រាយបញ្ហា ។ គណៈកម្មការក៏អាចចរចាឱ្យម្ចាស់ទូកបង់ប្រាក់ពិន័យ និងចុះកិច្ចសន្យាថាលែងប្រព្រឹត្តសកម្មភាពខុសច្បាប់នៅក្នុងតំបន់នោះទៀត ។ នេះជាជោគជ័យគួរឱ្យកត់សំគាល់មួយរបស់គណៈកម្មការគ្រប់គ្រងធនធាន ពីព្រោះម្ចាស់ទូកមានចំណងទាក់ទងជាមួយប៉ូលីសខេត្ត ដែលជាស្ថាប័នមានអំណាចខ្លាំង ជាងគណៈកម្មការឆ្ងាយណាស់ (Nong and Marschke, *in press*)! ។

ថ្វីបើគណៈកម្មការគ្រប់គ្រងធនធាន ត្រូវការជំនួយគាំទ្រអំពី PMMR ជាពិសេសដើម្បីរំលឹកថា ពួកគេមានសិទ្ធិបញ្ឈប់សកម្មភាពខុសច្បាប់ ប៉ុន្តែគណៈកម្មការខ្លួនឯងត្រូវចរចាពីវិធីដោះស្រាយបញ្ហា ។ បើសិនគ្មានហត្ថលេខារបស់អភិបាលខេត្ត និងគ្មានជំនួយសំរបសំរួលពី PMMR, រឿងនេះមិនប្រាកដថាអាចធ្វើកើតទេ ។ CBNRM ត្រូវមានការគាំទ្រពីតួអង្គជាច្រើន នៅកំរិតខេត្ត និងកំរិតជាតិ ។ ការដាក់បញ្ចូលអ្នកពាក់ព័ន្ធច្រើន ជួនកាលធ្វើឱ្យគេមានអារម្មណ៏នឿយហត់ ប៉ុន្តែជាទូទៅការគាំទ្រនឹងមានប្រយោជន៏ទៅអនាគត ។ ជោគជ័យនៃកិច្ចការពារព្រៃកោងកាង ផុសចេញពីសហប្រតិបត្តិការ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា ទាំងអ្នកគាំទ្រដោយផ្ទាល់ និងដោយប្រយោលដល់ CBNRM ។ ដូចលោក ស៊ិក (២០០២) បានកត់សំគាល់: ការគ្រប់គ្រងធនធានបានជោគជ័យ "មិនមែនដោយសារអវត្តមាន ភាពសំបូរបែប ទំនាស់ និងការតតាំងអំណាចគ្នានោះទេ ប៉ុន្តែតាមរយៈយន្តការដែលបានកកើតមាំទាំហើយសំរាប់ការចរចា និងដោះស្រាយទំនាស់" ។

## ការវិភាគពីនិន្នាការក្នុង NRM

*"ខ្ញុំសោកស្តាយណាស់ដែលអ្នកមានអំណាចបានចំណេញពីការបំផ្លិចបំផ្លាញធនធានធម្មជាតិរបស់យើង ។ អ្នកឃើញទេ តាមការបំផ្លិចបំផ្លាញធនធាននៅក្នុងព្រៃ និងនៅបឹងទន្លេសាប ពួកគេបានចំណេញប្រាក់កាន់តែច្រើនឡើងៗ ដែលនាំឱ្យពួកគេមានអំណាចកាន់តែច្រើន" ។ អ្នកភូមិម្នាក់នៅខេត្តសៀមរាប ថ្ងៃ១៨ មីនា ២០០៤ ។*

ថ្វីបើ CBNRM ក្នុងទំរង់ផ្សេងៗ បានរីកដុះដាលពាសពេញកម្ពុជា ប៉ុន្តែមានការស្រាវជ្រាវតិចតួចដើម្បីបង្ហាញថា តើរបៀបរបបគ្រប់គ្រងធនធាននានា បានជួយកែលំអកំរិតជីវភាពឬទេ ។ Rock (2004) លើកថា វិធីសាស្ត្រគ្រប់គ្រងផ្អែកលើសហគមន៏ដែលអនុវត្តដោយស្ថាប័នរដ្ឋបានទុកលទ្ធភាពតូចណាស់សំរាប់គំនិតផ្តួចផ្តើមរបស់ភូមិ, ធ្វើឱ្យខូចខាតដល់តួនាទីរបស់ក្រុមប្រឹក្សាឃុំ និងផ្តល់តិចតួចឱ្យសហគមន៏នូវភារកិច្ចគ្រប់គ្រង និងសុវត្ថិភាពក្នុងការកាន់កាប់ ។ ឧទាហរណ៏ និន្នាការក្នុងវិស័យព្រៃសហគមន៏ គឺផ្តល់ព្រៃខូចគុណភាព ឬត្រូវគេរុករានទៅឱ្យសហគមន៏ ក្នុងគោលដៅការពារ និងកសាងធនធានឡើងវិញ ។ ធនធានដែលជាព្រៃឬជលផលមានតំលៃ កំរមានការបែងចែកណាស់: ការបែងចែកធនធានដ៏ខ្សត់ខ្សោយគឺ ជាបញ្ហាប្រឈមយ៉ាងធំ ចំពោះការលើកកំពស់ជីវភាពនៅមូលដ្ឋាន ។

ប្រហែលត្រូវមានការគួបផ្សំរបៀបរបបធ្វើសេចក្តីសំរេចចិត្តតាមបែប "ពីក្រោម-ឡើងលើ" និង "ពីលើ-ចុះក្រោម" ទើបអាចដោះស្រាយបញ្ហាគ្រប់គ្រងធនធានធម្មជាតិបាន ។ ដោយសារបរិបទវប្បធម៌កម្ពុជា មិនសូវទទួលយកទំរង់ "ពីក្រោម-ឡើងលើ" នៃការធ្វើសេចក្តីសំរេចចិត្ត ឬការជះឥទ្ធិពល, ដូច្នេះគួរគិតគូរឡើងវិញពីរបៀបអនុវត្ត CBNRM ។ ថ្វីបើគួរមាន ច្បាប់ផ្តល់សំលេងឱ្យអ្នកភូមិនៅក្នុងសកម្មភាពគ្រប់គ្រងធនធានក្តី ប៉ុន្តែក៏ ត្រូវជំរុញឱ្យមានការគាំទ្រដ៏សមស្របខាងស្ថាប័នដើម្បីធានាថា វិធីសាស្ត្រ នេះអាចដំណើរការបាន ។ Blunt (2003: 62) បានលើកថា "ច្រកដ៏ប្រសើរ បំផុតសំរាប់លើកកំពស់កំរិតនៃការចូលរួម គឺស្ថិតនៅលើការចង្អុលទិសដ៏ រឹងប៉ឹង និងគ្មានស្រពិចស្រពិល (ពិតមែន) ពីថ្នាក់លើថា ប្រព័ន្ធរដ្ឋបាលនៅ មូលដ្ឋានត្រូវចូលពាក់ព័ន្ធជាមួយសហគមន៏តាមរបៀបនេះ ដោយមានគួបផ្សំ គ្រឿងលើកទឹកចិត្តដែលផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងការចូលពាក់ព័ន្ធ ។

## សេចក្តីសន្និដ្ឋាន

"ខ្ញុំមើលមិនដឹងថា តើមានអ្វីកើតឡើងតាមក្រោយផែនការ ។ គ្មានការអនុវត្តន៏ទេ ហើយខ្ញុំត្រូវខកចិត្ត ពីព្រោះមិនឃើញមានលទ្ធផល": នេះជាមតិអ្នកភូមិម្នាក់នៅពេលគេសាកសួរពីការចូលរួមរបស់គាត់ក្នុងការបង្កើតផែនការអភិវឌ្ឍន៏ឃុំ ។ អ្នកភូមិម្នាក់ទៀតត្អូញត្អែរថា "យើងបានធ្វើផែនការច្រើនណាស់ ប៉ុន្តែព្រៃឈើរបស់យើងនៅតែត្រូវគេកាប់រាន ហើយត្រីក៏កាន់តែតិចទៅៗ" (Marschkw 2004) ។ ដោយហេតុថា ជលផល/ព្រៃសហគមន៏, PLUP, និងការបញ្ជ្រាបដំណើរការ NREM នៅថ្មីថ្មោង, ទាំងអ្នកសំរបសំរួល និងអ្នកភូមិ សុទ្ធតែកំពុងរៀនសូត្រ ។ នៅពេលនេះ មានការសង្កត់ធ្ងន់លើ ដំណើរការធ្វើផែនការលំអិត មួយចំណែកគឺដោយសារការបង្កើតផែនការ គ្រប់គ្រងធនធាន វាងាយសំរបសំរួលជាង ការដោះស្រាយបញ្ហាជាក់ស្តែង ។ ប៉ុន្តែត្រូវកាត់បន្ថយការសង្កត់ធ្ងន់លើការបង្កើតផែនការ ដើម្បីទុកឱ្យចំណែក "សកម្មភាព" ក្នុងដំណើរការនេះ អាចកើតមានឡើង ។ ទំនាស់ទាក់ទិននឹងធនធានជាច្រើនមិនអាចមើលឃើញមុនទេ (ដូចជាការទន្ទ្រានដី ឬកំនើនការលួចឧបករណ៏នេសាទ): ដូច្នេះដំនើរការ CBNRM ត្រូវតែសកម្មគ្រប់គ្រង (ការធ្វើផែនការនិងបណ្តាញ) និងមានប្រតិកម្ម (ការឆ្លើយតប) ។

ដំណើរការ CBNRM ផ្សេងៗមានការត្រួតគ្នា ។ ឧទាហរណ៏ ពួកអ្នកភូមិដែលពាក់ព័ន្ធក្នុងការបញ្ជ្រាប NREM ទៅក្នុងផែនការឃុំ អាចបាន ឬមិនបានចូលពាក់ព័ន្ធធ្វើផែនការសំរាប់គំរោងជលផលសហគមន៏ជាមួយនាយកដ្ឋានជលផល ។ ម្យ៉ាងទៀត PLUP ឬក្រុមសំរបសំរួលផ្សេងទៀត អាចចូលទៅដល់ភូមិដោយមិនបានគិតគូរពីពត៌មានដែលមានកត់ត្រាក្នុងមូលដ្ឋានទិន្នន័យ

*តទៅទំព័រទី ១៣*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

នៅត្រីមាសទី១ ២០០៣ សេដ្ឋកិច្ចពិភពលោកបន្តមានលទ្ធផលរឹងប៉ឹងល្អ ទោះបីថាមពលឡើងថ្លៃខ្ពស់ក្តី ដែលធ្វើឱ្យមានការកែតំរូវតំលើងតួលេខកំណើនបានព្យាករណ៍ពីមុនសំរាប់សេដ្ឋកិច្ចនានានៅអាស៊ីខាងកើត ។ ប៉ុន្តែអត្រាអតិផរណានៅតែទាបដដែល ។

## កំណើនសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ច US បានរីកលូតលាស់តាមអត្រាប្រចាំឆ្នាំដ៏គួរឱ្យស្ញប់ស្ញែងដល់ ៥% ក្នុងរយៈពេល១ឆ្នាំមកដល់ចុងខែមីនា ២០០៤ ដែលជាកំណើនខ្ពស់បំផុតក្នុងរយៈ២០ឆ្នាំ ។ តាមការិយាល័យវិភាគសេដ្ឋកិច្ច កត្តាចំបងនៃកំនើន ក្នុង ផសស នេះគឺចំណាយប្រើប្រាស់ផ្ទាល់ខ្លួន, វិនិយោគក្នុងស្រុកឯកជនដុល, ចំណាយប្រើប្រាស់របស់រដ្ឋាភិបាល, និងការនាំចេញ ។ នៅត្រីមាសទី១ ២០០៤ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួនកើន ៤,៣% គិតពីមួយឆ្នាំទៅមួយឆ្នាំ ឬ កើន ០,៣% លឿនជាងកាលពីត្រីមាសមុន ដោយសារកំណើនចំណាយទិញ ទំនិញជាប់លាប់ (កើន ៩,៨%) និង ទំនិញមិនជាប់លាប់ (កើន ៥,១%) ។

នៅត្រីមាសទី១ ២០០៤ វិនិយោគក្នុងស្រុកឯកជនដុល កើន ១១,១% ធៀបនឹងកាលពីមួយឆ្នាំមុន ដែលជំរុញដោយកំណើនគួរកត់សំគាល់នៃវិនិយោគលើគ្រឿងបរិក្ខារ និងសូហ្វវែរ (កើន ១២,៥%) ។ ក្នុងរយៈពេលដដែល ចំណាយប្រើប្រាស់របស់រដ្ឋាភិបាលកើន ៣% ដែលឆ្លុះបញ្ចាំងពីកំនើនយ៉ាងច្រើន (១៣%) ក្នុងចំណាយការពារជាតិ ។ ក្នុងពេលជាមួយគ្នា ការនាំចេញស្ទុះឡើង ៨,៣% ដែលជាកំណើនខ្ពស់បំផុតក្នុង ១៤ត្រីមាសចុងក្រោយ ដោយសារលទ្ធផលល្អនៃការនាំចេញទំនិញ និងសេវា ។ ថ្វីបើនៅឆ្នាំ២០០៤ គោលនយោបាយជួយជំរុញប្រហែលមិនខ្លាំងក្លាដូចឆ្នាំមុនក្តី ប៉ុន្តែមានកត្តាជាច្រើនដែលនឹងបន្តធ្វើឱ្យមានការលូតលាស់យ៉ាងរលូនល្អនៅ US: លទ្ធផលកាន់តែប្រសើរខាងអាជីវកម្ម, ការកែលំអក្នុងផ្នែកក្រុមហ៊ុន និងទីផ្សារពលកម្ម, ព្រមទាំងកំណើនកាន់តែច្រើននៃចំណូលបុគ្គល ។ ដោយមូលហេតុនេះ IMF បានតំលើងតួលេខព្យាករណ៍ចុងក្រោយរបស់ខ្លួនពីសេដ្ឋកិច្ច US ដល់ ៤,៦% គឺតំលើង ០,៦% ធៀបនឹងការព្យាករណ៍លើកមុននៅខែកញ្ញា ២០០៣ ។ ការព្យាករណ៍សំរាប់ឆ្នាំ២០០៥ គឺ ៣,៩% ។

នៅត្រីមាសទី១ ២០០៤ សេដ្ឋកិច្ចនានានៅតំបន់អឺរ៉ូ ហាក់ដូចបានរើបឡើងវិញ ទោះបីមានការលូតលាស់ខ្សោយនៃចំណាយប្រើប្រាស់ក្នុងប្រទេសខ្លះៗក្តី (ពិសេសអាឡឺម៉ង់) ។ សេដ្ឋកិច្ចមានកំណើនប៉ាន់ស្មាន ១,៥% ធៀបនឹងកំរិត ០,៨% នៅត្រីមាសទី១ ២០០៣ ។ លទ្ធផលនេះមួយភាគធំ គឺដោយសារលទ្ធផលល្អជាងមុនក្នុងសេដ្ឋកិច្ចអាឡឺម៉ង់ និងបារាំង ហើយកត្តានាំមុខគេ (យ៉ាងហោចណាស់ក៏សំរាប់អាឡឺម៉ង់ដែរ) គឺលទ្ធផលដ៏ខ្លាំងនៃការនាំចេញដែលតំណាងឱ្យ ១/៣ នៃ ផសស អាឡឺម៉ង់ ។

នៅអាឡឺម៉ង់ កំនើនប្រចាំត្រីមាសទី១ ២០០៤ បានលឿនបំផុតក្នុងរយៈជាង៣ឆ្នាំចុងក្រោយ (ពត៌មានពី Bloomberg News) ។ ថ្វីបើក្នុងពេលកន្លងមក តំរូវការក្នុងស្រុកមានកំរិតខ្សោយ ប៉ុន្តែអ្នកវិភាគមានសុទិដ្ឋិនិយម ។ សេដ្ឋកិច្ចបារាំងកើន០,៨%គិតពីមួយឆ្នាំទៅមួយឆ្នាំនៅត្រីមាសទី១ ២០០៤ ដែលជាអត្រាលឿនបំផុតគិតតាំងពីឆ្នាំ២០០០មក និងដែលជំរុញដោយចំនាយវិនិយោគ និងចំនាយប្រើប្រាស់ (The Economist:២២-២៨ ឧសភា) ។ ក្នុងរយៈមួយឆ្នាំដល់ចុងត្រីមាសទី១ ផសស បារាំងកើន ១,៧% ប៉ុន្តែអត្រាគ្មានការងារធ្វើដ៏ខ្ពស់ (៨,៨%) អាចធ្វើឱ្យចុះខ្សោយដល់កំណើនចំណាយប្រើប្រាស់ ហើយការឡើងថ្លៃប្រាក់អឺរ៉ូកាន់តែខ្លាំងទល់នឹងដុល្លារ អាចធ្វើឱ្យចុះខ្សោយតំរូវការពីខាងក្រៅ ហើយតាមនេះគឺការលូតលាស់ ។

នៅត្រីមាសទី១ ២០០៤ សេដ្ឋកិច្ចជប៉ុនលូតលាស់តាមអត្រាប្រចាំឆ្នាំ ៥,៦% ដែលបង្ហាញថា ការរើបឡើងវិញនៅតែបានខ្ពស់ជាងការរំពឹងទុក និងដែលឆ្លុះបញ្ចាំងពីការកែលំអក្នុងចំណាយរបស់ក្រុមហ៊ុន ចំណាយប្រើប្រាស់ឯកជន និងការនាំចេញ ។ ថ្វីបើប្រាក់យ៉េនឡើងថ្លៃ ប៉ុន្តែតំរូវការយ៉ាងខ្លាំងពីបរទេសនូវគ្រឿងម៉ាស៊ីនឧស្សាហកម្ម និងគ្រឿងអេឡិចត្រូនិក ជាពិសេសពីបណ្តាប្រទេសនៅអាស៊ី ដូចជា ចិន កូរ៉េខាងត្បូង និងតៃវ៉ាន់ ជាដើម, បានពន្លឿនអត្រាកំណើនដល់ ១៥,១% នៅត្រីមាសទី១ ២០០៤ (ពត៌មានរបស់រដ្ឋាភិបាលជប៉ុន) ។ ទិន្នន័យថ្មីៗផ្សព្វផ្សាយដោយរដ្ឋាភិបាលជប៉ុន បាន បង្ហាញដែរថា នៅត្រីមាសទី១ តំរូវការឯកជនកើនឡើងគួរកត់សំគាល់ដល់ ៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដែលជាកំណើនលឿនបំផុតក្នុងរយៈ ១២ឆ្នាំ ។ នៅខែមីនា ២០០៤ អត្រាអ្នកគ្មានការងារធ្វើធ្លាក់ចុះដល់កំរិត ទាបបំផុតក្នុងរយៈ ៣ឆ្នាំ ដល់ ៤,៧% ហើយនេះជាកត្តាគន្លឹះដែលធ្វើឱ្យការរើបឡើងវិញមានចីរភាព ។ តាមវិទ្យាស្ថានស្រាវជ្រាវពីការធានារ៉ាប់រងជីវិតជប៉ុន កំណើននៅត្រីមាសទី១ ២០០៤ គឺជំរុញដោយតំរូវការក្នុងស្រុក ដោយសារទាំងចំណាយជាមូលធនរបស់ក្រុមហ៊ុន និងចំណាយប្រើប្រាស់ឯកជន សុទ្ធតែរឹងប៉ឹង ចំណែកឯការនាំចេញនៅតែមាននិន្នាការកើនឡើង ដោយសារសកម្មភាពសេដ្ឋកិច្ចខ្លាំងក្នុងប្រទេសសំខាន់ៗមួយចំនួន ។ មកទល់ពេលនេះ មានសញ្ញាកាន់តែច្រើនពីការរើបសេដ្ឋកិច្ចជប៉ុន ដែលរីកដុះដាល ចេញពីតំរូវការបំរើការនាំចេញ ទៅដល់វិស័យបំរើតំរូវការក្នុងស្រុក ។ ដើម្បី ឆ្លុះបញ្ចាំងពីការវិវត្តន៏នេះ IMF បានកែតំរូវការព្យាករណ៍អត្រាកំនើន ផសស ជប៉ុន ពី ២,២% ទៅជា ៣,៤% វិញ ។

នៅត្រីមាសទី១ ២០០៤ ផសស ចិន ស្ទុះឡើងដល់ ៩,៧% ដែលបង្កការបារម្ភកាន់តែច្រើនពីរឿងសេដ្ឋកិច្ចរត់លឿនពេក និងដែលជំរុញជាសំខាន់ដោយវិនិយោគលើទ្រព្យសកម្មជាប់លាប់ ។ យោងតាមការិយាល័យស្ថិតិជាតិចិន នៅត្រីមាសទី១ ២០០៤ វិនិយោគលើទ្រព្យសកម្មជាប់លាប់ស្ទុះឡើងយ៉ាងខ្លាំងដល់ទៅ ៤៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ម្យ៉ាងទៀត កំនើនការលក់ដូរនៅទីផ្សារក្នុងស្រុក ក៏បានជួយទ្រទ្រង់ ផសស ដែរ ។ នៅត្រីមាសទី១ ២០០៤ ការលក់រាយនៅចិន កើន ១១% គិតជាតួលេខពិត ដែលនាំមុខដោយកំណើនយ៉ាងលឿននៃការលក់រថយន្ត និងគ្រឿងបរិក្ខារទូរគមនាគមន៏ ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចចិន ក្នុង ៣ត្រីមាសចុងក្រោយនៃឆ្នាំ ២០០៤ នេះ រំពឹងថានឹងថយល្បឿនវិញ ដោយសាររដ្ឋាភិបាលបានរឹតបន្តឹងនយោបាយម៉ាក្រូសេដ្ឋកិច្ចថែមទៀត ដូចជា ការតំលើងធនបំរុងដែលត្រូវមាននៅធនាគារកណ្តាល និងការកាត់បន្ថយឥណទានចំពោះ វិស័យដែលរីកចំរើនលឿន (គឺមាន ដែកថែប រថយន្ត អចលនទ្រព្យ) ។

កំណើនសេដ្ឋកិច្ចសាកលកាន់តែខ្លាំងក្លា ជាពិសេសនៅចិន, បានបង្កើនតំរូវការទំនិញនាំចេញរបស់ប្រទេសអាស៊ីអគ្នេយ៏ ។ ក្នុងនេះ សេដ្ឋកិច្ចម៉ាឡេស៊ី កើនតាមអត្រាប្រចាំឆ្នាំ ៧,៦% ដែលជាអត្រាខ្ពស់បំផុតចាប់តាំងពីត្រីមាសទី៣ ឆ្នាំ២០០០ មក ។ នៅត្រីមាសទី១ ២០០៤ សេដ្ឋកិច្ចសិង្ហបុរី កើនលឿនជាងគឺបាន ៧,៥% ដោយសារបរិស្ថានខាងក្រៅអំណោយផល និងការកែលំអក្នុងវិស័យពាណិជ្ជកម្មលក់ដុំនិងលក់រាយ យោងតាមក្រសួងពាណិជ្ជ

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

កម្ម និងឧស្សាហកម្មសិង្ហបុរី ។ វិស័យកម្មន្តសាល បានរីកលូតលាស់ ១២,២% នៅត្រីមាសទី១ ២០០៤ ។ ក្នុងរយៈពេលដដែល ពាណិជ្ជកម្មលក់ដុំ និងលក់រាយ លូតលាស់ ១៣,៦% ធៀបនឹងត្រីមាសទី១ ២០០៣ ។

ផ្ទុយទៅវិញ សេដ្ឋកិច្ចថៃបានថយកំណើនមកត្រឹម ៦,៥% គិតពីមួយឆ្នាំទៅមួយឆ្នាំនៅត្រីមាសទី១ ២០០៤ ធៀបនឹងកំណើន ៧,៨%នៅត្រីមាសទី៤ ២០០៣ ។ រឿងនេះបណ្តាលពីការឆ្លងជំងឺផ្តាសាយបក្សី និងគ្រោះរាំងស្ងួតដ៏យូរ យោងតាមធនាគារកណ្តាលថៃ ។ ធៀបនឹងត្រីមាសទី១ ២០០៣, ចំណែកកសិកម្មនៅក្នុង ផសស រួមចុះអស់ ២,៨%នៅត្រីមាសទី១ ២០០៤ ក្នុងនេះចំណែកនៃផលដំណាំ និងសត្វចិញ្ចឹម នៅក្នុង ផសស បានថយចុះ ៣,៨% និង ២០,៧% រៀង១គ្នា ។ សេដ្ឋកិច្ចម៉ាឡេស៊ី និងសិង្ហបុរី បន្តកើនសន្ទុះនៅត្រីមាសទី២ ប៉ុន្តែនៅថៃ វាបង្កការបារម្ភខ្លះសំរាប់រយៈពេលខ្លី ដោយសារស្ថានការណ៍មិនច្បាស់លាស់នៅភាគខាងត្បូងប្រទេសដែលអាចប៉ះពាល់ដល់ទេសចរណ៍ ការងារ និងទំនុកចិត្តរបស់វិនិយោគិន/អ្នកប្រើប្រាស់ ។ ម្យ៉ាងទៀត ការថយល្បឿនសេដ្ឋកិច្ចចិនដែលគេរំពឹងទុក ក៏បង្កការបារម្ភចំពោះវិស័យនាំចេញដែរ ។

### អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ថ្វីបើប្រេងនៅបានឡើងថ្លៃគួរកត់សំគាល់ ប៉ុន្តែអតិផរណាក្នុងប្រទេសជាច្រើនស្ថិតនៅទាបគួរសម ។ នៅត្រីមាសទី១ ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ១,៧% គឺទាបជាងត្រីមាសទី៤ ២០០៣ បន្តិចដែលមានកំរិត ១,៩% និងដែលនាំឱ្យលោក Alan Greenspan ប្រធានធនាគារកណ្តាលUSផ្តល់មតិថា *អតិផរណាប្រហែលមិនមែនជាចំនុចត្រូវបារម្ភខ្លាំងទេក្នុងរយៈពេលខាងមុខនេះ* សំរាប់សេដ្ឋកិច្ច US (ពតិមានពី China Daily) ។ នៅតំបន់អឺរ៉ូ ថ្លៃទំនិញប្រើប្រាស់កើនយឺតបន្តិចវិញតាមអត្រា ១,៦% នៅត្រីមាសទី១ ២០០៤ ធៀបនឹងកំណើន ១,៩% នៅ ត្រីមាសមុន ចំនែកឯនៅជប៉ុន សំពាធបរិត្តផរណានៅមានជាបន្តទៀត ដោយកំរិតថ្លៃបានថយចុះ ០,១% នៅត្រីមាសទី១ ២០០៤ ។

នៅហុងកុង ចំណាយប្រើប្រាស់ខ្លាំងក្លាជាងមុនបានជួយកាត់បន្ថយអត្រាចុះថ្លៃទំនិញប្រើប្រាស់មកត្រឹម ១,២% នៅត្រីមាសទី១ ២០០៤ ធៀបនឹងកំរិត ២,៥%នៅត្រីមាសមុន ។ ក្នុងរយៈពេលដដែលថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរីកើនដល់ ១,៤% ដែលបណ្តាលជាសំខាន់ដោយសារកំណើនថ្លៃសឹងគ្រប់ប្រភេទសេវា និងទំនិញប្រើប្រាស់ លើកលែងតែសំលៀកបំពាក់ និងផ្ទះស្នាក់នៅ ។ ថ្លៃទំនិញប្រើប្រាស់នៅថៃកើនតាមអត្រា ១,៩% គិតពីមួយឆ្នាំទៅមួយឆ្នាំ ដែលឆ្លុះបញ្ចាំងជាសំខាន់ពីកំណើនថ្លៃម្ហូបអាហារ ។

ទិន្នន័យថ្មីបំផុតបង្ហាញថា ដុល្លារUS ចុះខ្សោយធៀបនឹងរូបិយវត្ថុចំបង១ និងរូបិយវត្ថុប្រទេសអាស៊ីភាគច្រើន ។ ដុល្លារUS បន្តចុះថ្លៃទល់នឹងអឺរ៉ូដល់កំរិតទាបបំផុតក្នុងរយៈ ១៩ត្រីមាស ដោយប្តូរបាន ០,៧៩អឺរ៉ូ/ដុល្លារUS នៅ ត្រីមាសទី១ ២០០៤ ។ ក្នុងរយៈពេលដដែល ដុល្លារUS ចុះថ្លៃអស់ ៤ត្រីមាសជាប់គ្នា ទល់នឹងប្រាក់យ៉េន ដល់ ១០៧,២យ៉េន/ដុល្លារUS ។ ក្នុងពេលនេះដែរ ដុល្លារUS ចុះថ្លៃទល់នឹងប្រាក់បាតថៃ និងដុល្លារសិង្ហបុរី អស់ ១,៥% និង ១,៧% ដល់ ៣៩,១បាត/ដុល្លារUS និង ១,៦៩ដុល្លារសិង្ហបុរី/ដុល្លារUS ប៉ុន្តែរំពឹងថានឹងឡើងថ្លៃវិញ បើសិនធនាគារកណ្តាលអាមេរិកតំលើងអត្រាការប្រាក់ក្នុងអនាគតដ៏ខ្លីខាងមុខ ។

### ថ្លៃផលិតផលក្នុងទីផ្សារពិភពលោក

នៅត្រីមាសទី១ ២០០៤ ថ្លៃអង្ករលេខ១ នៅទីផ្សារអន្តរជាតិក្រុងបាងកកឡើងដល់ ២១៥,៣ដុល្លារ/តោន ឬកំណើន ៩,៨%ធៀបនឹងត្រីមាសមុន ។ ថ្លៃអង្កររំពឹងថានឹងបន្តកើនឡើងក្នុងឆ្នាំ២០០៤ ដោយសារប្រទេសចិនដែលធ្លាប់តែនាំចេញអង្ករជាង ២លានតោន/ឆ្នាំ បានចាប់ផ្តើមនាំចូលអង្ករពីថៃ និងវៀតណាម, បន្ទាប់ពីមានការខូចផលស្រូវជាបន្តបន្ទាប់ (ពតិមានពី VNANET) ។ ផ្ទុយទៅវិញ ថ្លៃកៅស៊ូក្នុងទីផ្សារអន្តរជាតិនៅម៉ាឡេស៊ី បានថយចុះបន្តិចត្រឹម ១,២% ដល់ ១.២៤៦,៤ដុល្លារ/តោន នៅត្រីមាសទី១ ២០០៤ (១.២៦១,៤ដុល្លារ/តោននៅត្រីមាសមុន) ។ ក្នុងរយៈពេលដដែល ថ្លៃសណ្តែកសៀងនៅទីផ្សារអាមេរិកកើនឡើងគួរកត់សំគាល់ដល់ ២៣៨,៥ ដុល្លារ/តោន ឬកំណើន ៨,៥% ធៀបនឹងត្រីមាសមុន (២១៩,៧ដុល្លារ/តោន) ។ ក្នុងពេលដូចគ្នា ថ្លៃប្រេងឆៅកើនដល់ ២៩,៣ដុល្លារ/ធុង ឬកំនើន ៨,៥% ធៀបនឹងត្រីមាសមុន ។ កំណើននេះជំរុញដោយការព្យាករណ៍វិជ្ជមានពីការរើបសេដ្ឋកិច្ចក្នុងពិភពលោក ទោះបីស្តុកប្រេងUS មានភាពតឹងតែង, មជ្ឈិមបូព៌ាមានភាពមិនច្បាស់លាស់ និងមានសេចក្តីសំរេចរបស់ OPEC ថានឹងកាត់បន្ថយកូតាផលិតកម្មជាផ្លូវការចំនួន ១លានធុង/ថ្ងៃ ចាប់ពីថ្ងៃទី ១

---

*តពីទំព័រទី ១១* **កសាងផែនការ...**

របស់ឃុំទេ ដូច្នេះក៏ធ្វើលំហាត់ PRA ម្តងទៀតជាមួយអ្នកភូមិ ។ ការយល់ដឹងកាន់តែប្រសើរពីវិធីផ្សេង១ដែលមានប្រសិទ្ធភាព និង-ការសំរបសំរួលកាន់តែល្អរវាងស្ថាប័ននានា គឺមានតំរូវការចាំបាច់ ដើម្បីបន្ថយពេលដែលអ្នក ភូមិត្រូវចំណាយលើការធ្វើផែនការផ្សេង១ និងចំនួនគណៈកម្មការជាប់ទាក់ទិននឹង CBNRM ដែលឃើញមាននៅតាមភូមិ ឬឃុំនិមួយ១ ។

ផែនការ និងផែនទីគ្រប់គ្រងសហគមន៍ តែពីរមុខនេះ មិនអាចជួយអ្វីបានច្រើនទេដល់ ការកែលំអស្ថានភាពនៅមូលដ្ឋាន និងការធ្វើឱ្យតួអង្គសំខាន់១ នៅថ្នាក់ខេត្តនិងជាតិ មានការចូលពាក់ព័ន្ធ ។ គឺត្រូវមានក្របខ័ណ្ឌមួយដែលស្ថាប័ននានា និងពួកអ្នកអនុវត្តជាក់ស្តែងបានឯកភាពគ្នា, លក្ខណៈឆ្លើយតបកាន់តែប្រសើរដល់តំរូវការនៅមូលដ្ឋាន និងលក្ខណៈកាន់តែសមស្របល្អខាងវប្បធម៌ ។ ពាក្យខ្មែរ "អ្នកមានខ្នង" សំដៅដល់បុគ្គលដែលមានអ្នកមានអំណាចជួយទ្រទ្រង់ ។ រឿងនេះបង្ហាញថា ក្រៅពីត្រូវមានគោលនយោបាយគាំទ្រដល់ CBNRM ដូចជា ជលផលសហគមន៍, PLUP, ឬការបញ្ច្រាប NREM ជាដើម, មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ត្រូវដឹកនាំការងារដើម្បីធានាថា ដំណើរការទាំងនេះផ្តល់អត្ថប្រយោជន៍ពិត១ដល់អ្នកភូមិ ។ ចំពោះការអនុវត្តន៍ CBNRM ត្រូវមានមនុស្សមួយក្រុមដែលបានប្តេជ្ញាចិត្តដោះស្រាយបញ្ហា និងធ្វើការងារយ៉ាងទៀងទាត់លើបញ្ហាផ្សេង១ជាមួយដៃគូនានា ។ ហើយសំខាន់បំផុត ត្រូវមានអ្នកភូមិដែលហ៊ានប្រថុយនឹងគ្រោះថ្នាក់ និងបូជាពេលវេលា ដើម្បីអនុវត្តសកម្មភាពគ្រប់គ្រងធនធាន ។

### ឯកសារយោង

Blunt, P. (2003), "The Strategic Management of Capacity Building for Decentralisation and Deconcentration in the Kingdom of Cambodia: positioning the contribution of the

## តារាង១. កំនើន ផសស ពិតនៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | | 2003 | | | | 2004 | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | - | - | - | - | - | - | - | 5.0 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.9 | 3.8 | 3.4 | 3.8 | 3.9 | 4.3 | 4.5 | 4.1 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 5.6 | 5.4 | 4.0 | 4.4 | 3.5 | 6.4 | 7.6 | 5.3 |
| សិង្ហបុរី | 9.5 | -2.3 | 3.7 | 3.0 | 1.6 | -4.2 | 1.7 | 3.7 | 7.5 | 1.1 |
| ថៃ | 4.4 | 1.9 | 5.8 | 6.0 | 6.7 | 5.8 | 6.6 | 7.8 | 6.5 | 6.7 |
| វៀតណាម | | 6.0 | 6.7 | - | - | 6.9 | - | - | - | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.1 | 8.1 | 9.9 | 6.7 | 9.1 | 9.9 | 9.7 | 9.1 |
| ហុងកុង | 10.2 | 0.5 | 3.0 | 4.8 | 4.4 | -0.6 | 4.0 | 4.9 | 6.8 | 3.2 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 5.8 | 6.8 | 3.7 | 1.9 | 2.3 | 3.9 | 5.3 | 3.1 |
| តៃវ៉ាន់ | 5.8 | -2.2 | 4.8 | 4.2 | 3.2 | -0.4 | 4.2 | 5.4 | 6.3 | 3.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 3.5 | 1.4 | 0.8 | 1.3 | 0.8 | 0.2 | 0.3 | 0.6 | 1.5 | 0.6 |
| ជប៉ុន | 2.8 | 0.4 | 1.0 | 1.7 | 2.7 | 2.1 | 1.9 | 3.1 | 5.6 | 2.5 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 3.0 | 2.8 | 2.1 | 2.4 | 3.6 | 4.3 | 5.0 | 3.1 |

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | 2003 | | | | 2004 | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.3 | -0.4 | 3.5 | 3.0 | 1.8 | 1.6 | 0.7 | 0.5 | 0.8 | 1.5 |
| ឥណ្ឌូនេស៊ី | 3.7 | 11.3 | 10.2 | 10.3 | 7.7 | 6.5 | 5.6 | 3.7 | 4.8 | 5.8 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 2.1 | 1.9 | 1.3 | 0.9 | 1.0 | 1.1 | 0.9 | 1.0 |
| សិង្ហបុរី | 1.4 | 1.0 | -0.4 | 0.1 | 0.7 | 0.1 | 0.5 | 0.7 | 1.4 | 0.5 |
| ថៃ | 1.6 | 1.8 | 0.3 | 1.4 | 2.0 | 1.7 | 1.8 | 1.5 | 1.9 | 1.8 |
| វៀតណាម | -1.7 | 0.0 | 2.9 | 3.7 | 2.2 | 2.3 | 3.5 | 2.2 | - | 3.1 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 1.0 | -0.8 | -0.6 | 0.5 | 0.6 | 0.8 | - | - | 1.2 |
| ហុងកុង | -3.7 | -1.5 | -3.5 | -2.9 | -2.0 | -.25 | -3.7 | -2.5 | -1.2 | -2.5 |
| កូរ៉េខាងត្បូង | 2.3 | 4.3 | 2.5 | 3.2 | 4.1 | 3.3 | 3.1 | 3.5 | 3.2 | 3.5 |
| តៃវ៉ាន់ | 1.3 | -0.01 | -0.3 | -0.5 | 0.3 | -0.1 | - | - | - | -0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 2.3 | 2.6 | 2.0 | 2.3 | 2.4 | 2.0 | 2.0 | 1.9 | 1.6 | 2.1 |
| ជប៉ុន | -0.6 | -0.5 | -0.8 | -0.5 | -0.3 | - 0.2 | -0.3 | 0 | -0.1 | -0.2 |
| សហរដ្ឋអាមេរិក | 3.4 | 2.9 | 1.6 | 2.2 | 2.9 | 2.1 | 2.2 | 1.9 | 1.7 | 2.3 |

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | 2003 | | | | 2004 | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,871 | 3,935 | 3,935 | 3,948 | 3,948 | 4,008 | 4,015 | 3,999 | 3,991 | 3,992 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8,421 | 10,261 | 8,955 | 9,054 | 8,905 | 8,479 | 8,441 | 8,482 | 8,469 | 8,577 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.76 | 1.77 | 1.74 | 1.75 | 1.75 | 1.72 | 1.69 | 1.74 |
| ថៃ (បាត) | 40.1 | 44.4 | 42.01 | 43.4 | 42.7 | 42.2 | 41.3 | 39.7 | 39.1 | 41.5 |
| វៀតណាម (ដុង) | 14,168 | 14,725 | 15,324 | 15,376 | 15,426 | 15,472 | 15,522 | 15,618 | 16,208.6 | 15,510 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.27 | 8.28 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.79 | 7.75 | 7.77 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,197 | 1,219 | 1,202 | 1,207 | 1,174 | 1,182 | 1,171 | 1,192 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.8 | 34.1 | 33.8 | 34.8 | 34.7 | 35.0 | 34.2 | 34.0 | 33.4 | 34.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ (អឺរ៉ូ) | 1.08 | 1.12 | 1.02 | 1.00 | 0.93 | 0.88 | 0.88 | 0.84 | 0.79 | 0.88 |
| ជប៉ុន (យ៉េន) | 108 | 122 | 119.6 | 123.0 | 118.8 | 118.4 | 117.6 | 108.9 | 107.2 | 115.9 |

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ ២០០០-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | | 2003 | | | | 2004 | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 190.1 | 160.1 | 178.7 | 181.2 | 186.3 | 182.1 | 183.0 | 197 | 197.7 | 187.1 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 599.2 | 488.3 | 536 | 565.4 | 550.4 | 552.4 | 552.0 | 545.5 | 547.8 | 550.2 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 863 | 834.1 | 945.5 | 975.8 | 1,017.4 | 1,261.4 | 1,246.4 | 1,050 |
| អង្ករ - បាងកក ($/តោន) | 203.7 | 172.6 | 192.6 | 189.6 | 198.3 | 197.5 | 199.6 | 196 | 215.3 | 197.8 |
| សណ្តែកសៀង - សហរដ្ឋអាមេរិក ($/តោន) | 211.3 | 195.6 | 219.3 | 239.0 | 243.3 | 245.7 | 244.3 | 219.7 | 238.5 | 238.3 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 25.4 | 26.2 | 29.3 | 24.5 | 26.5 | 27 | 29.3 | 26.8 |
| មាស – London ($/troy ounce) | 279.0 | 279.0 | 313.7 | 317.8 | 352.1 | 346.7 | 363.3 | 391.9 | 408.5 | 363.5 |

*ប្រភព: តារាង ១: ទស្សនាវដ្តីThe Economist, Far Eastern Economic Review និងការិយាល័យស្ថិតិជាតិ និងធនាគារកណ្តាលនានា , តារាង ២ និង ៤: IMF និងទស្សនាវដ្តីThe Economist , តារាង ៣ : IMF , ទស្សនាវដ្តីThe Economist និងធនាគារជាតិនៃកម្ពុជា*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

កំណើនសេដ្ឋកិច្ចនៅកម្ពុជា ត្រូវបានជំរុញជាសំខាន់ដោយការនាំចេញសំលៀកបំពាក់ ទេសចរណ៍ និងសកម្មភាពសាងសង់ ។ វិស័យទេសចរណ៍បន្តកើនឡើងក្នុង ៣ត្រីមាសជាប់គ្នា ។ នៅត្រីមាសទី១ ២០០៤ ទេសចរអន្តរជាតិសរុបមាន ២៥៤.៤០០នាក់ ឬកើន ២២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ទេសចរមកតាមផ្លូវគោក និងទឹក កើន ៥៣% ដល់ ៩៦.៥០០នាក់ ដោយភាគច្រើនចូលតាមច្រកប៉ោយប៉ែត និងបាវិត ។ ក្នុងពេលជាមួយគ្នាភ្ញៀវចូលតាមផ្លូវអាកាសមានសរុប ១៥៧.៩០០នាក់ ឬ ៨%ច្រើនជាងឆ្នាំមុន, ក្នុងនេះអាកាសយានដ្ឋាននៅសៀមរាប ទទួលបាន ៧៩.៦៩៣នាក់ (កើន ១៥,៥%) ។

វិស័យសំណង់ មាននិន្នាការវិជ្ជមាននៅត្រីមាសទី១ ២០០៤ ។ គំរោងសាងសង់អនុម័តនៅភ្នំពេញមានសរុប ៧៣លានដុល្លារ (២២៥គំរោង) ឬ ៣៦% ច្រើនជាងឆ្នាំមុន ក្នុងនេះគំរោងសាងសង់ភូមិគ្រឹះ មាន ៨,១លានដុល្លារ (៥២គំរាង) ដែលជាតួលេខប្រចាំត្រីមាសខ្ពស់បំផុតគិតតាំងពីឆ្នាំ ២០០១ មក ។ ក្នុងរយៈពេលដដែល សកម្មភាពសាងសង់ផ្ទះល្វែង និងសំនង់ផ្សេងទៀត មាន ៤៨,៥លានដុល្លារ និង ១៦,៣លានដុល្លារ ធៀបនឹង ៣៤,៧លានដុល្លារ និង ១៥,១លានដុល្លាររៀងៗគ្នាកាលពីឆ្នាំមុន ។

ជញ្ជីងពាណិជ្ជកម្មកម្ពុជា បានកែលំអនៅត្រីមាសទី១ ២០០៤ គឺឱនភាពបានថយចុះអស់ ៤,៦% ធៀបនឹងឆ្នាំមុន ដោយសារការនាំចេញបានកើន ២០,៥% ដល់ ៣៩៩,៥លានដុល្លារ ក្នុងនេះការនាំចេញសំលៀកបំពាក់កើនលឿនជាងមួយនេះក៏រឹតទៀត (២២%) ។ ម្យ៉ាងទៀត ការនាំចូលរបស់កម្ពុជា ឡើងដល់ ៤៥៨,៩លានដុល្លារក្នុងត្រីមាសទី១ ២០០៤ គឺខ្ពស់ជាង ត្រីមាសដូចគ្នាឆ្នាំមុន ១៦,៥% ហើយកត្តាចំបងគឺ កំណើនការនាំចូលយាន ជំនិះ ៩២% និងប្រេងម៉ាស៊ូត ២១% ។ គួរកត់សំគាល់ថា ការនាំចូលសាំង ថយចុះយ៉ាងខ្លាំងអស់ ២២,២% បើគិតលើមូលដ្ឋានប្រចាំត្រីមាស ឬធ្លាក់ចុះ ៣២,៦% បើគិតប្រចាំឆ្នាំ ។

វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តនៅត្រីមាសទី១ ២០០៤ មានសរុប ៦៣,៣លានដុល្លារ ធៀបនឹង ១០៨,៥លានដុល្លារនៅត្រីមាសទី១ឆ្នាំមុន ។ រឿងនេះជាប់ទាក់ទងនឹងវិនិយោគដ៏តិចតួចបំផុតខាងកសិកម្ម និងការធ្លាក់ចុះជិត ៩០% ខាងវិស័យសេវាកម្ម ជាពិសេសអវត្តមានវិនិយោគខាងផ្នែកសណ្ឋាគារនៅត្រីមាសទី១ ២០០៤ ។ បើសិនគំរោងអនុម័ត និងការវិនិយោគជាក់ស្តែង វាជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ដូច្នេះការធ្លាក់ចុះគួរកត់សំគាល់ដូចខាងលើ នឹងមានផលប៉ះពាល់អវិជ្ជមានទៅលើការលូតលាស់ក្នុងអនាគត ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ២០០៤ ប្រតិបត្តិការថវិកាជាតិកម្ពុជាមានឱនភាពសរុបត្រឹម ១២៣,២ពាន់លានរៀល ឬថយចុះប្រហែល ៤៤% ធៀបនឹងឆ្នាំមុន ។ ចំនូលសរុបកើនដល់ ៥២៤ពាន់លានរៀល ធៀបនឹង ៤២៨,១ពាន់លានរៀល នៅត្រីមាសទី១ ២០០៣, ដែលឆ្លុះបញ្ចាំងពីកំណើន ៣១% ក្នុងចំណូលចរន្ត និងដែលហាក់ដូចជាលទ្ធផលនៃកំណែទំរង់ពន្ធដារ ដោយក្នុងនេះការប្រមូលអាករលើតំលៃបន្ថែមកើន ៤២,២% ពន្ធគយកើន ៤៨% និងអាករពិសេសកើន ៦៩% ។ កំនើនទាំងនេះមួយចំនែកត្រូវយកទៅប៉ះប៉ូវការថយចុះចំនូលមិនមែនពន្ធ (ជាង ១០%) ដែលទាក់ទងជាសំខាន់នឹងប្រាក់កំរៃលើអាជ្ញាប័ណ្ណនិងកូតានាំចេញ ព្រមទាំងប្រាក់ចំនូលពីប្រៃសនីយ៍និងទូរគមនាគមន៍ ។

ខាងផ្នែកថវិកាចំណាយ ក្នុងនេះមានទាំងចំណាយកែតំរូវផង នៅត្រីមាសទី១ ២០០៤ វាមានសរុប ៦៤៧,១ពាន់លានរៀល ដែលមិនសូវមានការប្រែប្រួលទេបើធៀបនឹងកាលពីមួយឆ្នាំមុន ។ ចំណាយចរន្តបានថយចុះគួរកត់សំគាល់ (ប្រហែល ២៧%) ក្នុងនេះចំណាយរដ្ឋបាលទូទៅថយចុះ ៦១,៦% បន្ទាប់មកគឺ ចំណាយខាងសន្តិសុខ និងការពារជាតិដែលថយចុះអស់ ៣% ។ ចំណាយមូលធនកើន ៨,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនេះ ចំណាយមូលនិធិផ្តល់ពីបរទេសមាន ៧៧% នៃតួលេខសរុប ។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

ទោះបីថ្លៃថាមពលកើនឡើងគួរកត់សំគាល់ក្តី ប៉ុន្តែសន្ទស្សន៍ថ្លៃនៅភ្នំពេញកើនតិចតួចត្រឹម ០,៨% នៅត្រីមាសទី១ ២០០៤ បើធៀបនឹងត្រីមាសទី១ ២០០៣ ។ ថ្លៃម្ហូបអាហារកើន ០,៦% រីឯថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍កើន ៤,៨% ។

តំលៃប្រាក់រៀលសឹងតែគ្មានការប្រែប្រួលទល់នឹងដុល្លារ ដោយប្តូរបាន ៣.៩៩១រៀល/ដុល្លារនៅត្រីមាសទី១ ២០០៤ ធៀបនឹង ៣.៩៤៨រៀល/ដុល្លារនៅត្រីមាសទី១ ២០០៣ ។ ក្នុងរយៈពេលដូចគ្នា ប្រាក់រៀលធ្លាក់ថ្លៃគួរកត់សំគាល់ទល់នឹងប្រាក់បាត (១០,៣%) ហើយធៀបនឹងប្រាក់ដុងវាប្តូរបាន ២៤,៦រៀល/១០០ដុង (ដែលជាកំរិតខ្ពស់បំផុតក្នុងរយៈ ១០ត្រីមាសចុងក្រោយ និងជាការឡើងថ្លៃ ៤% បើធៀបនឹងឆ្នាំមុន) ។

## ការវិវត្តន៍រូបិយវត្ថុ

យោងតាមធនាគារជាតិនៃកម្ពុជា សាច់ប្រាក់សរុបមាន ៣.៦៥៩ពាន់លានរៀល (៩១៧លានដុល្លារ) នៅចុងត្រីមាសទី១ ២០០៤ ដោយបានកើន ឡើងតាមអត្រាប្រចាំឆ្នាំ ២២% ។ តួលេខនេះឆ្លុះបញ្ចាំងពីកំណើនទាំងប្រាក់ បញ្ញើជារៀល និងជារូបិយប័ណ្ណៈ ២១% ជារៀល (ឡើងដល់ ១.០៩៥ពាន់លានរៀល) និង ២០,៦%ជារូបិយប័ណ្ណ (៦៤២,៥លានដុល្លារ) ។ ក្នុងកំនើន ប្រាក់រៀលនៅត្រីមាសទី១ ២០០៤ គឺមានកំណើនសាច់ប្រាក់នៅក្រៅធនាគារ ២៤% និងកំណើនប្រាក់បញ្ញើជាប្រភេទសន្សំ និងមានកាលកំណត់ ១៨% ។ នៅត្រីមាសទី១ ២០០៤ រូបិយវត្ថុទូទៅ កើន ១០% ធៀបនឹងត្រីមាសមុន ដោយសារកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណជាសំខាន់ (១០,៧%) ។

## វិនិយោគឯកជន និងការងារ

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុវត្តគោលនយោបាយវិនិយោគធូរទូលាយជាងមុន ក្នុងគោលដៅលើកទឹកចិត្ត ទាំងអ្នកវិនិយោគក្នុងស្រុក និងបរទេស ។ ក្នុងនេះគឺមានការបង្កើនរយៈពេលផ្តល់អាជ្ញាប័ណ្ណពី ៦ខែ ទៅ ១ឆ្នាំ (នេះជារយៈពេលត្រូវអនុវត្តគំរោងដែលបានទទួលការអនុមតិ បើមិនដូច្នោះទេអាជ្ញាប័ណ្ណនឹងត្រូវលុបចោលវិញ) ។ ទោះយ៉ាងនេះក្តី គំរោងដែលបានអនុម័តជាក់ស្តែង បានថយចុះជិត ៤២% នៅត្រីមាសទី១ ២០០៤ បើធៀបនឹងត្រីមាសទី១ ២០០៣ ។ ចំណុចគួរភ្ញាក់ផ្អើលមួយគឺ គំរោងបានអនុម័តសំរាប់ឧស្សាហកម្មកាត់ដេរបានកើនយ៉ាងច្រើនក្នុងរយៈពេលនេះ (ពី ៦,៥លានដុល្លារ ដល់ជិត ៥០លានដុល្លារ) ទោះបីមានការបារម្ភអំពីការដក

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ចេញនូវកិច្ចព្រមព្រៀងលើក្រណាត់គ្រប់មុខ (Multi-Fiber Agreement: MFA) នៅចុងឆ្នាំក្តី ហើយនេះជាសញ្ញាមួយដែលផ្តល់ការលើកទឹកចិត្ត ។

**ស្ថានភាពក្រីក្រ_និងប្រាក់ចំណូលរបស់ពលករងាយរងគ្រោះ**

ការកាត់បន្ថយភាពក្រីក្រគឺជា អាទិភាពចំបងរបស់រដ្ឋាភិបាលកម្ពុជា ។ ដើម្បីឃ្លាំមើលពីការប្រែប្រួលក្នុងជីវភាពប្រចាំថ្ងៃរបស់កម្មករងាយរងគ្រោះ វិបសអ បានធ្វើអង្កេតប្រចាំត្រីមាសតាំងពីឆ្នាំ១៩៩៨មក ដោយផ្តោតលើចំណូលប្រចាំថ្ងៃនៅក្រុងភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ជាសំខាន់ ។

នៅខែឧសភា ២០០៤ ប្រាក់ចំណូលចារិកប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះគ្រប់ក្រុមកើន ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ក្នុងចំណោម ១០ក្រុមពលករ មាន ៨ក្រុមកើនចំណូល រីឯ ២ក្រុមទៀតបានថយចំណូល (តារាង៨) ។ ប៉ុន្តែបើធៀបនឹងខែកុម្ភៈ ២០០៤ មានតែ២ក្រុមទេដែលកើនចំណូលមធ្យមប្រចាំថ្ងៃ គឺមានកម្មកររោងចក្រកាត់ដេរ និងអ្នកលក់បន្លែតូចតាច ។

សាំងឡើងថ្លៃយ៉ាងខ្លាំង (១២%) នៅខែឧសភា ២០០៤ ដល់ ២.៨៥០ រៀល/លីត្រធៀបនឹង ២.៥៥០រៀល/លីត្រ នៅខែកុម្ភៈ ២០០៤ ។ ការឡើងថ្លៃនេះ បានប៉ះពាល់យ៉ាងខ្លាំងលើពលករងាយរងគ្រោះ ជាពិ-សេសអ្នករត់ម៉ូតូឌុប ។ លទ្ធផលអង្កេតបង្ហាញថាមានតែអ្នករត់ម៉ូតូឌុប ៥% ប៉ុណ្ណោះ ដែលគិតថា ចំណូលមធ្យមប្រចាំថ្ងៃរបស់ខ្លួនបានកើនឡើង រីឯ ៧២% ទៀត អះអាងថា ចំណូលរបស់ខ្លួនថយចុះ ។

ចំណូលប្រចាំថ្ងៃជាមធ្យមរបស់កម្មករសំណង់គ្មានជំនាញ បានធ្លាក់ចុះ ៣% ក្នុងរយៈមួយឆ្នាំមកដល់ចុងខែ ឧសភា ២០០៤ ។ម្យ៉ាងទៀត ៨០%នៃកម្មករសំណង់គ្មានជំនាញបានរាយការណ៍ពីកំណើនចំនួនកម្មករបើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ផ្ទុយទៅវិញ កម្មករសំណង់មានជំនាញរកចំណូលបានច្រើនបំផុតក្នុងចំណោមពលករទាំង ១០ក្រុម ដោយចំណូលប្រចាំថ្ងៃជាមធ្យមបានកើនឡើង ៣% ស្របទៅតាមតំរូវការកាន់តែធំនៃឧស្សាហកម្មសាងសង់ ។ កម្មករសំណង់មានជំនាញ ៩០% គិតថាតំរូវការបានកើនឡើង ហើយ ៩៧% ប្រាប់ថា ចំណូលប្រចាំថ្ងៃរបស់គាត់គឺជាប្រភពចំបងនៃប្រាក់ចំណូលសំរាប់គ្រួសារគាត់ ហើយប្រាក់សន្សំរបស់គាត់មិនគ្រប់គ្រាន់ទេសំរាប់ចាប់ផ្តើមអាជីវកម្មថ្មី ។ ក្នុងគំរូតាងកម្មករសំណង់មានជំនាញភាគច្រើន (៨០%) ជាអ្នកមកពីខេត្ត ។

ចំណូលប្រចាំថ្ងៃជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរ បានកើន ៧% នៅខែឧសភា ២០០៤ បើធៀបនឹងខែឧសភា ២០០៣ តែស្ថិតក្នុងកំរិតស្មើគ្នានឹងខែឧសភា ២០០២ ។ ប្រហែល ៨០% នៃកម្មកររោងចក្រកាត់ដេរ (១០ រោងចក្រ) បានរាយការណ៍ពីកំណើនសកម្មភាព បើធៀបនឹងបីខែកន្លងទៅ និងមាន ៧៧% បានរាយការណ៍ថា មានម៉ោងបន្ថែមច្រើនជាងពីមុន ។ អង្កេតធ្វើនៅខែឧសភា ២០០៤ បង្ហាញថា កម្មកររោងចក្រកាត់ដេរជាទូទៅចំណាយ ២៦ដុល្លារ/ខែ ក្នុងនេះមានជាអាទិ៍ចំនាយលើម្ហូបអាហារ ការស្នាក់នៅ និងការធ្វើដំណើរ ។

ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នករើសអេតចាយ អ្នកបំរើតាមភោជនីយដ្ឋាន និងអ្នកស៊ីឈ្នួលធ្វើស្រែ បានប្រហែល ៤.៤០០រៀល/នាក់ នៅខែឧសភា ២០០៤ ។ បើធៀបនឹងខែឧសភា ២០០៣ ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ក្រុមទាំងនេះបានកើន ២៧%, ១៦%, និង ៣% រៀងៗគ្នា ។ អង្កេតរក ឃើញទៀតថា ៦០% នៃអ្នករើសអេតចាយ និងអ្នកស៊ីឈ្នួលធ្វើស្រែ បានខ្ចី ប្រាក់ដោយមានអត្រាការប្រាក់ខ្ពស់ ។ អង្កេតបង្ហាញថា អ្នកស៊ីឈ្នួលធ្វើស្រែ ៩២% គ្មានដីធ្លីទេ ហើ-យពឹងផ្អែកជាសំខាន់លើពលកម្មរបស់ខ្លួនផ្ទាល់ ។

ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកលក់បន្លែតូចតាច បានកើន ២៣% នៅខែឧសភា ២០០៤ ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ពួកគេបានរាយការណ៍ថា មានការឡើងថ្លៃទំនិញក្នុងរយៈ ៣ខែកន្លងទៅ ហើយប្រហែល ៥០% បានខ្ចី

---

*តពីទំព័រទី ៤* **តើប័ណ្ណសំគាល់...**

នឹងមានកំនើនភាគរយនៃការផ្ទេរដីតាមរយៈប្រព័ន្ធចុះបញ្ជី ជាពិសេសនៅក្នុងទីផ្សារដីធ្លីដែលមានសកម្មភាព និងដែលមានដីកំពុងឡើងថ្លៃ ។ ការរំពឹងបែបនេះផ្អែកលើការសន្មតថាៈ (១) ចំណាយចុះបញ្ជីនូវការទិញ/លក់ដី នឹងចុះទាបជាងសព្វថ្ងៃ, (២) ប្រជាជនកាន់តែមានទំនុកចិត្តទៅលើសន្តិសុខនៃការកាន់កាប់ដី, និង (៣) ប្រជាជននឹងមានចំណេះដឹង/សមត្ថភាពគ្រប់គ្រាន់ដើម្បីប្រើប្រាស់ប្រព័ន្ធនេះ ។

**សេចក្តីសន្និដ្ឋាន**

សិទ្ធិកាន់កាប់ដីធ្លីមានសុវត្ថិភាព វាអាចរួមចំនែកបានកំរិតណាដល់កំនើនសេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅជនបទ គឺត្រូវពឹងផ្អែកភាគច្រើនទៅលើសមត្ថភាពរដ្ឋបាលសាធារណៈដើម្បីគ្រប់គ្រង និងពង្រឹងកម្មសិទ្ធិដីធ្លី ។ ផលប៉ះពាល់នៃប័ណ្ណសំគាល់កម្មសិទ្ធិ ហាក់ដូចបានខ្លាំងក្លាបំផុតនៅពេលប្រជាជនជឿជាក់លើសមត្ថភាព និងការប្តេជ្ញារបស់រដ្ឋាភិបាលដើម្បីពង្រឹងសិទ្ធិកាន់កាប់ដីធ្លី ទៅតាមបែបបទមួយដែលមានយុត្តិធម៌ និងតំលាភាព ។ ប្រជាជនក្នុងតំបន់អង្កេតមូលដ្ឋាន បានបញ្ចេញពីទំនុកចិត្តយ៉ាងច្រើនតាំងពីដំបូងទៅលើប័ណ្ណសំគាល់កម្មសិទ្ធិដែល LMAP កំពុងចេញឱ្យ ។

អត្ថប្រយោជន៍នៃប័ណ្ណសំគាល់កម្មសិទ្ធិ ក៏ជាប់ទាក់ទងផងដែរទៅនឹងកាលៈទេសៈនៅក្នុងមូលដ្ឋាន ជាអាទិ៍ (ក) កំរិតសកម្មភាពទីផ្សារដីធ្លី, (ខ) លទ្ធភាពមានសេវាខាង ឥណទាន ផ្សព្វផ្សាយបច្ចេកទេស ថែទាំសុខភាព និងសេវាសង្គមកិច្ចផ្សេងទៀត, (គ) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង (ឃ) ទីតាំងនៅជិតកន្លែងដឹកជញ្ជូន និងទីផ្សារ ។ គ្រួសារនានា និងសង្គមអាចទទួលបានអត្ថប្រយោជន៍ច្រើនបំផុត នៅតាមតំបន់ដែលមានទីផ្សារដីធ្លីសកម្ម និងងាយស្រួលទទួលបានសេវាអភិវឌ្ឍន៍ ។ ការរួមចំណែកនៃប័ណ្ណសំគាល់កម្មសិទ្ធិចំពោះការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ អាចបាន លទ្ធផលប្រសើរបំផុតតាមរយៈការផ្តោតកិច្ចប្រឹងប្រែងចេញប័ណ្ណសំគាល់កម្មសិទ្ធិទៅលើតំបន់ដែលរដ្ឋាភិបាល NGOs អ្នកផ្តល់ជំនួយផ្សេងទៀត និងវិនិយោគិនឯកជន មានសកម្មភាពខ្លាំង ។

ផលប្រយោជន៍នៃប័ណ្ណសំគាល់កម្មសិទ្ធិក៏ទាក់ទងនឹងលក្ខណៈគ្រួសារដែរ ។ ទំហំដីនិងភេទនៃមេគ្រួសារ គឺជាអាំងឌីកាទ័រដ៏ល្អបង្ហាញពីសក្តានុពលរបស់គ្រួសារ ដើម្បីទទួលបានអត្ថប្រយោជន៍ពីគំរោងចេញប័ណ្ណសំគាល់កម្មសិទ្ធិ ។ យើងរំពឹងថា គ្រួសារមានដីកាន់កាប់តូចៗ រួមទាំងគ្រួសារស្រ្តីជា មេគ្រួផង អាចបានអត្ថប្រយោជន៍ពីការកាន់កាប់ដីមានសុវត្ថិភាពនៅក្នុងកាលៈទេសៈមានអំណោយផល ។ ប៉ុន្តែគ្រួសារមានដីកាន់កាប់ធំៗ គេមានស្ថានភាពពីដើមទីកាន់តែល្អ ដើម្បីទទួលបានអត្ថប្រយោជន៍ច្រើនៗ ។ អត្ថប្រយោជន៍សំរាប់គ្រួសារចាញ់ប្រៀប និងងាយរងគ្រោះ អាចបង្កើនឡើងបានដោយកំណត់យកតំបន់គោលដៅជាក់លាក់មួយចំនួន ហើយផ្តោតធនធាន

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 Q4 | 2003 Q1 | Q2 | Q3 | Q4 | 2004 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនគំរោងវិនិយោគ | | | | | | | | | | | |
| សរុប | 300 | 136 | 140 | 96 | 96 | 188 | 8 | 20 | 14 | 17 | 15 | 15 |
| កាត់ដេរ | 144 | 48 | 84 | 44 | 52 | 76 | 2 | 6 | 7 | 12 | 6 | 11 |
| | មូលធនបានចុះបញ្ជី (លានដុល្លារ) | | | | | | | | | | | |
| សរុប | 391.2 | 278 | 416.4 | 246.8 | 102.4 | 129.2 | 20.3 | 41.6 | 10.4 | 4.0 | 15.4 | 11.9 |
| កាត់ដេរ | 156.8 | 34.4 | 91.6 | 55.6 | 25.6 | 60 | 1 | 5 | 4.1 | 1.0 | 5.8 | 8.4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| សរុប | 746.8 | 761.6 | 849.2 | 474 | 266.4 | 217.2 | 60.9 | 108.5 | 48.3 | 95.1 | 62.1 | 63.3 |
| កាត់ដេរ | 158.4 | 38.8 | 120.8 | 79.6 | 76.8 | 100 | 1.7 | 6.5 | 10.5 | 43.3 | 14.5 | 49.9 |

*ប្រភពៈ ក្រុមប្រឹក្សាវិនិយោគកម្ពុជា (១៩៩៥-២០០៣) ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

## តារាង២. គំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 Q4 | 2003 Q1 | Q2 | Q3 | Q4 | 2004 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ភូមិគ្រឹះ | 205 | 179 | 143 | 136 | 111 | 108 | 40 | 29 | 39 | 25 | 48 | 52 |
| ផ្ទះល្វែង | 537 | 528 | 678 | 864 | 520 | 499 | 123 | 125 | 104 | 148 | 116 | 157 |
| ផ្សេងៗ | 116 | 117 | 132 | 74 | 64 | 57 | 14 | 21 | 23 | 17 | 22 | 20 |
| សរុប | 858 | 824 | 953 | 1074 | 695 | 664 | 177 | 175 | 166 | 190 | 186 | 229 |

*ប្រភពៈ នាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រុងភ្នំពេញ ។*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 Q4 | 2003 Q1 | Q2 | Q3 | Q4 | 2004 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 387.1 | 493.4 | 784.4 | 941.1 | 1055.5 | 1267.0 | 412.9 | 331.5 | 408.5 | 492.3 | 475.7 | 399.5 |
| រួមមានៈ - សំលៀកបំពាក់ | 78.8 | 227.2 | 378 | 554 | 962.1 | 1201.0 | 385.4 | 314.7 | 389.9 | 475.2 | 448.5 | 383.6 |
| ទៅសហរដ្ឋអាមេរិក | 0.4 | 107.2 | 74.1 | 486 | 714.1 | 840.9 | 269.2 | 230.6 | 267.8 | 303.2 | 298.2 | 255.8 |
| ប្រទេសផ្សេងទៀត | 78.4 | 120 | 82 | 68 | 248.0 | 360.1 | 116.2 | 84.1 | 122.1 | 172.0 | 150.3 | 127.8 |
| - កសិកម្ម | - | - | - | - | 90.5 | 66.0 | 27.4 | 16.8 | 18.7 | 17.0 | 27.2 | 16.0 |
| កៅស៊ូ | - | - | - | - | 29.6 | 25.9 | 9.1 | 6.3 | 6.7 | 10.0 | 12.1 | 8.0 |
| ឈើ | - | - | - | - | 32.5 | 22.3 | 3.3 | 2.8 | 2.8 | 2.1 | 2.4 | 1.8 |
| ជលផល | - | - | - | - | 5.4 | 6.0 | 0.5 | 0.8 | 0.7 | 0.6 | 0.7 | 0.8 |
| ផ្សេងៗ | - | - | - | - | 26.0 | 11.8 | 14.5 | 6.9 | 8.5 | 4.3 | 12.0 | 5.4 |
| ការនាំចូលសរុប | 1114.4 | 1094.5 | 1112.2 | 1237.4 | 1417.7 | 1501.4 | 438.7 | 393.8 | 507.3 | 436.2 | 497 | 458.9 |
| រួមមានៈ - សាំង | - | - | - | - | - | - | 7.6 | 10.4 | 8.0 | 5.6 | 9.0 | 7.0 |
| - ម៉ាស៊ូត | - | - | - | - | - | - | 23.3 | 25.0 | 33.4 | 25.1 | 24.4 | 30.2 |
| - សំភារៈសំណង់ | - | - | - | - | - | - | 2.9 | 2.8 | 3.4 | 2.4 | 3.5 | 3.0 |
| - ផ្សេងៗ | - | - | - | - | - | - | 404.9 | 355.6 | 462.5 | 403.1 | 460 | 418.7 |
| ជញ្ជីងពាណិជ្ជកម្ម | -727.3 | -601.2 | -327.8 | -296.3 | -362.2 | -234.0 | -25.8 | -62.3 | -98.8 | 56.1 | -21.3 | -59.4 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 198 | 188 | 66 | 47 | 74 | 24.8 | 33.2 | 26.3 | 34.7 | 10.1 | 16.4 | 21.9 |
| ការនាំចេញសរុប | 2.1 | 27.5 | 58.9 | 12.4 | 19.7 | 20 | 35.3 | 20.7 | 30.0 | 9.0 | 15.2 | 20.5 |
| ការនាំចូលសរុប | 1.2 | -1.8 | 1.6 | 11.3 | 14.5 | 5.9 | 27 | 22 | 7.8 | -10.0 | 19.6 | 16.5 |

*ប្រភពៈ ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ទីចាត់ការគយ និងរដ្ឋាករ, រួមទាំង ការលើកលែងពន្ធ ។*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៦-២០០៣

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 Q4 | 2003 Q1 | Q2 | Q3 | Q4 | 2004 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| ទិដ្ឋាការទេសចរ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 58.7 | 183.7 | 83.8 | 132.0 | 209.1 | 230.7 |
| តាមយន្តហោះ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 58.7 | 124.6 | 44.4 | 76.2 | 131.3 | 139.6 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 59.1 | 39.4 | 55.8 | 77.7 | 91.1 |
| ទិដ្ឋាការជំនួញ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 16.1 | 20.4 | 14.7 | 20.3 | 15.5 | 15.8 |
| តាមយន្តហោះ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 16.1 | 17.2 | 11.2 | 16.3 | 15.5 | 11.5 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 3.2 | 3.5 | 4.0 | - | 4.3 |
| ទិដ្ឋាការរដ្ឋការ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 92.9 | 4.7 | 4.6 | 5.9 | 6.1 | 7.9 |
| តាមយន្តហោះ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 92.9 | 4.0 | 4.0 | 5.1 | 6.1 | 6.8 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 0.7 | 0.6 | 0.8 | - | 1.1 |
| សរុបតាមអាកាស | | | 186.3 | 262.9 | 351.7 | 408.4 | 167.7 | 145.8 | 59.6 | 97.6 | 152.9 | 157.9 |
| សរុបតាមផ្លូវគោក និងទឹក | - | - | 100..2 | 104.8 | 114.7 | 196.5 | 69.6 | 63 | 43.5 | 60.6 | 77.7 | 96.5 |
| សរុបអ្នកដំណើរ | 260.4 | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 237.3 | 208.8 | 103.1 | 158.2 | 230.6 | 254.4 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុបអ្នកដំណើរ | 18.5 | -15.9 | 30.9 | 28.3 | 26.8 | 29.7 | 41.3 | -0.9 | -37.4 | -8.9 | -14.2 | 21.8 |

*ប្រភពៈ ក្រសួងទេសចរណ៍ ។*

## តារាង៥. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៦-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | |
| ខេត្ត | - | 6.1 | 16.3 | 6.2 | 5.4 | 0.9 | -0.3 | 7.4 | 5.9 | -1.9 | 1.8 | 4.6 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 7.1 | 8.0 | 14.8 | 4.0 | -0.8 | -0.6 | 3.04 | 1.8 | 1.6 | 0.8 | 0.5 | 0.8 |
| - ម្ហូបអាហារ | 7.6 | 6.7 | 14.1 | 7.6 | -3.3 | -2.8 | 2.00 | 3.20 | 2.3 | 1.5 | -0.04 | 0.6 |
| - ឋាមពល | 20.7 | 20.0 | 15.1 | 3.5 | 6.6 | -1.1 | 2.25 | 4.75 | 5.2 | 5.1 | 5.1 | 4.8 |
| | | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | |
| រៀលក្នុង ១ ដុល្លារ | 2,666 | 3,029 | 3,824 | 3,832 | 3,879 | 3,935 | 3,948 | 3,948 | 4,008 | 4,015 | 3,999 | 3,991 |
| រៀលក្នុង ១ បាតថៃ | 105 | 98 | 88 | 101 | 96.3 | 88 | 90.9 | 92.4 | 94.9 | 96.9 | 100.5 | 101.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.0 | 25.6 | 28.6 | 27.8 | 27.4 | 26.6 | 25.8 | 25.6 | 25.9 | 24.9 | 24.8 | 24.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 34.0 | 33.3 | 32.7 | 38.5 | 39.8 | 40.0 | 41.5 | 44.4 | 46.0 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,550 | 1,697 | 1,683 | 1,683 | 1,700 | 1,867 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,200 | 2,433 | 2,383 | 2,367 | 2,400 | 2,567 |

## តារាង៦. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៦-២០០៤ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 881 | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,737 | 3,741 | 3,594 | 3,627 | 4,027 | 4,265 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 31 | -114 | -496 | -576 | -759 | -876 | -849 | -737 | -641 | -621 | -698 | -606 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 128 | 54 | 178 | 103 | 3 | -75 | -119 | -72 | -19 | 18 | -128 | -133 |
| ឥណទានចំពោះផ្នែកឯកជន | 435 | 637 | 655 | 763 | 898 | 936 | 1,059 | 1,125 | 1,224 | 1,287 | 1,337 | 1,389 |
| រូបិយវត្ថុទូទៅ M2 | 912 | 1,063 | 1,230 | 1,443 | 1,831 | 2.204 | 2,888 | 3,004 | 2,953 | 3,007 | 3,328 | 3,659 |
| រូបិយវត្ថុ M1 | 329 | 385 | 543 | 531 | 540 | 609 | 813 | 829 | 871 | 886 | 937 | 1007 |
| រូបិយវត្ថុផ្សេងៗ | 583 | 678 | 687 | 911 | 1,291 | 1,594 | 2,075 | 2,175 | 2,,082 | 2,120 | 2,391 | 2,652 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 40.3 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 24.1 | 24.6 | 11.5 | 9.3 | 15.2 | 21.8 |
| រូបិយវត្ថុ M1 | 18.3 | 17 | 41 | -2.2 | 1.7 | 12.8 | 33.4 | 22.6 | 16.4 | 14.9 | 15.3 | 21.5 |
| រូបិយវត្ថុផ្សេងៗ | 57.1 | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 25.7 | 9.5 | 7.1 | 15.2 | 21.9 |

## តារាង៧. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៦-២០០៤ (ពាន់លានរៀល)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q4* | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 748 | 880 | 920 | 1326 | 1528 | 1529 | 495.9 | 428.1 | 379 | 400.5 | 506 | 523.9 |
| ចំណូលចរន្ត | - | - | - | - | - | 1521 | 495.9 | 400 | 377 | 399.2 | 506 | 523.3 |
| ចំណូលពន្ធ | 536 | 596 | 676 | 956 | 1096 | 1096 | 350.1 | 273 | 287 | 273.1 | 349.1 | 409.3 |
| ពន្ធគយ | 344 | 348 | 376 | 432 | 376 | 376 | 122.5 | 92 | 94 | 91.6 | 117.4 | 137 |
| ចំណូលមិនមែនពន្ធ | 176 | 272 | 204 | 348 | 424 | 424 | 145.8 | 127 | 90 | 126.2 | 156.8 | 113.9 |
| អាជីវកម្មព្រៃឈើ | 28 | 36 | 20 | 36 | 28 | 29 | 4.7 | 1 | 1 | 4.5 | 0.5 | 0.9 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 64 | 84 | 88 | 108 | 124 | 122 | 44.8 | 19 | 18 | 33.5 | 44.3 | 16.1 |
| ចំណូលជាមូលធន | 40 | 12 | 36 | 12 | 8 | 9 | 0.0 | 28.4 | 2 | 1.3 | 0.0 | 0.6 |
| ចំណាយសរុប | 1440 | 1260 | 1296 | 1792 | 2332 | 2332 | 864.9 | 647.5 | 660 | 661.6 | 582.4 | 647.1 |
| ចំណាយជាមូលធន | 628 | 452 | 368 | 624 | 976 | 977 | 440.1 | 272.3 | 271 | 279.6 | 205.1 | 295.6 |
| ចំណាយចរន្ត | 812 | 808 | 980 | 1164 | 1356 | 1355 | 424.8 | 375.3 | 388 | 381.9 | 377.3 | 351.5 |
| អប់រំ និងសុខាភិបាល | 124 | 128 | 132 | 280 | 344 | 343 | 227.7 | 36 | 88 | 122.4 | 128.4 | 31.4 |
| ការពារជាតិ និងសន្តិសុខ | 408 | 420 | 448 | 464 | 404 | 405 | 163.9 | 70 | 119 | 75.4 | 110.1 | 67.6 |
| ក្រសួងផ្សេងៗទៀត | 284 | 260 | 332 | 412 | 636 | 637 | 33.1 | 279 | 182 | 214 | 138.8 | 252.6 |
| ឱនភាពជាទូទៅ | -692 | -380 | -380 | -476 | -804 | -803 | -369 | -219.4 | -281 | -261 | -76.5 | -123.2 |
| ហិរញ្ញប្បទានក្រៅប្រទេស | 680 | 444 | 268 | 416 | 768 | 766 | 333.3 | 119 | 201 | 230 | 244.8 | -223 |
| ហិរញ្ញប្បទានក្នុងស្រុក | 12 | -64 | 112 | 60 | 36 | 37 | 35.7 | 100.4 | 80 | 31 | -168.3 | 99.8 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះ ឆ្នាំ១៩៩៧-២០០៤

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1997 | 2001 | 2002 | 2003 | | | | 2004 | | 2003 | 2004 | |
| | មុនកក្កដា | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ ០៤ | ឧសភា ០៤ | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 12,250 | 6,262 | 8,878 | 9,200 | 7,000 | 9,380 | 9,817 | 9,500 | 8,425 | 10.58 | 3.26 | 20.36 |
| អ្នកលីសែង | 9,675 | 5,000 | 6,312 | 7,600 | 6,225 | 7,240 | 6,500 | 8,700 | 7,847 | 2.98 | 14.47 | 26.06 |
| អ្នកលក់បន្លែតូចតាច | 7,050 | 5,096 | 7,158 | 7,250 | 6,162 | 6,860 | 6,700 | 7,400 | 7,625 | -6.40 | 2.07 | 23.74 |
| អ្នករើសអេតចាយ | 4,155 | 3,393 | 4,012 | 3,875 | 3,605 | 4,900 | 3,900 | 4,800 | 4,600 | -2.79 | 23.87 | 27.60 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | – | 2,358 | 4,000 | 4,600 | 4,380 | 4,520 | 4,435 | 4,900 | 4,500 | 10.88 | 6.52 | 2.74 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | 3,618 | 4,219 | 4,180 | 3,712 | 4,600 | 4,450 | 4,700 | 4,300 | 5.48 | 12.44 | 15.84 |
| កម្មកររោងចក្រកាត់ដេរ | – | 8,968 | 10000 | 10,127 | 9,123 | 10,300 | 10000 | 9,675 | 9,740 | 0.0 | -4.46 | 6.76 |
| អ្នករត់ម៉ូតូឌុប | – | 9,791 | 12,075 | 11,400 | 9372 | 10900 | 10000 | 11,200 | 9,000 | -17.18 | -1.75 | -3.97 |
| កម្មករសំណង់គ្មានជំនាញ | – | 4,841 | 5,850 | 6,162 | 7100 | 7600 | 6200 | 7,200 | 6,900 | 5.98 | 16.85 | -3.16 |
| កម្មករសំណង់មានជំនាញ | – | 9,866 | 13,350 | 12,500 | 12,050 | 12,700 | 16,900 | 13,800 | 12,450 | 26.59 | 10.40 | 3.32 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នកម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ *ចំនួនអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្តល់ឱ្យទេ ។ ប្រភព: តារាង៥: វិបសអ, IMF, NIS ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: ធនាគារជាតិនៃកម្ពុជា Q4* 2003 បានកែតំរូវ / តារាង៧: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, Q4* 2002 បានកែតំរូវ, ២០០៣ និង Q1 2004 ជាតួលេខបណ្តោះអាសន្ន / តារាង៨: វិបសអ ។*

*តពីទំព័រទី ៧* **សមាគមវត្តអារាម...**

### *៣.៤ ការកសាងសមត្ថភាព*

សព្វថ្ងៃ ការគាំទ្រដល់សមាគមតាមវត្តនៅស្រុកស្ទោង ពីសំណាក់ផ្នែកសង្គមស៊ីវិលរបស់អង្គការ GTZ ផ្តោតលើការពង្រឹងតួនាទីរបស់សមាគមក្នុងឋានៈជាអ្នកតំណាងឱ្យសហគមន៍នៅក្នុងកិច្ចការអភិបាលកិច្ចនៅមូលដ្ឋាន ដូចជា ការពន្យល់ពីសារៈសំខាន់នៃការចូលរួមក្នុងការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ ការបង្ហាញពីលទ្ធផលសកម្មភាពឥណទានរបស់សមាគម និងការអញ្ជើញសមាជិកក្រុមប្រឹក្សាឃុំ ឱ្យមកពិនិត្យសង្កេតសកម្មភាពសមាគម ។ ក្នុងឆ្នាំ២០០៣ សមាជិក Pacoco បានទទួលការបណ្តុះបណ្តាល ដើម្បីបានយល់ច្បាស់ពីនិយមន័យ និងគោលគំនិតនៃវិមជ្ឈការ និងទទួលបានការយល់ដឹងខាងទ្រឹស្តី ដែលនឹងត្រូវយកមកដាក់អនុវត្តក្នុងការងារប្រចាំថ្ងៃ ។ ការវាយតំលៃមួយធ្វើនៅឆ្នាំ២០០៣ បានបង្ហាញថា សមាជិក Pacoco កាន់តែចូលពាក់ព័ន្ធច្រើនក្នុងទិដ្ឋភាពផ្សេងៗនៃការងារអភិវឌ្ឍន៍ ក្រៅពីសមាគមសន្សំប្រាក់ និងសមាគមស្រូវជាប្រពៃណី, ដោយអ្នកខ្លះបានធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ និងខ្លះទៀតជា "ជនបង្គោល" នៃការអភិវឌ្ឍន៍សហគមន៍ ។ យោងតាមការសិក្សានេះ "បណ្តាញយ៉ាងធំទូលាយនៃគណៈកម្មការ និងសមាគមសន្សំប្រាក់ និងស្រូវ មានន័យថា សមាជិក Pacoco មានសក្តានុភាពល្អ ដើម្បីជួយជំរុញការចូលរួមរបស់មហាជននៅក្នុងការងារអភិបាលកិច្ចនៅមូលដ្ឋាន និងការអភិវឌ្ឍន៍សហគមន៍នៅស្រុកស្ទោង" (Warthon 2003:3) ។ ប៉ុន្តែការសិក្សាបានរកឃើញថា សឹងតែគ្មានការផ្ទេរចំណេះដឹងអ្វីជាផ្លូវការទេរវាង Pacoco សមាគមនានា និងពួកសមាជិកក្រុមប្រឹក្សាឃុំ ។ បទពិសោធន៍នៅស្ទោងបង្ហាញថា ត្រូវមានជំនួយគាំទ្រពីគំរោង ដើម្បីធ្វើការផ្លាស់ប្តូរពីការបណ្តុះបណ្តាល ទៅផ្តោតលើការរៀនសូត្រតាមរយៈការអនុវត្តន៍ និងដើម្បីសំរបសំរួលកិច្ចសហប្រតិបត្តិការរវាងសមាគម និងក្រុមប្រឹក្សាឃុំ ក្នុងការធ្វើផែនការ និងការអនុវត្តន៍គំរោងខ្នាតតូច ។ សព្វថ្ងៃ ការងារនេះត្រូវបានបំពេញបន្ថែមតាមការកសាងសមត្ថភាពអំពីការតស៊ូមតិ និងការផ្សព្វផ្សាយពត៌មាន, តាមការកសាងប័ណ្ណប្រកាសខ្នាតធំប៉ូស្ទ័រ និងខិត្តប័ណ្ណ, និងតាមការឧបត្ថម្ភគាំទ្រដល់កិច្ចប្រជុំនានានៅតាមវត្ត ដែលក្នុងនោះសមាជិកសមាគមអាចផ្លាស់ប្តូរបទពិសោធន៍ជាមួយពួកសមាជិកផងគ្នា និងជាមួយក្រុមប្រឹក្សាឃុំ ។

## ៤. សេចក្តីសន្និដ្ឋាន

Bonnal បានសរសេរអំពីទំនាក់ទំនងរវាងទុនសង្គមកិច្ច បណ្តាស្ថាប័នសហគមន៍តាមប្រពៃណី និងវិមជ្ឈការ ដោយបញ្ជាក់ថា "ការប្រឹងប្រែងធ្វើវិមជ្ឈការឱ្យបានធំទូលាយក្នុងពេលកន្លងមក ភាគច្រើនមិនបានពិចារណាពីសារៈសំខាន់ដ៏ធំក្រៃលែងនៃគំនិតឈ្វេងយល់ដែលមាននៅក្នុងមូលដ្ឋានទេ" (1997:1) ។ សព្វថ្ងៃនៅកម្ពុជា មានកិច្ចប្រឹងប្រែងដ៏ធំធេងរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិដើម្បីកែលំអសមត្ថភាព និងជំនាញរបស់សមាជិកក្រុមប្រឹក្សាឃុំ ។ Pacoco និងសមាគមនានា តំណាងឱ្យអង្គការសង្គមស៊ីវិលជាប្រពៃណី និងមានតួនាទីដ៏សំខាន់ក្នុងការលើកកំពស់អភិបាលកិច្ចនៅមូលដ្ឋាន, ជាពិសេសក្នុងសកម្មភាពឥណទានផ្សេងៗដែលផ្តល់លទ្ធភាពឱ្យពួកគេអាចរកមូលនិធិផ្គត់ផ្គង់ខ្លួនឯងបាន និងធ្វើជាតំនាងការពារផលប្រយោជន៍របស់គ្រួសារមួយចំនួនធំ ។ ហេតុនេះពួកគេត្រូវក្លាយជាមុខសញ្ញានិងត្រូវបានចូលពាក់ព័ន្ធក្នុងការងារកសាងសមត្ថភាពដ៏ជាក់លាក់មួយចំនួន ដែលរៀបចំដោយអ្នកផ្តល់ជំនួយ និងស្ថាប័នរដ្ឋាភិបាល ។ បទពិសោធន៍នៅស្រុកស្ទោងបង្ហាញថា ជំនួយគាំទ្រគួរផ្តោតលើបញ្ហាជាមូលដ្ឋាន ដូចជា វត្តមាន និងការចូលរួមក្នុងការប្រជុំផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ ដោយប្រើសំភារៈបណ្តុះបណ្តាលបែបសាមញ្ញៗ ហើយជាពិសេសតាមការជួយគាំទ្រដល់ការផ្លាស់ប្តូរទស្សនកិច្ចនៅក្នុងនិងក្រៅខេត្ត ។ រឿងនេះនឹងអនុញ្ញាតឱ្យសមាគមតាមវត្តជាប្រពៃណី អាចដើរតួនាទីយ៉ាងសកម្មនៅក្នុងអភិបាលកិច្ចនៅមូលដ្ឋាន និងបង្កើតឱ្យមានការជួយឧបត្ថម្ភទៅវិញទៅមកជាមួយក្រុមប្រឹក្សាឃុំ ។

### ឯកសារយោង

Aschmoneit, W., et al. (1997). *Pagoda Committees and Community Life in Kampong Thom Province Cambodia*, Kompong Thom: GTZ Self-Help Team

Aschmoneit, W. (1998) *Traditional Self-Help Associations in Cambodia: How to Identify and Cooperate with Them*, Eschborn (Germany): GTZ

Bonnal, J. (1997). "Relating Social Capital, Traditional Community Institutions and Decentralisation Processes," prepared for the Technical Consultation on Decentralization, FAO, Rome, 16-18 December 1997

Narak, S. (1998), "Historically Rooted Organizations in the Traditional Rural Community in Stung District, Kampong Thom province, Cambodia," Internal Report, GTZ Provincial Development Programme, Kompong Thom

Ovensen, J., Trankell, I. and Öjendal, J. (1996), *When Every Household Is an Island: Social organisation and power structures in rural Cambodia*, Uppsala Research Report in Cultural Anthropology, No. 15, Stockholm:

---

*តពីទំព័រទី ២០* **ពត៌មានថ្មីៗពី...**

ពេលអនាគត ។

**មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍**

នៅត្រីមាសទី២ ២០០៤ ក្រុមបណ្តុះបណ្តាលបានបើកវគ្គទី២ នៃការបណ្តុះបណ្តាលដើម្បីសន្តិភាព (ការបណ្តុះបណ្តាលគ្រូបង្គោល), វគ្គការងារកសាងសន្តិភាពពីរម៉ូឌុលធ្វើនៅ វបសអ, សិក្ខាសាលាបណ្តុះបណ្តាលវគ្គពិសេសមួយធ្វើនៅស្រុកវាលវែង ខេត្តពោធិសាត់ ។ នៅដើមខែកក្កដា លោកស្រី ហ៊ុយ រំដួល ប្រធានក្រុម មសអ បានទៅចូលរួមសិក្ខាសាលារយៈ ៥ថ្ងៃ ស្តីពីការយល់ដឹង និងការសះស្បើយពីរបួសផ្លូវចិត្តនៅ Harrisonburg VA, USA ឧបត្ថម្ភដោយ CWS-កម្ពុជា ។ ក្រុម មសអ បានចែករំលែកបទពិសោធន៍ស្តីពីទស្សនាទាននៃការផ្សះផ្សារ នៅឯ សេវាអភិវឌ្ឍន៍អាឡឺម៉ង់ (Deutscher Etwikklungs Dienst: DED) ។

**បណ្ណាល័យ**

តាំងពីដើមខែតុលា ២០០៣ បណ្ណាល័យមានអ្នកប្រើប្រាស់ជាសមាជិក ៥៧០នាក់ ។ បណ្ណាល័យបានពង្រីកការជាវសៀវភៅពីក្រៅប្រទេស ហើយនាពេលថ្មីៗ បានទទួលសៀវភៅជាង ១០០មុខ ពីអង្គការមូលនិធិអាស៊ី។ ការណែនាំបង្ហាញពីបណ្ណាល័យ មានធ្វើជាបន្តបន្ទាប់សំរាប់អ្នកប្រើប្រាស់ថ្មី

# ព័ត៌មានថ្មីៗ ពី វបសអ

## ផ្នែកគ្រប់គ្រង

នៅថ្ងៃ ៣ កក្កដា វបសអ បានប្រារព្ធបើកកិច្ចប្រជុំពាក់កណ្ដាលឆ្នាំនៃក្រុមប្រឹក្សាភិបាលរបស់ខ្លួន ហើយរបាយការណ៍ វបសអ ប្រចាំឆ្នាំ២០០៣ ត្រូវបានចែកចាយជូនអង្គប្រជុំ និងបានចុះផ្សាយលើ Website វបសអ ។ ទំរង់និងលក្ខណៈរបស់វា ត្រូវបានកែលំអថែមដើម្បីឱ្យកាន់តែមានប្រយោជន៍សំរាប់ការកសាងកេរ្តិ៍ឈ្មោះ វបសអ ការស្វែងរកដៃគូជាយុទ្ធសាស្រ្តថ្មីៗ និងការកសាងបណ្ដាញនៅឆមាសទី២ ២០០៤ ។

ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) បានបន្តការឧបត្ថម្ភរបស់ខ្លួនដល់ កម្មវិធីបរិស្ថាននិងធនធានធម្មជាតិរបស់ វបសអ រហូតដល់ពាក់កណ្ដាលឆ្នាំ២០០៦ ។

នៅខែមិថុនា ២០០៤ នាយកប្រតិបត្តិ វបសអ បានចូលរួមសិក្ខាសាលា ម ួ យ េ ន ៅ ជ ា ង ក ក ដើម្បីបង្កើតបណ្ដាញវិទ្យាស្ថានស្រាវជ្រាវឈានមុខនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនឹងធ្វើការលើបញ្ហាពាណិជ្ជកម្ម និងអង្គការពាណិជ្ជកម្ម ពិភពលោក (WTO) ។ បណ្ដាញស្រាវជ្រាវអាស៊ីប៉ាស៊ីហ្វិកស្ដីពីពាណិជ្ជកម្ម (ARTNET) នឹងត្រូវសំរបសំរួលដោយ UNESCAP និងឧបត្ថម្ភដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានអន្តរជាតិ(IDRC) ។ វានឹងជួយសម្រួលដល់កិច្ចសហការស្រាវជ្រាវ និងការកសាងសមត្ថភាពខាងគោលនយោបាយ និងការស្រាវជ្រាវ នៃវិទ្យាស្ថានអ្នកចូលរួមនានាស្ដីពីបញ្ហាពាណិជ្ជកម្ម និង WTO ។

## ផ្នែកស្រាវជ្រាវ

ការស្រាវជ្រាវរបស់ វបសអ បានពង្រីកទំហំ និងប្រធានបទយ៉ាងច្រើនក្នុងប៉ុន្មានខែថ្មីៗ ។ បច្ចុប្បន្ន មានការសិក្សាជាងដប់ដែលកំពុងដំណើរការ ។ នឹងមានការសិក្សាជាច្រើនថែមទៀត ដែលកំពុងស្ថិតក្នុងដំណាក់កាលចរចាជាមួយដៃគូ ។ ចំពោះការបោះពុម្ពឯកសារស្រាវជ្រាវរបស់ វបសអ មានការដាក់អនុវត្តយន្តការពិនិត្យស្នាដៃឡើងវិញដោយអ្នកមានឋានៈស្មើ ។ វបសអ បានពង្រីកសមត្ថភាពខ្លួនតាមរយៈគោលនយោបាយជ្រើសបុគ្គលិកដ៏សកម្ម ដោយផ្ដោតលើអ្នកស្រាវជ្រាវកម្ពុជាទាំងថ្នាក់ក្រោមៗ និងថ្នាក់ខ្ពស់ ។

បច្ចុប្បន្ន មានការសិក្សាជាច្រើនស្ថិតក្នុងដំណាក់កាលបញ្ចប់ ដូចជា ការសិក្សាលើសហគ្រាសធុនតូចនិងមធ្យម និងការសិក្សាជាមូលដ្ឋានពីការផ្ដល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី ។ ការសិក្សាពីរទៀតបានចប់សព្វគ្រប់ និងកំពុងបញ្ជូនសុំការជួយមតិៈ (ក) ការសិក្សាពីវិមជ្ឈការសារពើពន្ធ និង (ខ) ការសិក្សាពីការគ្រប់គ្រងធនធានព្រៃឈើមានតំលៃខ្ពស់ដោយសហគមន៍ ។

គំរោងស្រាវជ្រាវថ្មីៗដែលកំពុងដំណើរការ ឬស្ថិតក្នុងដំណាក់កាលជឿនលឿននៃការចរចាគឺៈ

- ការចេញឱ្យផុតពីភាពក្រីក្រ (ធនាគារពិភពលោក)
- ការវាយតំលៃពីភាពក្រីក្រដោយមានការចូលរួមនៅទន្លេសាប (ធនាគារអភិវឌ្ឍន៍អាស៊ី)
- អង្កេតតាមដានពីចំណាយសាធារណៈ-PETS (ធនាគារពិភពលោក)
- សេដ្ឋកិច្ចនៃធនធានធម្មជាតិ (DANIDA)
- ការផ្ដល់ប័ណ្ណសំគាល់កម្មសិទ្ធិដីនៅទីក្រុង (ធនាគារពិភពលោក, ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់)
- ការផ្ដល់សេវាកម្មថ្នាក់មូលដ្ឋាន (UNCDF)

អង្គភាពគ្រប់គ្រងទិន្នន័យមួយ ត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រង និងផ្ដល់ឱ្យបានប្រសើរនូវទិន្នន័យនៃអង្កេត និងការស្រាវជ្រាវរបស់ វបសអ នៅ

*តទៅទំព័រទី ១៩*

**ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ៕**

***Cambodia Development Review* is also available in English.**

**ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា**

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី៨ លេខ៣ ខែកក្កដា_កញ្ញា ឆ្នាំ២០០៤

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

អាសយដ្ឋានប្រៃសណីយ៍ៈ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទៈ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារៈ (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh

***ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា***
បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

***ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា*** ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

***ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

គ្រឹះស្ថានផ្សាយៈ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
គ្រប់គ្រងកែសំរួលៈ អែម សូវ៉ានី
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា /អ្នកបកប្រែៈ យូ សិទ្ធីរិទ្ធ
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ LMAP

**រក្សាសិទ្ធិ ២០០៤** វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560-7615**

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។